អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Jun-2012, 15:03
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៦៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក គឹម ម៉េងឃី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ឡូរ៍ ដេសហ្វកស៍
*(Ms.Laure DESFORGES)*

លោក បាណាបេ ណេគ្វី
*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ | អង់គ្លេស |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សគឹម ល្មុត (TCW-583) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ÷ លោក សគឹម លូត** (TCW-583)
បន្តសួរដោយ លោក វ៉េង ហ៊ាត់ ផ្ដើមពី៖ ........................................................................ ទំព័រ ៣
សួរដោយ លោក ចារីក អាប់ឌុលឡាក់ ផ្ដើមពី៖ ........................................................................ទំព័រ១៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងប្រគល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ថ្ងៃនេះមិនមានវត្តមានជនជាប់ចោទ អៀង សារី នៅក្នុងសាលសវនាការទេ។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពរបស់លោក អៀង សារី។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ ជនជាប់ចោទ អៀង សារី មានវត្តមាននៅក្នុងបន្ទប់ខាងក្រោម នៃបន្ទប់សវនាការ។ ជនជាប់ចោទ បានលះបង់សិទ្ធិតាមរយៈមេធាវីរបស់ខ្លួន ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០៣:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយស្នើសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដាន ស្ដាប់នូវកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះបាន។

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ តែគាត់មានលទ្ធភាពតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីការពារក្ដីរបស់គាត់បាន។

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការ ក្នុងបន្ទប់សវនាការនេះ ឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ដែលបានរៀបចំសម្រាប់គាត់នូវឧបករណ៍សោតទស្សន៍នៅក្រោមសវនាការនេះ សម្រាប់ថិរវេលានៃដំណើរការសវនាការពេញមួយថ្ងៃនេះ។

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:០៥:៤២]

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម។ គ្រាន់តែចង់សូមជម្រាបជូនលោកចៅក្រមប្រធាន និងលោក លោកស្រីចៅក្រមថា មេធាវីនាំមុខសូមអនុញ្ញាតប្រគល់សិទ្ធិជូនមេធាវី ស៊ីន ស៊ុវ៉ន ហើយនិងលោកមេធាវី បាណាបេ ណេគ្វី ដើម្បីធ្វើអន្តរាគមន៍ពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំ របស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅ ក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក វ៉េង ហ៊ត់៖**

សូមគោរពលោកប្រធាន សូមគោរពអង្គចៅក្រមទាំងមូល និងសូមគោរពភាគីទាំងអស់ដែលចូលរួមក្នុងអង្គសវនាការ ព្រមទាំងសូមគោរពបងប្អូនៗ លោក លោកស្រី ដែលបានចូលរួមនៅក្នុង ក្រៅអង្គសវនាការនេះ។

[០៩:០៧:០៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វើង ហ៊ាត់៖**

**ស៖** កាលពីម្សិលមិញ ខ្ញុំបានសាកសួរលោក ល្មុត ឥឡូវនេះ ខ្ញុំនឹងសួរលោកបន្តទៀត។ មុននឹងខ្ញុំសួរបន្ត ខ្ញុំសូមរំឭកសំណួរម្សិលមិញចុងក្រោយបន្តិច។ ខ្ញុំសួរលោកថា តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាហានដែលពិការនោះ ត្រូវបានគេរៀបចំឲ្យរៀបការជាមួយនឹងស្ត្រី តើលោកដឹងឬទេ? លោកឆ្លើយថា មិនដឹងទេ។ តើអ៊ីចឹងមែនទេលោក?

**លោក សគីម ល្មុត៖**

**ឆ៖** បាទអ៊ីចឹងមែនហើយ គឺខ្ញុំបាទមិនដឹងទេបាទរឿងហ្នឹង។

**ស៖** បាទ អរគុណលោក។ ខ្ញុំសូមអនុញ្ញាតសួរលោក ល្មុត ទាក់ទងពីបញ្ហាជំនឿសាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យម្តង។ តើលោកធ្លាប់ឮពាក្យ “ប្រតិកិរិយា” ឬទេ?

**ឆ៖** បាទ ធ្លាប់ឮ។

[០៩:០៨:៤៤]

**ស៖** ចុះពាក្យ “សាសនា ប្រតិកិរិយា” តើធ្លាប់-- លោកធ្លាប់ឮទេ?

**ឆ៖** ពាក្យនេះ ចំពោះរូបខ្ញុំមិនដែលអ្នកណានិយាយអ៊ីចឹងជាមួយខ្ញុំទេបាទ។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកបានឃើញព្រះសង្ឃនៅតាមវត្តអារាមឬទេ?

**ឆ៖** នៅក្នុងកន្លែងដែលសហករណ៍ខ្ញុំ នៅហ្នឹងមានវត្តមានវ៉ាអ៊ីចឹងដែរ ប៉ុន្តែពេលនុ៎ងមិនដែលមានព្រះសង្ឃអីគង់នៅអីទេ។

**ស៖** លោកអាចរៀបរាប់បានទេនៅក្នុង-- តើព្រះសង្ឃនៅក្នុងសម័យនោះ គេចាត់ទុកព្រះអង្គជាច្រើនរូបជាពួកកាន់សាសនាប្រតិកិរិយាដែរទេ?

[០៩:១០:១២]

**ឆ៖** បញ្ហានេះគ្មានអ្នកណានិយាយអ៊ីចឹងជាមួយខ្ញុំទេបាទ។

**ស៖** សាសនាដទៃទៀតដូចជា សាសនាយាស៊ូគ្រិស្ត និងអ៊ីស្លាម តើគេមានប្រាប់លោកថាជាសាសនាប្រតិកិរិយា ឬក៏សាសនាយ៉ាងម៉េចដែរ លោកអាចពន្យល់បានទេ?

**ឆ៖** ខ្ញុំមិនអាចពន្យល់បានទេ ពីព្រោះគ្មានអ្នកណានិយាយជាមួយខ្ញុំយ៉ាងនេះ។

**ស៖** អរគុណលោក ល្មុត។ ឥឡូវនេះ ខ្ញុំបន្តសំណួរទៅដល់ផែនការរួម។ នៅក្នុងមុនខែមេសា

ឆ្នាំ១៩៧៥ លោក ល្មុត បានឆ្លើយកាលពីម្សិលមិញហើយថា លោកបានចូលនៅក្នុងចលនាបដិវត្តន៍។ លោកបានប្រឹងប្រែងជួយទាំងកម្លាំងកាយ បញ្ញាញាណ និងលុយផង។ ខ្ញុំសូមសួរលោកថា តើលោកមានបានចូលរួមប្រជុំជាញឹកញាប់ជាមួយនឹងមេដឹកនាំទាំងនោះទេ?

[០៩:១១:៥៥]

**ផ៖** បាទ គ្មានទេបាទ គ្មានទេ។

**ស៖** លោកមិនបានចូលរួមប្រជុំមែន លោកឆ្លើយអម្បាញ់មិញ ក៏ប៉ុន្តែមានមធ្យោបាយណាដែលលោកអាចដឹងថា ផែនការដើម្បីវាយយកទីក្រុងភ្នំពេញទេ?

**ផ៖** ខ្ញុំអត់បានដឹងអំពីផែនការយ៉ាងណាៗនោះទេបាទ។

**ស៖** តើលោកបានដឹងអំពីមធ្យោបាយ ដែលបក្សកុម្មុយនីស្តកម្ពុជារៀបចំជម្លៀសប្រជាជនចេញ ពីទីក្រុងភ្នំពេញទេ?

**ផ៖** បាទ ខ្ញុំអត់បានដឹងជាមុនទេបាទ អត់បានដឹងទេបាទ។

**ស៖** អរគុណលោក។ ឥឡូវនេះ សំណួរខ្ញុំសួរនៅក្នុងខែមេសា ឆ្នាំ១-- ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ បានមកដល់។ ខ្ញុំសួរលោកថា តើអាចប្រាប់បានទេថា លោកស្ថិតនៅកន្លែងណា?

**ផ៖** ថ្ងៃនោះ ខ្ញុំនៅផ្ទះភ្នំពេញ។

**ស៖** តើលោកដឹងថា ក្រុងភ្នំពេញពេលនោះយ៉ាងម៉េចដែរ?

**ផ៖** ពេលនោះ ខ្ញុំនៅផ្ទះដឹងតែម្តុំជុំវិញក្បែរៗផ្ទះហ្នឹង ឃើញមានយុទ្ធជនខាងខ្មែរក្រហមហ្នឹងចូលមក។ ឃើញតែជុំវិញប៉ុណ្ណឹង ហើយត្រង់សង្កាត់អីផ្សេងៗយ៉ាងណាៗ ខ្ញុំមិនបានដឹងទេ ព្រោះនៅតែក្នុងផ្ទះ ក្បែរៗផ្ទះហ្នឹង។

[០៩:១៤:៣៦]

**ស៖** នៅពេលដែលលោកឃើញយុទ្ធជន គឺលោកសំដៅលើទាហាន ឬមួយក៏សំដៅលើជនស៊ីវិល?

**ផ៖** គឺសំដៅលើទាហាន ព្រោះគេស្ពាយកាំភ្លើង។

**ស៖** ទាហានរបស់ខ្មែរក្រហមមានបាននិយាយអ្វីជាមួយលោកទេ?

**ផ៖** ពេលដែលចូលមកហ្នឹង គឺអត់ឃើញ គេអត់មាននិយាយអីទេ គ្រាន់តែគេដើរក្បែរផ្ទះយើងអ៊ីចឹងទៅ។ អត់មាននិយាយអីទេ ពេលនុ៎ង។

**ស៖** តើគេមានប្រាប់លោកថាឲ្យចាកចេញពីទីក្រុងភ្នំពេញដែរទេ?

**ឆ៖** បាទ ដល់ថ្ងៃរសៀលបន្តិច គេមកប្រាប់ថា ឲ្យចេញទាំងអស់គ្នា ទៅប្រហែលជាពីរបីថ្ងៃទេ ត្រូវចេញ។

**ស៖** ខ្ញុំសូមអានសំណួរលើកឡើងវិញថា ខ្មែរក្រហមគេបានបញ្ជាឲ្យលោកចេញតែពីរបីថ្ងៃទេ។ ភ្ជាប់នឹងសំណួរនេះ តើគេមាននិយាយអំពីទ្រព្យសម្បត្តិរបស់ប្រជាជននោះ តើត្រូវចាត់ចែង ឬក៏យកទៅតាម ឬក៏យ៉ាងម៉េច? សូមលោកជួយពន្យល់ផង។

[០៩:១៦:៥៧]

**ឆ៖** គេអត់ប្រាប់ថា យ៉ាងម៉េចៗទេ គ្រាន់តែថាត្រៀមស្បៀង ត្រៀមអី យើងពីរបីថ្ងៃប៉ុណ្ណឹង។ មិនបានប្រាប់ល្អិតថា ត្រូវយកអី មិនយកអី។ មិនមានអី ឲ្យល្អិតទេ។

**ស៖** នៅក្នុងពេលដែលលោកធ្វើដំណើរចេញពីទីក្រុងភ្នំពេញ តើលោកបានឃើញសភាពប្រជាជននៅតាមផ្លូវយ៉ាងម៉េចដែរ?

**ឆ៖** ពេលដែលចេញទៅហ្នឹង គឺថាឃើញតាមផ្លូវចង្អៀតណែនណាន់តាន់តាប់ ហើយម្នាក់ៗក៏មិនដឹងថា ទៅណាទៅណីដែរទេ ទាំងរូបខ្ញុំហ្នឹង អ៊ីចឹងដែរ។

**ស៖** នៅពេលដែលលោកចេញពីទីក្រុងដំបូងនោះ តើលោកទៅសុំចតទៅទីណាដែរ?

**ឆ៖** ខ្ញុំទៅសុំចត នៅផ្ទះសាច់ញាតិដែលឆ្ងាយទេ នៅម្តុំក្នុងភូមិមួយ ហៅភូមិចំប៉ា នៅក្នុងស្រុកកៀនស្វាយ ផ្លូវជាតិលេខ១ យើងហ្នឹង។ ខ្ញុំសុំចតនៅផ្ទះរបស់គាត់។

**ស៖** នៅស្ថានភាពតាមផ្លូវដែលលោកធ្វើដំណើរទៅនោះ លោកបានឃើញប្រជាជន ឬក៏មនុស្សចាស់ ឬក៏កុមារ ស្ថិតនៅក្នុងស្ថានភាពដូចម្តេចដែរ លោក?

**ឆ៖** ពេលចេញទៅនោះ គឺថាឃើញថា ដូចថា ចេញទៅទាំងគ្រួសារៗ។ គ្រួសារនីមួយៗនោះវាមានចាស់ មានក្មេង ទៅទាំងអស់គ្នាអ៊ីចឹងទៅ ហើយមិនឃើញជាស្អីឲ្យប្លែកទេ គ្រាន់តែថាវាទៅអ៊ីចឹង។ ទាំងក្មេង ទាំងចាស់ គ្រួសារយើង គ្រួសារគេ។ ហើយត្រង់អ្នកណាហួសទៅណា មកណាទៀតក៏មិនដឹងដែរទេ ឃើញតែនៅកកកុញនៅម្តុំៗកៀនស្វាយ ម្តុំអី នៅនុំង។

[០៩:២០:០០]

**ស៖** នៅក្នុងស្ថានភាពដែលច្របូកច្របល់យ៉ាងនេះ តើអង្គការមានបានរៀបចំដូចជាពេទ្យ ឬក៏ប្រព័ន្ធសង្គ្រោះអីស្រួលបួលសម្រាប់ប្រជាជនទេ?

**ផ៖** ខ្ញុំមិនឃើញមានទេបាទ។

**ស៖** តើលោកនៅកៀនស្វាយនោះរយៈពេលប៉ុន្មានដែរ? ហើយលោកធ្វើការងារអ្វីនៅទីនុ៎ង?

**ផ៖** នៅពេលនោះ ដូចថាៗ ស្គាល់ជាសាច់ញាតិនៅកន្លែងនោះ ខ្ញុំក៏-- គេថាមានសហករណ៍ខ្ញុំក៏សូមចូលទៅជាសហករណ៍នៅកន្លែងនុ៎ងទៅ។ ហើយនៅប្រហែលតែ-- ខ្ញុំមិនចាំច្បាស់ទេ មួយខែប្លាយ ឬក៏ពីរខែមិនដឹងទេ ក៏មានគេទៅហៅខ្ញុំចេញមក មកនៅសហករណ៍ថ្មីមួយទៀត នៅខាងត្បូងភ្នំពេញនេះ។

**ស៖** នៅក្នុងសហករណ៍ទីមួយ ដែលលោកបានចូលទៅដល់ដំបូងនោះ តើរបៀប ឬក៏ការរស់នៅ និងហូបចុកនោះយ៉ាងម៉េចដែរលោក?

[០៩:២២:០០]

**ផ៖** ពេលនោះគឺឃើញដូចជាមិនទាន់មានការរៀបរយអីទេ ទៅតាមនុ៎ង គឺតាមមួយៗហ្នឹងខំដោះស្រាយខ្លួនឯងអ៊ីចឹងទៅ ដូចរកត្រី រកអីនៅជិតទន្លេមេគង្គហ្នឹង ទៅរកអី ដូចជានៅតាមរៀងៗគ្រួសារ មិនទាន់ឃើញរៀបចំឲ្យទៅយ៉ាងម៉េចៗមិនទាន់មានច្បាស់លាស់ដែរទេ។

**ស៖** បាទ តើនៅក្នុងសហករណ៍ទីពីរ ដែលលោកបានត្រូវគេជម្លៀសបន្តទៅទៀតនោះស្ថានភាពហូបចុកនៅក្នុងសហករណ៍នោះយ៉ាងម៉េចដែរ?

**ផ៖** សហករណ៍នេះមិនមានការខ្វះខាតអីទេ ប៉ុន្តែគ្រាន់តែវាមិនសម្បូរ តែក៏មិនជាខ្វះខាតអីដល់អត់ឃ្លានទេ សហករណ៍នេះ។

**ស៖** តើទ្រព្យសម្បត្តិរបស់លោក គេមានប្រាប់ឲ្យយកទៅដាក់រួមទេពេលនុ៎ង?

**ផ៖** គេប្រាប់ដែរ ប៉ុន្តែខ្ញុំគ្មានស្អីយកទៅដាក់ទេ អស់អី អត់មានអីរលីង អត់មានអី។ មានតែនាឡិកាអីមួយអីអ៊ីចឹង អត់មានអីទៀតទេ។

**ស៖** ខ្ញុំឃើញថា នៅក្នុងមួយជីវិតរបស់លោក ខិតខំប្រឹងធ្វើការសន្សំទ្រព្យសម្បត្តិ។ អ៊ីចឹងទ្រព្យសម្បត្តិដែលលោកចេញពីភ្នំពេញទៅ គឺលោកមិនបានយកទៅតាមទេមែនទេ?

**ផ៖** បាទ អត់បានទេ បាទ។

[០៩:២៤:១៥]

**ស៖** តើលោកបានដឹងជោគវាសនាទ្រព្យសម្បត្តិរបស់លោក ត្រូវបានអង្គការរឹបអូសយកទេ?

**ផ៖** ពេលដែលខ្ញុំចេញពីភ្នំពេញទៅហ្នឹងគឺថា សល់តែផ្ទះមួយនៅភ្នំពេញហ្នឹង អីវ៉ាន់ប្រើប្រាស់

ក្នុងផ្ទះហ្នឹង ហើយត្រង់គេយកមិនយកអី ខ្ញុំក៏មិនដឹងដែរទេ។ ហើយពេលដែលខ្ញុំចេញទៅហ្នឹងគឺ មានរថយន្តផ្ទាល់ខ្លួនដឹកអីវ៉ាន់បន្តិចបន្តួច ហើយចាស់ៗជិះទៅជាមួយហ្នឹង ទៅដល់កៀនស្វាយហ្នឹងក៏ប្រគល់ឲ្យគេអស់ទៅ។ ដូច្នេះអស់រលីងត្រឹមកៀនស្វាយហ្នឹងហើយ។

**ស៖** ពេលទៅដល់កន្លែងសហករណ៍នីមួយៗ តើគេមានកត់ ឬក៏ដកស្រង់ប្រវត្តិរូបលោកទេ?

**ឆ៖** កាលនៅសហករណ៍ទីមួយ មិនទាន់មានធ្វើអីប្រវត្តិរូបទេ ដូចថាកំពុងតែរៀបចំដំបូងហ្នឹង វាមិនដឹងជាការចាត់បែបនៅច្របូកច្របល់ដែរ មិនឃើញមានធ្វើប្រវត្តិរូបទេ ទាល់តែមកសហករណ៍ទីពីរ អាហ្នឹងបានឲ្យធ្វើប្រវត្តិរូប។

[០៩:២៥:៥២]

**ស៖** តើលោកដឹងថា ប្រវត្តិរូបរបស់លោកនេះ ត្រូវបានគេបញ្ជូនទៅណាទេ?

**ឆ៖** ខ្ញុំមិនដឹងទេបាទ។

**ស៖** អរគុណលោក។ នៅក្នុងសហករណ៍នីមួយៗនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសសហករណ៍ដែលលោកបានទៅដល់ គេមានបែងចែកឋានៈប្រជាជន ដូចជាប្រជាជន១៧ មេសា ប្រជាជនចាស់ ប្រជាជនថ្មីទេ?

**ឆ៖** នៅសហករណ៍ទីមួយហ្នឹង គឺថាមិនទាន់មានទេ ទូទៅអ្នកណានៅត្រង់ណា នៅត្រង់ហ្នឹងសិនទៅ មិនទាន់មានការបែងចែកអីអ៊ីចឹងទេបាទ។

**ស៖** ចុះសហករណ៍ទីពីរ?

**ឆ៖** សហករណ៍ទីពីរ គឺថានៅកន្លែងហ្នឹងច្រើនតែ គឺថាបញ្ញាជនចេញពីភ្នំពេញទៅហ្នឹង មានជាគ្រូសាស្ត្រាចារ្យអីសព្វគ្រប់ ជាមួយរដ្ឋមន្ត្រីហ្នឹង។ ហើយមានកម្មករខ្លះ កម្មកររោងចក្រភ្នំពេញហ្នឹង ហើយមានកសិករមូលដ្ឋាន ពីម្តុំហ្នឹងខ្លះ ពីខាងត្បូងៗហ្នឹង ម្តុំជើងឯកអ៊ីចឹង ក៏មកនៅក្នុងសហករណ៍ហ្នឹងដែរ។ ដូច្នេះវារួមមានពួកបញ្ញាជន ពួកកម្មករ ពួកសិករ។ ហើយដូចជាមិនបែងចែកអីច្បាស់លាស់គឺថា ពិតមែនតែខ្លះបញ្ញាជន ខ្លះកម្មករ ខ្លះកសិករ ក៏នៅរួមគ្នាអ៊ីចឹងទៅ ធ្វើការដូចៗគ្នា ការធ្វើកសិកម្មធ្វើស្រែចម្ការដូចគ្នា ទាំងអស់គ្នាហ្នឹងនៅអ៊ីចឹងទៅ។

[០៩:២៨:០១]

**ស៖** តើនៅក្នុងស្ថានភាពនោះ លោកមានប្រពន្ធហើយ ឬក៏មានកូនហើយនៅ?

**ឆ៖** បាទ មានហើយបាទ។

**ស៖** នៅក្នុងសហករណ៍ តើកូនរបស់លោក និងប្រពន្ធរបស់លោកនៅជុំគ្នាដែរទេពេលនោះ?

**ឆ៖** បាទ ជុំគ្នា។ លើកលែងតែកូនមួយដែលនៅបរទេស អាហ្នឹងគេអត់មានមកពាក់ព័ន្ធអីទេបាទ។

**ស៖** បាទ។ ខ្ញុំសួរបន្តទៀត តើនៅពេលណាដែលគេបញ្ជូនលោកមកភ្នំពេញ?

**ឆ៖** ខ្ញុំមិនចាំថ្ងៃខែច្បាស់ទេ ប៉ុន្តែខ្ញុំចាំត្រង់ណេះ គឺថាពេលទៅសហករណ៍ហ្នឹង ខ្ញុំចូលរួមធ្វើស្រែបានមួយវស្សា ហើយក៏ច្រូតទុកដាក់អីទៅ រៀបចំបើង រៀបអីទុកដាក់ អាពេលនុ៎ងហើយ ដែលកំពុងរៀបចំ ទុកដាក់ចំបើងអីហ្នឹង ខ្ញុំវាឲ្យធ្វើខាងហ្នឹង ហើយក៏មានខាងៗលើនេះ ឲ្យហៅខ្ញុំថាមកភ្នំពេញ អង្គការខាងលើ អាចថា៧៦ ដើមឆ្នាំ៧៦ ខ្ញុំហាក់ប្រហែល ខ្ញុំមិនចាំច្បាស់ទេ។

**ស៖** ពេលនោះលោកចាំទេ ថាមានអ្នកណាខ្លះត្រឡប់មកជាមួយលោក?

**ឆ៖** មានតែខ្ញុំម្នាក់ឯងទេបាទ។

**ស៖** គេមានប្រាប់ថា មូលហេតុអីដែលឲ្យលោកមកភ្នំពេញទេ?

**ឆ៖** ពេលនោះគេអត់បានប្រាប់មូលហេតុទេ បាទ។

**ស៖** ពេលមកដល់ភ្នំពេញ តើលោកឃើញសភាពទីក្រុងភ្នំពេញយ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ មកដល់ទីក្រុងភ្នំពេញឃើញមានសភាពស្ងាត់ជ្រងំ។

**ស៖** ខ្ញុំសួរសំណួរថយក្រោយបន្តិច អម្បាញ់មិញលោកថា ត្រឡប់មកភ្នំពេញហ្នឹងមកតែម្នាក់ឯងទេ ចុះគ្រួសារ និងកូនរបស់លោកនោះ គាត់អញ្ជើញមកមួយដែរទេ?

**ឆ៖** អត់ទេបាទ។ អត់មកទេ បាទ។ គាត់នៅសហករណ៍ដដែល។

**ស៖** តើពេលណាដែលលោកអាចជួបប្រពន្ធកូនលោកវិញបាន?

[០៩:៣១:៤០]

**ឆ៖** បាទ ក្នុងពេលពីរបីអាទិត្យ ឬក៏កន្លះខែអីចឹងគេអនុញ្ញាតឲ្យខ្ញុំទៅលេងប្រពន្ធកូនបានដែរ។ ទៅមួយយប់អីចឹងទៅ ឬមួយថ្ងៃអីចឹងទៅ ហើយមកវិញមក។

**ស៖** ពេលដែលគេអនុញ្ញាតឲ្យលោកនោះ តើគេមានធ្វើសំបុត្រដើរផ្លូវទេ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែដូចជាអត់ទេ។ ដូចខ្ញុំមិនច្បាស់ ខ្ញុំថាដូចជាអត់ បាទដូចជាអត់ទេ។

**ស៖** អ្នកណាទទួលខុសត្រូវលើការអនុញ្ញាតឲ្យលោក ដើរទៅជួបប្រពន្ធដោយគ្មានលិខិតដើរផ្លូវបែបហ្នឹង?

**ឆ៖** គឺប្រធាន ដែលអ្នកទទួលខុសត្រូវលើខ្ញុំនៅភ្នំពេញហ្នឹង គឺថាគេប្រាប់អ៊ីចឹងទៅ ហើយខ្ញុំក៏ពេលឱ្យទៅហ្នឹងខ្ញុំជិះកង់អ៊ីចឹងទៅ ជិះតាមស្ទឹងមានជ័យអីហូរហែទៅ ទៅដល់មានកន្លែងប៉ុស្តិ៍យាមយោធាអីទៅ គេសួរខ្ញុំទៅណា ហៅអ៊ំ ហៅអីអ៊ីចឹងទៅ ខ្ញុំមិនចាំថា ខ្ញុំទៅសហករណ៍ខាងមុខនេះ។ សហករណ៍នោះ ហើយគេថា អ៊ីចឹងអញ្ជើញចុះ! តែប៉ុណ្ណឹង។ អត់មានឆែកសួររកសំបុត្ររកស្នាមអីទេ។

[០៩:៣៣:២០]

**ស៖** ប្រធានដែលទទួលខុសត្រូវអនុញ្ញាតឱ្យលោកទៅហ្នឹង គាត់ឈ្មោះអីដែរ?

**ឆ៖** ពេលនុ៎ងគឺ គាត់ឈ្មោះ ឌឿន ជាប្រធានគណៈកម្មការពាណិជ្ជកម្មជំនាន់នុ៎ង។

**ស៖** ឥឡូវនេះ សំណួរខ្ញុំបានចូលកៀកមកដល់ក្រសួងពាណិជ្ជកម្ម ហើយអ្វីដែលខ្ញុំសួរនៅពេលបន្ទាប់នេះ គឺទាក់ទងតែក្រសួងពាណិជ្ជកម្មទេ។ ខ្ញុំសួរថា តើលោកស្នាក់នៅកន្លែងណាដំបូង នៅពេលដែលគេបញ្ជូនលោកមកដល់ភ្នំពេញ?

**ឆ៖** មកដល់ភ្នំពេញ ជាបណ្តោះអាសន្នគេឱ្យខ្ញុំស្នាក់នៅផ្ទះមួយក្បែរ យើងឥឡូវយើងថាក្រសួងឧស្សាហកម្មអ៊ីចឹង ប៉ុន្តែពេលនោះគេមិនហៅក្រសួងទេ គឺគណៈកម្មការឧស្សាហកម្ម ហើយខ្ញុំនៅ ឱ្យនៅផ្ទះមួយក្បែរគ្នានុ៎ង ឱ្យនៅបណ្តោះអាសន្នក៏នៅចាំអ៊ីចឹងទៅ។ នៅត្រង់នុ៎ងបាទ។

**ស៖** ពេលនោះលោកបានជួបអ្នកណាខ្លះនៅទីនោះ?

**ឆ៖** ពេលនោះគឺថា ដោយសារខ្ញុំទៅស្នាក់នៅក្បែរមន្ទីរឧស្សាហកម្មហ្នឹង ក៏ប្រធានឧស្សាហកម្មហ្នឹងជួបខ្ញុំថាឱ្យបងឯងនៅហ្នឹងសិនទៅ ជួបគាត់ហ្នឹង ហើយគាត់ជាប្រធានគណៈកម្មការឧស្សាហកម្ម។

**ស៖** ប្រធានហ្នឹង គាត់ឈ្មោះអីដែរលោក?

**ឆ៖** គាត់ឈ្មោះ អន។

[០៩:៣៦:០៦]

**ស៖** លោកអាចស្គាល់ឈ្មោះពេញរបស់គាត់ទេ?

**ឆ៖** ខ្ញុំមិនស្គាល់ទេបាទ។ ខ្ញុំដឹងតែឈ្មោះ អន គេហៅ អន លោក មិត្តអនៗអ៊ីចឹង។

**ស៖** តើលោកទទួលខុសត្រូវភារកិច្ចអ្វីខ្លះនៅពេលនុ៎ង?

**ឆ៖** ពេលនុ៎ងមិនទាន់មានការបញ្ជាក់ថា ឱ្យខ្ញុំធ្វើអីៗអត់ទាន់មានទេ គ្រាន់តែថាស្នាក់នៅចាំអ៊ីចឹងទៅ។

**ស៖** តើគេមានប្រជុំដើម្បីជាការបង្ហាញខ្លួន របស់លោកជាលើកដំបូងដែរទេ?

**ឆ៖** បាទ មិនមានទេបាទ។

**ស៖** លោកបាន-- លោកធ្លាប់ជួបគណៈប្រតិភូមកពីប្រទេសក្រៅដែរទេ?

**ឆ៖** បាទ ធ្លាប់ ធ្លាប់ជួបបាទ។

**ស៖** កម្មវត្ថុនៃគណៈប្រតិភូមនោះ គេមកតើក្នុងគោលបំណងអ្វីដែរលោក?

**ឆ៖** គេមកដើម្បីជជែកគ្នា អំពីការ គឺថា ដោះដូរពាណិជ្ជកម្មរវាងប្រទេសគេនុ៎ង ហើយនិងប្រទេសកម្ពុជាប្រជាធិបតេយ្យហ្នឹងបាទ។

[០៩:៣៨:២១]

**ស៖** ប្រទេសគេដែលលោកបាននិយាយនេះ គឺសំដៅទៅលើប្រទេសអីដែរ?

**ឆ៖** បាទ គឺប្រទេសចិនបាទ គឺចិនប្រជាមានិតបាទ។

**ស៖** ពេលនោះយើងមានការបង្កើតធនាគារ សម្រាប់នាំចេញក្រៅប្រទេសហើយនៅ?

**ឆ៖** ពេលនោះមិនទាន់មាននៅឡើយទេបាទ។

**ស៖** បើមិនទាន់មាន តើទំនាក់ទំនងរវាងបរទេសនោះ គេរៀបចំរបៀបម៉េចដែរ ដើម្បីធ្វើពាណិជ្ជកម្មនោះ?

**ឆ៖** ជាដំបូងគឺថា គេគ្រាន់តែថា ពន្យល់យើងថា របៀបរបបធ្វើពាណិជ្ជកម្មដោះដូរគ្នា ត្រូវធ្វើរបៀបម៉េចៗ ត្រូវមានដូចថា មានធនាគារ មានអីអ៊ីចឹង ប៉ុន្តែមិនទាន់បង្កើតទេ ហើយពេលគេពន្យល់ការងារពីបែបបទធនាគារមក ភាគច្រើននៅខាងភាគីខ្មែរហ្នឹង មិនមានអ្នកណាយល់ដឹងទេ។ មានតែខ្ញុំៗអាចយល់ដឹង មិនមែន១០០ភាគរយទេ គឺយល់ដឹងគួរសម ហើយក៏ជួយពន្យល់មកខាងខ្មែរយើងដូចថាបែបបទខ្លះទៅ។ ដូច្នេះពេលនុ៎ងមិនមានបង្កើតទេ។

[០៩:៤០:៣០]

**ស៖** ក្នុងចន្លោះអំឡុងឆ្នាំដែរទៅ ដែលត្រូវបង្កើតធនាគារ ហើយប្រធានដែលៗគ្រប់គ្រងធនាគារហ្នឹងអ្នកណាដែរ?

**ឆ៖** ខ្ញុំមិនចាំច្បាស់ខែឆ្នាំនោះទេ រវាងចុងប្រាំមួយអីក៏មិនដឹងណា សូមអភ័យទោស ខ្ញុំមិនច្បាស់ខែ និងឆ្នាំទេ។ ហើយនៅពេលនោះ បង្កើតហ្នឹងដាក់ឈ្មោះធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។ ហើយប្រធានឈ្មោះ-- សូមៗថយមកវិញ គឺថាអ្នកដែលគ្រប់គ្រងធនាគារហ្នឹងនៅក្នុងលិខិត

បញ្ជាក់បង្កើតហ្នឹងមានតែពីរនាក់ទេ គឺម្នាក់ជាអគ្គនាយក ម្នាក់ជានាយករង តែពីរនាក់ទេ។ ហើយអគ្គនាយកហ្នឹង ខ្ញុំមិនចាំឈ្មោះអស់ ភ្លេចហើយ គឺថាដឹងតែនាមត្រកូលគាត់ហ្នឹង ម៉ី ក្នុងនឹង ម៉ី មិនដឹងជា ម៉ី ខាន់, ម៉ី ចាន់, ម៉ី អីខ្ញុំសូមអភ័យទោស ខ្ញុំមិនចាំទេ វា-- ហើយនិងឈ្មោះខ្ញុំបាទហ្នឹងជានាយករង។ ហើយសូមបញ្ជាក់អ៊ីចេះថា ប្រធានហ្នឹង ខ្ញុំមិនដែលឃើញមុខទេ មានតែឈ្មោះហ្នឹង ប៉ុន្តែខ្ញុំមិនដឹងមុខមាត់ម៉េច ហើយក៏មិនដែលជួបគ្នាដែរ។ មិនដែលជួបគ្នាទេ។

[០៩:៤២:២៨]

**ស៖** ទាក់ទងនឹងរចនាសម្ព័ន្ធធនាគារ ដែលត្រូវបង្កើតនេះ ខ្ញុំសូមសួរលោក តើធនាគារនេះស្ថិតនៅក្រោមស្ថាប័នណាមួយដែរលោក?

**ឆ៖** ខ្ញុំមិនច្បាស់ថាស្ថិតនៅក្រោមស្ថាប័នណាទេបាទ មិនច្បាស់ទេ។

**ស៖** នៅក្នុងប្រតិបត្តិការនៃរបបធនាគារ គឺគេត្រូវមានរបាយការណ៍ជាប្រចាំ តើលោកធ្វើរបាយការណ៍ទៅបុគ្គលណាដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ល្អិតបន្តិច គឺថាធនាគារនេះដូចខ្ញុំបាទជម្រាបពីខាងដើមអ៊ីចឹង គឺមានប្រធានអគ្គនាយក ហើយនាយករង។ អគ្គនាយក ខ្ញុំមិនដឹងបុគ្គលមុខមាត់យ៉ាងម៉េចទេ។ ហើយខាងក្រោមនេះមានខ្ញុំ ហើយវាគ្មានផ្នែកគណនេយ្យ ផ្នែករដ្ឋបាល ផ្នែកអីទេ ព្រោះវាគ្មានមនុស្ស។ ដូច្នេះរបបរាយ-ការណ៍នោះ ពេលណាត្រូវការសួរអី ក៏សួរទៅ គ្មានថា វាគ្មានគណនេយ្យ ខាតចំណេញអីក៏អត់មានរាយការណ៍។ ដូច្នេះធនាគារមានតែឈ្មោះធនាគារ ហើយមានម្នាក់ខ្ញុំហ្នឹងមិនអាចធ្វើអីគ្រប់មុខទេ ហើយមានឃើញទារថាត្រូវរបាយការណ៍អ៊ីចេះអ៊ីចុះទេ ហើយពេលត្រូវការថាពេលប្រជុំអីមានគណៈប្រតិភូអីមក ទៅមានមុខនៅនុំងទៅ។ ថាអ្នកនេះៗជាធនាគារ ទៅគ្រាន់តែអង្គុយស្ដាប់ទេ គ្មានទៅមានយោបល់ មានអីទេ។ អាហ្នឹងវា-- ហើយបើថាយូរៗមានរាយការណ៍អីបន្តិចបន្តួចហ្នឹង ក៏យើងមាននីរសារមួយឲ្យយកទៅមន្ទីរៗមួយខាងលើ ប៉ុន្តែមិនដឹងនៅកន្លែងណាទេ។ ខ្ញុំមិនដឹងដែរ។ ដឹងតែនីរសារគេដឹងទៅ យកទៅៗកន្លែងនោះទៅ។ ហើយខ្ញុំក៏មិនប៉ានសួរគេថា អ្នកឯងយកទៅត្រង់ណា? ផ្ទះត្រង់ណា? អត់ប៉ានសួរទេ។

[០៩:៤៥:២៦]

**ស៖** អ៊ីចឹងប្រព័ន្ធនីរសារនេះក៏ស្ថិតនៅក្នុង-- ជាអ្នកផ្ដល់ព័ត៌មាន ឬក៏បញ្ជូនសារពីលោក តើអ៊ីចឹងមែនទេ ពេលនុំង?

**ឆ៖** បាទ នីរសារនេះគឺគាត់ជាក្មេងអាយុពីរបីប្អូនដណ្តប់ឆ្នាំហ្នឹង ដូច្នេះគ្នាគ្មានដឹងអីទេ ដឹងថាមានអីយកទៅលើ គាត់កាន់យកទៅ។ តែប៉ុណ្ណឹង គ្មាន-- ហើយនីរសារនេះក៏មិនមែនជារូបខ្ញុំនេះ ជាជ្រើសរើសចាត់តាំងអីដែរ គឺថាគេចាត់តាំងមកអ៊ីចឹង ក្មេងនៅហ្នឹង ហើយក៏នៅជាមួយគ្នាអ៊ីចឹងទៅ។

**ស៖** នីរសារនេះ គឺជាក្មេងដែលមានអាយុ បីប្អូនដណ្តប់ឆ្នាំ តើកម្មវត្ថុនៃលិខិតដែលលោកបញ្ជូនទៅឱ្យនីរសារហ្នឹងជូនទៅ លោកសរសេរដាក់ទៅៗថ្នាក់ណា? ឬក៏ទៅបងណា? តើលោកមានសរសេរអ៊ីចឹងទេ?

[០៩:៤៧:០០]

**ឆ៖** អ្វីដែលខ្ញុំផ្ញើទៅហ្នឹង គឺថាច្រើនតែអ៊ីចេះ ច្រើនតែព្រាង ពង្រាង លិខិតអីមួយឱ្យធ្វើរឿងអីមួយ។ ពង្រាងហ្នឹងធ្វើជាភាសាអង់គ្លេស តែអក្សរអង់គ្លេសខ្ញុំមិនពូកែទេ ខ្ញុំសរសេរត្រូវខ្លះ ខុសខ្លះ ពាក្យណាមិនច្បាស់ ខ្ញុំដាក់រង្វង់ក្រចក ដាក់ពាក្យបារាំងទៅ។ ហើយយកទៅ មានទៅខាងលើទៅ មានគេពូកែអង់គ្លេស គេសរសេរត្រឹមត្រូវទៅ ហើយខ្ញុំដាក់ស្រោមឱ្យនីរសារកាន់ទៅ។ កាន់ទៅ គ្រាន់តែប្រាប់ថាទៅមន្ទីរ ខ្ញុំមិនចាំថាមន្ទីរកប៉ុន្មាន "ក"អីប៉ុន្មានទេមន្ទីរទេដឹងតែលេខទេ។ ហើយឥឡូវ ខ្ញុំមិនចាំលេខហ្នឹងទេ។ ហើយនីរសារហ្នឹង គាត់យកទៅឱ្យមន្ទីរហ្នឹងទៅ។ ហើយត្រង់ខាងណោះ ប្រហែលគេដឹងហើយរឿងនេះត្រូវឱ្យអ្នកនោះ រឿងនោះឱ្យទៅអ្នកនោះ។ អាហ្នឹងខ្ញុំគិតថាអ៊ីចឹង។ ខ្ញុំមិនចាំមន្ទីរណា មន្ទីរលេខអី ខ្ញុំសាមសិបឆ្នាំប្លាយ ខ្ញុំមិនចាំទេរឿងឈ្មោះ លេខមន្ទីរហ្នឹង។ ហើយដឹងតែនីរសារហ្នឹង ប្រាប់ថាមិត្តឯងយកទៅៗ ទៅមន្ទីរលេខប៉ុន្មានហ្នឹងទៅ ហើយគាត់ក៏យកទៅៗ។ ហើយខ្ញុំអត់មានដាក់ថា ជូនបងនេះ ជូនបងនោះ ខ្ញុំអត់មានដាក់ទេ។

[០៩:៤៨:២៣]

**ស៖** បាទ មុននេះបន្តិចលោកបានជម្រាបប្រាប់អង្គសវនាការថា ឌឿន ប្រធានគណៈកម្មាធិការពាណិជ្ជកម្ម។ តើលោកដឹងថាអ្នកណានៅពីលើ ឌឿន ទៀតទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេបាទ។

**ស៖** រវាងឋានៈ ឌឿន និងឋានៈរបស់លោក តើអ្នកណាបញ្ជាអ្នកណាបានលោក?

**ឆ៖** ពីរឿងឋានៈលោក ឌឿន ហើយនិងខ្ញុំ គឺដែលគាត់បញ្ជាខ្ញុំ ពីព្រោះគាត់-- ក្នុងការចាត់តាំងគាត់នៅខាងលើ ហើយខ្ញុំគ្រាន់តែជាដូចថា "អែប" ធនាគារគ្រាន់តែអែប ជួយបច្ចេកទេស ឬពន្យល់ការងារខ្លះទេ ហើយការអីៗទៅលើគាត់។

[០៩:៤៩:៤៨]

**ស៖** ទាក់ទងជាមួយនឹងរចនាសម្ព័ន្ធក្រសួង តើលោកបានដឹងថាអ្នកណាជាប្រធានក្រសួងទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់អ៊ីចេះ អំពីប្រើពាក្យថា ក្រសួង។ យើងសម័យឥឡូវ យើងប្រើថា ក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និយាយពីក្រសួង ប៉ុន្តែពេលនោះដូចជាមិនប្រើពាក្យថា ក្រសួងអ៊ីចឹងទេ ច្រើនថាមានគណៈកម្មាធិការៗ អ៊ំ គណៈកម្មាធិការពាណិជ្ជកម្ម គណៈកម្មាធិការឧស្សាហកម្មអីអ៊ីចឹងទៅ។ ហើយដល់ក្នុងករណីដែលពាក់ព័ន្ធខាងពាណិជ្ជកម្មហ្នឹង គឺថាប្រធានគណៈកម្មាធិការពាណិជ្ជកម្ម។ ហើយដំបូងឡើង ដែលខ្ញុំគេហៅមកភ្នំពេញ ទំនាក់ទំនងធ្វើការហ្នឹង គឺជាមួយមិត្ត ឌឿន ហ្នឹងឯងគាត់ជាប្រធានគណៈកម្មាធិការពាណិជ្ជកម្ម។ ហើយក្រោយមកទៀត ខ្ញុំមិនចាំខែឆ្នាំទេ ក៏មិនដឹងជាមានការដកចេញ គឺផ្លាស់អី ខ្ញុំមិនដឹងទេ ហើយបានដាក់លោក វ៉ាន់ រិទ្ធ ហ្នឹង មកជំនួសគាត់។ វ៉ាន់ រិទ្ធ ហ្នឹង ក៏គាត់ជាសមាជិកគណៈកម្មាធិការពាណិជ្ជកម្មដែរ តែដល់លោក ឌឿន ហ្នឹង គាត់ទៅណាទៅក៏លោក វ៉ាន់ រិទ្ធ ហ្នឹង គាត់ឡើងជំនួស។ បាទ សូមជម្រាបប៉ុណ្ណឹងបាទ។

**ស៖** នៅក្នុងស្ថានភាពដែល ឌឿន ត្រូវបានគេដកចេញមិនដឹងថា គេយកទៅណា វ៉ាន់ រិទ្ធ បានចូលមកជំនួស។ តើខ្ញុំសួរថា គណៈកម្មាធិការនេះ ដែលបានចុះទៅប្រមូលស្រូវផលិតតាមតំបន់ឬទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេបាទ។

**ស៖** តើលោកដែលធ្លាប់បានទទួលរបាយការណ៍ផ្ទាល់ពីតំបន់ ស្ដីពីការផលិតស្រូវឬទេ?

**ឆ៖** បាទ មិនដែលទេបាទ។

**ស៖** ខ្ញុំសូមសួរលោកលម្អិតបន្តិច នៅក្នុងស្ថានភាពដែលលោកជាអគ្គនាយករងធនាគារ តើលោកមានទំនាក់ទំនងធនាគារក្រៅប្រទេសដែរឬទេ?

[០៩:៥៣:១៧]

**ឆ៖** ដំបូងឡើយ ខ្ញុំសូមបញ្ជាក់អ៊ីចេះ គឺថាពិតមែនតែខ្ញុំជានាយករង ប៉ុន្តែខ្ញុំមិនបានចុះហត្ថលេខាទៅលើឯកសារស្អីបន្តិចបន្តួចទេ។ គឺឯកសារអ្វីព្រាងទៅ ទៅឲ្យអគ្គនាយក ដែលខ្ញុំមិនឃើញមុខហ្នឹង កែសម្រួលហើយ គេផ្ញើទៅណាៗទៅ។ ហើយក៏មិនឃើញមានឲ្យសំណៅអីមកខ្ញុំទុកដាក់ដែរមានឯកសារគេហៅថា កាលប្បវត្តិអីៗទុកហ្នឹង ក៏មិនមានទេបាទ។ ហើយខ្ញុំស្មានទៅទេ ថាវាអាចមានផ្ញើទៅនេះទៅនោះ តែគ្រាន់តែខ្ញុំវាគ្មានឯកសារអីមកកត់ត្រានៅក្នុងកន្លែងខ្ញុំ អត់មាន។ នេះខ្ញុំកាន់។

**ស៖** អ៊ីចឹង ខ្ញុំអាចនិយាយបានថា ឯកសារនោះ គឺមាន ក៏ប៉ុន្តែលោកមិនបានចាំ តើមែនទេ?

**ធ៖** ឯកសារនោះ គឺថាខាង អាចខាងអគ្គនាយកនោះ គាត់ធ្វើហើយ គាត់បញ្ជូនទៅ ហើយអត់មានឲ្យមកខ្ញុំវិញដឹងឮអីទេ។ ដូច្នេះ ខ្ញុំថាមិនចាំក៏បាន ព្រោះថាមិនឃើញឯកសារណាមកដៃខ្ញុំផង។ ខ្ញុំ-- ទេអានេះជា ខ្ញុំនិយាយនេះ គ្រាន់តែជាការប៉ាន់ប្រមាណទេ វាអាចគាត់ធ្វើទៅ គេទុកទៅ ហើយមិនឲ្យមកខ្ញុំដឹងទេ។

[០៩:៥៥:០៣]

**ស៖** តើលោកស្គាល់ វន វ៉េត ទេ?

**ធ៖** បាទ ស្គាល់បាទ។

**ស៖** វន វ៉េត គាត់កាន់មុខងារអ្វីដែរបាទ?

**ធ៖** ក្នុងការចាត់តាំងរចនាសម្ព័ន្ធរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យកាលនោះ ខ្ញុំមិនៗ មិនដឹងច្បាស់លាស់ទេ ពីព្រោះគ្មានការផ្សាយអីដូចជាយើងរាល់ថ្ងៃនេះ អ្នកនេះធ្វើនេះ ក្រសួងនេះអីហ្នឹងគ្មានទេ។ តែគ្រាន់ថា តាមការសង្កេតមើលទៅឃើញថា គាត់ដូចជាកាន់ ទទួលខុសត្រូវខាងសេដ្ឋកិច្ច។ ហើយពេលដែលខ្ញុំមកដំបូងហ្នឹង ពីសហករណ៍មក គឺគាត់ហ្នឹងបានប្រាប់ខ្ញុំថា-- គាត់ហៅខ្ញុំបងៗ ព្រោះខ្ញុំបងគាត់ អានេះជា-- ថាមានគណៈប្រតិភូគេមកហ្នឹងគេមានធនាគារគេមក។ ហើយគាត់ថា គេហៅបងឯងមកហ្នឹង គឺថា បងឯងចេះធនាគារ។ ដូច្នេះ ចូលរួមនឹងគណៈប្រតិភូខ្មែរទៅ ដើម្បីខាងភាគីគេនិយាយអីមក យើងមានអ្នកយល់ ហើយចាំមកពន្យល់គ្នីគ្នាឯងទៅ។ ហើយជួបគាត់ម្តងហ្នឹង។

[០៩:៥៦:៥២]

**ស៖** ទន្ទឹមនឹងយើងដឹងប្រតិបត្តិការជាក់ស្តែងរបស់ វន វ៉េត នៅក្នុងក្រសួងសេដ្ឋកិច្ច។ ខ្ញុំសូមសួរលោក ថាតើលោកដឹងរចនាសម្ព័ន្ធនៅក្នុងក្រសួងសេដ្ឋកិច្ចយ៉ាងម៉េចដែរ?

**ធ៖** បាទ ខ្ញុំមិន-- ខ្ញុំមិនដឹងទេបាទ។

**ស៖** ខ្ញុំសូមលោកជួយប្រាប់អង្គសវនាការ អំពីឈ្មោះសម្ងាត់។ ឈ្មោះសម្ងាត់ ហែម នេះលោកដែលឮទេឈ្មោះហ្នឹង?

**ធ៖** បាទ ធ្លាប់ឮបាទ។

**ស៖** ឈ្មោះពេញរបស់គាត់ លោកបានដឹងហើយនៅសព្វថ្ងៃ?

**ធ៖** ឈ្មោះពេញរបស់គាត់គឺលោក ខៀវ សំផន ដឹងតាំងពីយូរមកហើយបាទ។

**ស៖** តើលោកដឹងថា ខៀវ សំផន ដែលមានឈ្មោះសម្ងាត់នៅក្នុងបក្សនេះ គាត់មានតួនាទីអ្វីដែរ

សម័យនោះ?

**ផ៖** ខ្ញុំមិនដឹងទេបាទ។

**ស៖** ខ្ញុំសូមសួរលោក តើអ្នកណាមានសិទ្ធិចុះហត្ថលេខាលើការទិញលក់ទេ នៅសម័យនោះ?

[០៩:៥៩:២២]

**ផ៖** ខ្ញុំមិនដឹងទេបាទ។ ព្រោះអាហ្នឹងពាក់ព័ន្ធនឹងរឿងខាងពាណិជ្ជកម្ម ខាងសេដ្ឋកិច្ច គឺខាងខ្ញុំមិនៗ ដឹងជាស៊ីជម្រៅទេបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចូលមកវគ្គមួយទៀតទាក់ទងជាមួយនឹងខ្លួនលោកផ្ទាល់។ លោកបាននិយាយថា លោក ឌឿន ត្រូវបានបាត់ខ្លួន។ ក្រៅពី ឌឿន តើលោកដឹងថា អ្នកណាទៀតដែលធ្វើការជាមួយលោកនេះបាត់ខ្លួនជាបន្តបន្ទាប់ទេ?

**ផ៖** ខ្ញុំមិនដឹងទេបាទ។ ហើយអ្នកដែលធ្វើការជាមួយខ្ញុំនេះ នៅធនាគារគ្មានអ្នកណាទេ មានតែខ្ញុំ ហើយនិងក្មេងៗម្នាក់ពីរនាក់ហ្នឹង។ ហើយត្រង់អ្នកឯទៀត ដែលជាធ្វើការជាមួយលោក ឌឿន ហ្នឹងខ្ញុំមិនដឹងនរណាទៀត ខ្ញុំមិនបានដឹងនរណាបាត់ទៀត ខ្ញុំអត់បានដឹងដែរ។

**ស៖** តើលោកបានដឹងអំពីការផ្លាស់ប្តូរការងាររបស់មនុស្សមួយចំនួន ដែលធ្វើការនៅក្រសួងនុំងទេ?

**ផ៖** បាទ ខ្ញុំអត់ដឹងទេបាទ។

**ស៖** លោកស្គាល់ គ្រិន ទេ?

[១០:០១:១១]

**ផ៖** ពីដំបូងឡើងមិនដែលស្គាល់គាត់ទេ ដល់ក្រោយមក ខ្ញុំមិនចាំឆ្នាំដូចឆ្នាំណាទេ មានឱកាសទៅកំពង់សោមហ្នឹង ក៏ជួបគាត់ ថាគាត់ហ្នឹងជាប្រធានផែហ្នឹង ក៏ស្គាល់គាត់ពីពេលនោះមក តែខ្ញុំមិនចាំខែឆ្នាំទេបាទ គ្រិន ហ្នឹងបាទ។ ពីដើមមិនដែលស្គាល់ទេបាទ។

**ស៖** គ្រិន នេះលោកដែលឃើញទេសព្វថ្ងៃ ឬក៏បាត់ខ្លួនរហូត?

**ផ៖** សព្វថ្ងៃនេះ ខ្ញុំមិនដឹងដែរ មិន-- គ្មានដំណឹងអី ថាគាត់នៅរស់ ឬអីទៅណា ខ្ញុំមិនដឹងទេបាទ។

**ស៖** លោកបានមានប្រសាសន៍មុននេះបន្តិចថា ឌឿន ជាប្រធាន។ តើបន្ទាប់ពីបាត់ខ្លួនរបស់ ឌឿន លោកដឹងថា អ្នកណាមកជំនួសតំណែង ឌឿន ទេ?

**ឆ៖** បាទ ន៎ក្នុងគណៈកម្មាធិការពាណិជ្ជកម្មហ្នឹង ពីមុនមានលោក ឌឿន ហ្នឹង ហើយដល់គាត់បាត់ទៅ គឺលោក វ៉ាន់ រិទ្ធ ហ្នឹងឡើងជំនួស។ ខ្ញុំដឹងប៉ុណ្ណឹងបាទ។ នៅក្នុងនាទីជាគណៈកម្មាធិការពាណិជ្ជកម្មហ្នឹង គឺលោក វ៉ាន់ រិទ្ធ ហ្នឹងគាត់ឡើងកាន់ជំនួស។

[១០:០២:៥២]

**ស៖** ចុះ វន វ៉េត ដូចលោកដឹងថាបាត់ខ្លួននៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ។ មិនចាំទេបាទ។

**ស៖** មិនចាំពេលណា ឬក៏មិនចាំថាគាត់បាត់ខ្លួន?

**ឆ៖** គឺមិនដឹងថា បាត់ខ្លួន ពីព្រោះថាក្នុងការ គឺខ្ញុំជួបគាត់ម្តងដំបូង ដល់ក្រោយមកវាគ្មាន គ្មានរឿងអីដែលត្រូវទំនាក់ទំនងគាត់ ហើយដូច្នេះដូចថា គាត់ទៅណាពេលណា បាត់ពេលណា ខ្ញុំក៏មិនដឹងដែរ។

**ស៖** នៅក្នុងអារម្មណ៍របស់លោកដែលធ្វើការ ឌឿន បាត់ខ្លួន ឬក៏យ៉ាងម៉េចនេះ តើលោកមានការភ័យខ្លាច ឬក៏លោកសប្បាយចិត្តនឹងធ្វើការក្នុងសម័យនោះ?

**ឆ៖** ពេលនោះ ពេលដែលមិនឃើញលោក ឌឿន មកខ្ញុំក៏មិនបានទៅគិត ទៅដល់ថាយ៉ាងម៉េចយ៉ាងម៉េចទេ គឺថាគេផ្លាស់ប្តូរជាធម្មតាអ៊ីចឹងទៅ ហើយក៏ចំពោះខ្ញុំនោះ ក៏មិនទាន់គិតថា មានការភ័យខ្លាចអីដែរ។ ខ្ញុំក៏ធ្វើការជាមួយធម្មតាទៅតាមការដឹងខ្លះខាងផ្នែកធនាគារអ៊ីចឹងទៅ អ៊ីចឹងទៅហើយថាសប្បាយ មិនសប្បាយ អាហ្នឹងការងារមកធ្វើទៅ ពេលនុ៎ងគឺយើងសប្បាយមិនសប្បាយ ក៏ត្រូវតែធ្វើឱ្យវាអស់សមត្ថភាពរបស់យើងដែរ។

[១០:០៥:០១]

**ស៖** យើងខ្លាចគេទេធ្វើពេលនុ៎ង ឬមួយយើងធ្វើដោយចំណេះវិជ្ជាយើងដែលមាន?

**ឆ៖** បាទ គឺថាធ្វើទៅតាមចំណេះវិជ្ជាដែលខ្ញុំមាន ហើយក៏មានហៅថា ខ្លាចថ្នាក់លើដែរ។

**លោក វ៉េង ហ៊ាត់៖**

លោកប្រធាន សំណួរខ្ញុំបានបញ្ចប់ត្រឹមនេះ ហើយការងារសំណួរបន្តបន្ទាប់ទៀតទាក់ទងនឹងអង្គហេតុជាក់លាក់ និងការបង្ហាញភស្តុតាងគឺសហការីរបស់ខ្ញុំលោក ថារីក នឹងសួរសាក្សីបន្តទៀត។ ខ្ញុំសូមអរគុណលោកសាក្សីដែលបានជួយឆ្លើយតាំងពីថ្ងៃម្សិលមិញរហូតដល់ថ្ងៃនេះ។ ហើយសូមលោកជួយឆ្លើយ និងជួយបកស្រាយការងារមួយចំនួនដែលសហការីរបស់ខ្ញុំនឹងសួរលោកបន្តទៀត។

សូមអរគុណលោកប្រធាន និងក្រុមប្រឹក្សាទាំងអស់។

[១០:០៦:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងមេធាវី ហើយសូមជម្រាបសួរលោកសាក្សី សគីម ល្មុត ផងដែរ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** អ្វីដែលខ្ញុំចង់សួរលោកនោះ គឺត្រឡប់ទៅរកចំណុចមួយចំនួនដែលលោកបានឆ្លើយទៅនឹងសំណួររបស់សហសេវិករបស់ខ្ញុំ ហើយបន្ទាប់ទៀត ខ្ញុំនឹងសួរផ្នែកផ្សេងទៀត ហើយខ្ញុំសួរ-- សូមអរគុណដែលលោកបានវត្តមាននៅទីនេះ។ ហើយខ្ញុំនឹងសួរសំណួរមួយចំនួនដែលកើតឡើងក្នុងអតីតកាល ហើយនិងអរគុណផងដែរ ដែលលោកបានប្រឹងប្រែងក្នុងការឆ្លើយ។ ពីម្សិលមិញលោកបាននិយាយថា លោកបានចូលបដិវត្តន៍ បាទ នៅក្នុង-- គឺថាកាលពីលោកនៅវ័យក្មេង។ តើលោកអាចជម្រាបតុលាការបន្ថែមទៀតបានដែរទេ? ថាតើៗនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ឬក៏ទសវត្សរ៍ឆ្នាំ១៩៦០ ឬក៏ក្រោយពីហ្នឹងបាទ?

[១០:០៨:១៩]

**លោក សគីម ល្មុត៖**

**ឆ៖** តាមខ្ញុំចាំប្រហែលជាទសវត្សរ៍៥០ហ្នឹងហើយបាទ។ ៥០, ៦០ ហ្នឹងវា ៥០អីហ្នឹងបាទ។ សូមទោស សូមបន្ថែមថា ពេលនោះមិនទាន់មានជាការចាត់តាំងរចនាសម្ព័ន្ធជាបក្សកុម្មុយនីស្ត បក្សអីទេ គឺគ្មានទេ ពេលនុ៎ង។

**ស៖** ខ្ញុំគិតថា លោកបានជម្រាបទៅសហសេវិកខ្ញុំថា នៅក្នុងសម័យកាលនោះលោកបានជួបលោក វន វ៉េត រួចហើយ តើត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** សម័យនោះ ខ្ញុំមិនដឹងជាជួបអ្នកណាខ្លះទេ ខ្ញុំមិនចាំទេបាទ តាំងពី៥០, ៦០ នោះ ខ្ញុំមិនចាំថាជួបអ្នកណាខ្លះទេបាទ។

[១០:០៩:៣៩]

**សៈ** តើលោកនៅនឹកឃើញដែរទេ ថាលោកនៅស្គាល់ថា នៅស្គាល់ វន វ៉េត មុនឆ្នាំ១៩៧៥ នោះ?

**អ្នកបកប្រែ៖**

សូមកែតម្រូវ៖ តើលោកបានស្គាល់ វ៉ាន់ រិទ្ធ កាលពីមុនឆ្នាំ១៩៧៥ ដែរឬទេ? (*ពីអ្នកបកប្រែ*)។

**លោក សគឹម ល្អុត៖**

**ឆៈ** វ៉ាន់ រិទ្ធ ហ្នឹងស្គាល់បាទ មុន៧៥ ហ្នឹងស្គាល់បាទ។

[១០:១០:២២]

**សៈ** តើគាត់បានចូលរួមក្នុងកិច្ចប្រជុំ ដែលលោកបានរៀបរាប់កាលពីម្សិលមិញ និងថ្ងៃនេះទេ ដែលក្នុងកិច្ចប្រជុំនោះគឺថា បាននិយាយអំពីមូលហេតុនៃការធ្វើបដិវត្តន៍នោះ គេពិភាក្សាក្នុងអង្គប្រជុំនោះ?

**ឆៈ** ក្នុងការប្រជុំផ្សេងៗនោះគឺថា ជួនប្រជុំជាមួយអ្នកនេះ ជួនប្រជុំជាមួយអ្នកនោះឲ្យនិយាយតែអំពីរឿងរួបរួមទេ ហើយខ្ញុំមិនចាំថា វ៉ាន់ រិទ្ធ ហ្នឹងបានចូលជាមួយ ឬមិនចូលទេ ព្រោះថា សាមសែសិបឆ្នាំមកហើយ ខ្ញុំជួបវាច្រើនគ្នាណាស់ ខ្ញុំមិនចាំ ប៉ុន្តែជាបុគ្គលស្គាល់គ្នាជាមួយគាត់បាទ។

**សៈ** លោកបាននិយាយប្រាប់យើងពីម្សិលមិញថា នៅក្នុងដំណាក់កាលមួយ វ៉ាន់ រិទ្ធ គឺថា ត្រូវបានបង្ខំឲ្យចេញទៅខាងក្រៅ ចេញពីប្រទេស បាទ គឺពួកខាង លន់ នល់ គឺតាមចាប់គាត់។ តើមានមនុស្សណាផ្សេង ដែលលោកបានជួបនោះជាសមាជិករបស់ចលនានោះទេ? តើសមាជិកណាមួយត្រូវបានបង្ខំខ្លួនចេញក្នុងសម័យជាមួយ វ៉ាន់ រិទ្ធ ហ្នឹងដែរទេ?

**ឆៈ** ខ្ញុំមិនដឹងទេបាទ។

**សៈ** តើត្រូវដែរឬទេ បើនិយាយថា ក្រៅពី វ៉ាន់ រិទ្ធ ដែលបានគេចខ្លួននោះគឺមានការប្រជុំនៅតែមានបន្តជាមួយអ្នកផ្សេងៗទៀត ដែលលោកក៏នៅក្នុងស្រុក ហើយនៅបន្តការប្រជុំទៀត។ តើត្រូវទេ?

**ឆៈ** បាទ នៅមានប្រជុំដែរបាទ ប៉ុន្តែសូមបញ្ជាក់ថា វ៉ាន់ រិទ្ធ មិនមែនទៅក្រៅស្រុកខ្មែរ គឺគ្រាន់តែគាត់ចេញទៅតំបន់ ដែលខ្មែរក្រហមកាន់កាប់ មិនមែនទៅបរទេសទេបាទ។ គាត់ចេញទៅនុ៎ង។

**សៈ** សូមអរគុណ ដែលលោកបានបំភ្លឺបន្ថែម។ តើលោកអាចទាក់ទងជាមួយគាត់ទេ នៅពេលដែលគាត់រត់ចេញពីភ្នំពេញទៅនោះ?

**ឆ៖** អត់ទេបាទ។

**ស៖** ហើយផ្តោតទៅលើសម័យកាលឆ្នាំ១៩៦០ ឬក៏ដើមឆ្នាំហ្នឹង តើលោកស្គាល់លោក ខៀវ សំផន ដែរឬទេ?

**ឆ៖** បាទស្គាល់បាទ។

[១០:១៣:៤៣]

**ស៖** តើគាត់មានមុខតំណែងជាអ្វីដែរកាលនោះ?

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអា្ជា! អ៎ តំណាង-- លោកមេធាវីការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ ហើយសូមអភ័យទោស សហព្រះរាជអាជ្ញា។ ខ្ញុំជំទាស់ ប៉ុន្តែកម្រងសំណួរដែលលោកសួរនេះ ទសវត្សរ៍ឆ្នាំ៦០ ដែលថា ទាក់ទងទៅអ្នកគេចខ្លួនគឺថា នាំឲ្យយើងមានការព្រួយបារម្ភមួយគឺថា ឥឡូវនេះ យើងនិយាយនៅក្នុងផ្នែកនេះ ក្នុងសម័យកាលនេះគឺជាក់ស្តែង គឺវានៅក្រៅអាជ្ញាយុកាលពេលវេលា គឺមិនសមស្រប។ ប៉ុន្តែតើសំណួរបែបនេះគឺថា អាចនឹងទាក់ទងទៅនឹងព្រះវររាជបិតា ដែលថាគាត់ជាប្រមុខរដ្ឋ ហើយអ្វីដែលជាការងារសម័យនោះគឺ វាបង្ហាញពីសម័យកាលប្រវត្តិសាស្ត្រងងឹងមួយនៃកម្ពុជា។ ដូច្នេះគឺថា យើងសូមបញ្ជាក់ថា សូមឲ្យកោះយាងព្រះមហាក្សត្រ ដើម្បីមកបំភ្លឺក្នុងផ្នែកនេះផង បើសួរពីសំណួរបែបនេះ។ បើមិនដូច្នោះទេ គឺថាសាក្សីនៅក្នុងសម័យកាលនោះ រួមទាំងព្រះមហាក្សត្រ-- អតីតព្រះមហាក្សត្រផង គឺថាអាចនឹងមកបំភ្លឺនៅក្នុងវគ្គ រឿងក្តី០០២/១ នេះផងដែរ។ ហើយខ្ញុំមិនបញ្ជាក់ថាគួរតែកោះយាងព្រះអង្គនោះទេ ក៏ប៉ុន្តែបើយើងចង់សួរថាហេតុអីបានជាមនុស្សត្រូវគេចខ្លួនពេលនោះ នោះគឺយើងត្រូវមានសាក្សីបែបនោះបាទ។

[១០:១៥:២៤]

**ប្រធានអង្គជំនុំ៖**

បានហើយ! ប៉ុណ្ណឹងបានហើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា បន្តការតាំងសំណួរតទៅទៀតចុះ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** អ៊ីចឹងខ្ញុំត្រឡប់មកសំណួរមកលោកសាក្សី សគឹម ល្មុត វិញ។ ខ្ញុំសួរថាតើលោកស្គាល់លោក ខៀវ សំផន ដែរឬទេ? ហើយគាត់មានតំណែងអ្វីទេនៅក្នុងសម័យកាលនោះ ដែលខ្ញុំសួរខាងដើមអំមិញនេះ?

**លោក សគឹម ល្មុត៖**

**ឆ៖** ខ្ញុំស្គាល់គាត់ ហើយជាតំណែងនៅក្នុងជួរបដិវត្តន៍ហ្នឹង ខ្ញុំមិនដឹងច្បាស់ដែរទេ តែមានពេលដែលក្នុងសម័យព្រះករុណា គាត់ធ្វើជា ធ្លាប់ធ្វើជាតំណាងរាស្ត្រ ធ្លាប់ធ្វើជារដ្ឋមន្ត្រី ដឹងប៉ុណ្ណឹងបាទ។ តែបើក្នុងជួរចាត់តាំងបដិវត្តន៍នោះ ខ្ញុំមិនដឹងថាគាត់មានមុខតំណែងអីៗ ខ្ញុំមិនដឹងទេបាទ។ អាហ្នឹងមិនដឹងតែម្តងបាទ។

**ស៖** តើលោកបានជួបគាត់ទេ គឺក្នុងដើមទសវត្សរ៍ឆ្នាំ១៩៦០ បើជួបៗញឹកញាប់ប៉ុនណាបាទ?

**ឆ៖** មិនសូវជា ដូចជាគ្មានការអីជួបគាត់ផង បើពេលកាលដែលគាត់នៅក្នុងស្រុកមិនទាន់ចេញទៅក្រៅ ទៅតំបន់រំដោះហ្នឹងក៏ជាចៃដន្យអីក៏ជួបគ្នាទៅ ប៉ុន្តែថាជាប្រជុំអីជាមួយគាត់ ខ្ញុំមិនដែលចូលប្រជុំអីជាមួយគាត់ទេបាទ។

**ស៖** សូមអរគុណ លោកបានប្រាប់យើងថា លោកមិនច្បាស់ទេថាតើគាត់មានតួនាទី ឬក៏មុខតំណែងអីទេនៅក្នុងសម័យកាលនោះ។ ប៉ុន្តែតាមអ្វីដែលលោកបានដឹង តើគាត់ពាក់ព័ន្ធជាមួយចលនាបដិវត្តន៍ទេ កាលពីដើមទសវត្សរ៍ឆ្នាំ១៩៦០នោះ?

**ឆ៖** ខ្ញុំមិនប៊ានថាទេបាទ មិនអាចថាបានទេ ខ្ញុំមិនច្បាស់ទេបាទ។

**ស៖** តើលោកស្គាល់លោក អៀង សារី ទេក្នុងសម័យកាលនោះ?

**ឆ៖** បាទស្គាល់បាទ។

[១០:១៨:៣៣]

**ស៖** តើគាត់បានចូលពាក់ព័ន្ធក្នុងការងារចលនាបដិវត្តន៍នោះដែរឬទេ នៅក្នុងសម័យកាលនោះបាទ?

**ឆ៖** ខ្ញុំៗមិនដឹងទេបាទ។

**ស៖** ខ្ញុំចង់បញ្ចប់ប្រធានបទនេះក្នុងពេលនេះ ហើយក្នុងសម័យកាលនោះ តើលោកស្គាល់លោក នួន ជា ដែរទេ?

**ឆ៖** បាទអត់ស្គាល់ទេបាទ។

**ស៖** សូមអរគុណ។ កាលម្សិលមិញលោកបានប្រាប់សហព្រះរាជអាជ្ញាថា លោកបានផ្តល់ការឧបត្ថម្ភខ្លះទៅដល់ចលនានោះក្នុងសម័យកាលនោះ តើលោកអាចជម្រាបតុលាការថាលោកអាចផ្តល់ការផ្តល់ការឧបត្ថម្ភអ្វីខ្លះទៅដល់ចលនានោះបាទ ជាលម្អិតបន្តិចបានទេ?

[១០:១៩:៤៧]

**ឆ៖** គឺគ្មានអ្វីច្រើនពីប្រាក់កាសបន្តិចបន្តួចទេ ហើយខ្ញុំក៏មិនចាំថាប៉ុន្មានៗដែរ ហើយខ្ញុំគិតថាលុយហ្នឹងមិនជាច្រើនអីទេ ពីព្រោះខ្ញុំធ្វើការរាជការហ្នឹងក៏វាប្រាក់ខែគ្រាន់តែចិញ្ចឹមជីវិតហ្នឹង ហើយវាតិចតួចទៅអ៊ីចឹង អត់មានអីជាធំដុំទេបាទ គ្មានលុយកាក់អីច្រើនទេបាទ។ ក្រៅពីនោះអត់មានអីទៀតទេ។

**ស៖** តើលោកផ្តល់លុយកាក់បន្តិចបន្តួចហ្នឹងផ្តល់ដោយវិធីណា? ផ្តល់ទៅឲ្យអ្នកណាបាទ?

**ឆ៖** គឺថាពេលប្រជុំៗ ដូចថាខាងថ្នាក់ក្រោមហ្នឹង គឺថាយើងឲ្យទៅនរណាដែលប្រធានអង្គប្រជុំហ្នឹង ដែលប្រជុំម្តងគ្នាពីរបីបួននាក់ហ្នឹង ហើយឲ្យទៅគេទៅ។ ហើយគេថាយកទៅជួយក៏ដល់ណាមិនដល់ណាខ្ញុំក៏មិនដឹងដែរទេ គ្រាន់តែថាជួយបន្តិចបន្តួចទៅ។ យើងទុកចិត្តគេ ហើយថាយើងឲ្យទៅ។ បាទ លុយបន្តិចបន្តួចហ្នឹង។

**ស៖** តើលោកបានផ្តល់ការឧបត្ថម្ភអ្វីផ្សេងទៀតក្រៅពីហ្នឹងទេ ដែលលោកជាអ្នកជំនាញខាងធនាគារ ឬហិរញ្ញវត្ថុ តើមានការឧបត្ថម្ភក្រៅពីហ្នឹងដែរទេ?

**ឆ៖** បាទ អត់មានទេបាទ។

[១០:២១:៤៦]

**ស៖** ខ្ញុំនឹងបញ្ចប់ប្រធានបទនេះភ្លាមៗនេះ លោក សគីម ល្មុត ហើយខ្ញុំចង់សួរលើឯកសារមួយចំនួនដែលបញ្ជាក់ពី-- ដែលឯកសារដែលមានឈ្មោះលោក ថាតើការរៀបរាប់នៅលើឯកសារនោះត្រឹមត្រូវដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវទំព័រ E3/9 ជាឯកសាររបស់ សៀវភៅ

ហ្វីលីព ស្បួត ជាសេចក្ដីយោងខ្លីមួយទៅរកលោកសាក្សីរូបនេះ។ សូមអនុញ្ញាតអាន ហើយនិងបង្ហាញទំព័រនេះជូនលោកសាក្សី ដើម្បីឲ្យលោកសាក្សីគាត់អាចបំភ្លឺអង្គហេតុនេះជូនតុលាការបាទ។

**ប្រធានអង្គជំនុំ៖**

ទំព័រអីទៅ? ERN ប៉ុន្មាន? ខ្មែរប៉ុន្មាន? អង់គ្លេសប៉ុន្មាន? បារាំងប៉ុន្មានទៅ? ដើម្បីឲ្យភាគីពាក់ព័ន្ធហ្នឹង គាត់បានក្ដាប់បាននូវទំព័រ ដែលលោកមានបំណងក្នុងការបង្ហាញ និយាយយោងទៅដល់ក្នុងការសួរដេញដោលនេះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ERN ឯកសារនេះនោះគឺជាអកុសលនៅពេលនេះគឺមានតែជាភាសាអង់គ្លេស ជាភាសបារាំងនោះទេ ហើយយើងបានសូមស្នើសុំឲ្យមានការបកប្រែទៅជាភាសាខ្មែរ ប៉ុន្តែមិនទាន់បកចប់។ បាទ ERN គឺ 00396469 ជាភាសាបារាំង ERN 00639792។ ផ្នែកនោះគឺយោងដោយសង្ខេបទេ ហើយខ្ញុំអាចអាន អ្នកបកប្រែនឹងបកបាន។ អ៊ីចឹងសូមអនុញ្ញាតបង្ហាញផ្នែកនេះនៅលើអេក្រង់ផងដែរ លោកប្រធានបាទ។

[១០:២៣:៥០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី ល្អុត តើលោកអាចអានអត្ថបទលើអេក្រង់បានទេ ឬក៏លោកត្រូវការឯកសារលើក្រដាស?

**លោក សគីម ល្អុត៖**

**ឆ៖** គឺរឿងនេះមិនពិតទេបាទ មិនពិតទាល់តែសោះ ខ្ញុំអត់មានទេបាទ ខ្ញុំមិនទទួលស្គាល់ទេបាទ។

**ស៖** មិនបញ្ហាទេ លោកសាក្សី ហើយខ្ញុំអាន ដើម្បីកត់ត្រាផ្នែកនេះនិយាយហើយថា "អ្នកធនាគារិក សគីម ល្អុត គឺបម្រើការជារតនាគារជាអ្នក-- បាទ ហេរញ្ញិករបស់ចលនានោះ"។ ហើយបាទ

បើសិនជាលោកមិនមានយោបល់អ្វីបន្ថែមទេ យើងនឹងបន្តទៅមុខទៀតបាទ។

[១០:២៥:០៦]

**ឆៈ** ខ្ញុំថា នេះគឺជាការគិតស្មានរបស់អ្នកនិពន្ធនេះទេ។ ខ្ញុំមិនដែលធ្វើជា ហិរញ្ញិកសម្ងាត់អីឯណាឲ្យចលនាខ្មែរក្រហម គឺគ្មានៗដាច់ខាត ក្រៅពីលុយកាក់បន្តិចបន្តួចឲ្យហ្នឹង។ អានេះ គឺជាខ្ញុំជាការសន្និដ្ឋាន ដោយគ្មានភស្តុតាងរបស់អ្នកសរសេរ អ្នកនិពន្ធហ្នឹង។

**សៈ** សូមអរគុណបាទ។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចូលទៅប្រធានដែលបទនិយាយពី ចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយសូមឲ្យលោកសាក្សីជួយបំភ្លឺជូនយើងខ្ញុំ និងតុលាការអំពីបញ្ហាមួយចំនួន។ លោកបានជម្រាបតុលាការថា គេប្រាប់ឲ្យលោកចាកចេញពីភ្នំពេញនៅពេលល្ងាចមួយ នៅថ្ងៃនោះ គឺថ្ងៃ១៧ មេសា ៧៥ ហើយគេប្រាប់លោកថា លោកអាចត្រឡប់មកវិញ ក្នុងរយៈពេលតែពីរបីថ្ងៃប៉ុណ្ណោះ។ តើលោកបានចាកចេញជាមួយគ្រួសារទាំងមូលទេ ថ្ងៃនោះ?

[១០:២៦:៤០]

**ឆៈ** បាទ ខ្ញុំបានចាកចេញពីជាមួយគ្រួសារទាំងមូល ទាំងអស់គ្នាតែម្តង ទាំងក្មេង ទាំងចាស់អីទៅទាំងអស់។

**សៈ** ចុះអ្នកជិតខាងរបស់លោក ហើយនិងអ្នកដែលនៅក្នុងមណ្ឌល ឬក៏ទីកន្លែងដែលលោករស់នៅ គេទៅទាំងអស់ដែរឬទេ?

**ឆៈ** តាមមើលទៅ ដូចជាទៅ ប៉ុន្តែខ្ញុំមិនបាន-- យើងចេញទៅ មិនបានផ្ទៀងថា អ្នកណានៅនរណាមិននៅ ខ្ញុំមិនដឹងទេ។ តែថាមើលទៅ ត្រូវតែទៅហើយ។ តែបើដល់ខ្ញុំចេញផុតទៅអ៊ីចឹងទៅ ខ្ញុំមិនដឹងថាផ្ទះជិតខាងនេះ អ្នកណាទៅ មិនទៅ អាហ្នឹងខ្ញុំមិនអាចថាបានទេបាទ។ គេដើរប្រាប់គ្រប់តែផ្ទះ។

**សៈ** ខ្ញុំគិតថា លោកបានបញ្ជាក់ថា លោកបានចេញពីភ្នំពេញនៅតាមផ្លូវជាតិលេខ១ តើអ៊ីចឹងដែរឬទេ? គឺតាមផ្លូវមន្ទីរវង្ស ហើយបន្តពីនុំងទៅទៀត តើលោកអាចរៀបរាប់បានដែរឬទេ? ជូនតុលាការជ្រាប ថាតើលោកបានឃើញអ្វីខ្លះ ក្នុងដំណើររបស់លោកតាមផ្លូវជាតិលេខ១នេះ?

[១០:២៨:១១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ឆ្លើយ! ចាំស្តាប់ការជំទាស់របស់អង្គជំនុំជម្រះស្តាប់-- អ៎ សម្រេចលើការជំទាស់

របស់មេធាវីការពារក្តីសិន។ សូមអញ្ជើញលោកមេធាវីការពារក្តី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមអភ័យទោសដែលខ្ញុំកាត់នេះ គឺថានេះជាផ្នែកនេះ យើងបាន-- នេះហើយជាបញ្ហា បើសិនជាមេធាវីជាតិ ឬក៏សហព្រះរាជអាជ្ញាអន្តរជាតិបាននិយាយ-- អ៎ ជាតិបាននិយាយហើយ គឺបន្ទាប់មកគឺលើកឡើងម្តងទៀត ហើយត្រឡប់មកដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ អ៊ីចឹង គឺថាធ្វើឲ្យការងារនេះ ត្រួត ហើយប្រើពេល។ ហើយផ្នែកនេះ ហើយសហព្រះរាជអាជ្ញាជាតិលោកបានសួរ ហើយនិងឆ្លើយរួចហើយ។ ដូច្នេះ ប្រធានបទនេះ ត្រូវបានដោះស្រាយរួចហើយ។

[១០:២៩:០១]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកអាចឲ្យលទ្ធផលនៃការជំទាស់របស់លោកខ្លីៗនូវមូលហេតុនៃការបង្ហាញបានទេ? យើងឃើញថាលោកចេះតែថ្លែងការណ៍ ការចំណាយពេលវេលា លោកគិតថាពេលវេលាដ៏មានតម្លៃណាស់ ហើយភាគីផ្សេងទៀត ដែលពាក់ព័ន្ធនឹងបញ្ហានេះ មិនគួរចំណាយពេលវេលាមានតម្លៃនៅក្នុងការដេញដោលនេះទេ។ ប៉ុន្តែផ្ទុយទៅវិញ លោកលើកធ្វើសេចក្តីថ្លែងការណ៍រាល់លើក គឺអូសបន្លាយ-- អូសៗវែងអន្លាយនូវសេចក្តីអត្ថាធិប្បាយរបស់ខ្លួនម្តងហើយម្តងទៀត។ លោកជំទាស់លើបញ្ហាអ្វីជាក់ច្បាស់ ជាសំណួរច្រំដែល? សំណួរនាំមុខ? សំណួរឧបមាណវិធី ឬក៏សំណួរក្រៅអង្គហេតុ ឬក៏យ៉ាងម៉េច? ដើម្បីឲ្យអង្គជំនុំជម្រះហ្នឹងមានការពិចារណា និងសម្រេចជាក់ច្បាស់ភ្លាមៗតែម្តង។ យើងបានជម្រាបលោកហើយ។ តើលោកជំទាស់អ្វីអំពីអាបញ្ហាហ្នឹង? ឥឡូវ ការតាំងសំណួរនេះ ជំទាស់យ៉ាងណាម៉េច ឥឡូវហ្នឹង? ជាសំណួរច្រំដែល ឬក៏យ៉ាងម៉េច?

[១០:៣០:០៦]

**លោក ម៉ៃខល កាណាវាស៖**

មិនមែនត្រឹមតែសំណួរច្រំដែលនោះទេ។ ប៉ុន្តែអង្គជំនុំជម្រះពិនិត្យឃើញថា ទំនងជាអនុញ្ញាតឲ្យមានសំណួរដដែលនេះ អ៊ីចឹងហើយ ដូច្នេះហើយបានពន្យល់ពីបរិបទនៃការជំទាស់។ ប៉ុន្តែតាមវិធីដែលអង្គជំនុំជម្រះសម្រេចហ្នឹងគឺថា ៗអ៊ីចឹងគឺជាចំណុចមួយដែលខ្ញុំត្រូវបង្ហាញអំពីមូលហេតុ អំពីសំខាន់ បើសិនមិនដូច្នោះទេ គឺថាខ្ញុំអាចនឹងប្តឹងឧទ្ធរណ៍ បើសិនជាមានបញ្ហានៅក្នុងចំណុចនេះបាទ។

**ប្រធានអង្គជំនុំ៖**

លោកមានអ្វីតទេ? តតបទៅលើអ្វីដែលមេធាវីការពារក្ដីជំទាស់អម្បាញ់មិញទេ? ដើម្បីយើងសម្រេចអំពីបញ្ហានេះ រឿងសិទ្ធិជំទាស់តវ៉ាប្ដឹងឧទ្ធរណ៍របស់ភាគី គឺមានសេរីភាពពេញបរិបូរចែងនៅក្នុងវិធាន និងបណ្ដានីតិវិធីទាំងឡាយ ដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកប្រើប្រាស់ និងអនុវត្តនៅទីនេះ មិនមានកំហិតសិទ្ធិករណីណាមួយឡើយ។

[១០:៣១:៣៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ យើងមិនយល់ស្របទៅនឹងការជំទាស់របស់មេធាវីការពារនោះទេ ហើយអ្វីដែលសួរដោយសហសេរីកជាតិនោះគឺថា គឺសម័យកាលមុនឆ្នាំ១៩៧៥ ទេ ហើយខ្ញុំសួរពេលនេះ គឺថាចាប់ពីឆ្នាំ១៩៧៥ តទៅមុខ គឺនិយាយអំពីការជម្លៀស ដើម្បីកត់ត្រានោះ គឺអ្វីៗដែលគាត់និយាយថា គាត់ឃើញមនុស្សដើរចេញនោះគឺថា គាត់បានរៀបរាប់។ អ៊ីចឹងហើយ គឺខ្ញុំចង់សួរសំណួរតាមដានបន្ថែមទៀត ដើម្បីឲ្យសាក្សីគាត់បង្ហាញបន្ថែមទៀតថាតើ រូបភាពទាំងស្រុងដូចម្ដេច? បើសិនជាមេធាវីគាត់ជំទាស់ គឺធ្វើឲ្យយើងមានការលំបាកក្នុងការបង្ហាញអំពីទិដ្ឋភាព ពីភស្តុតាងសក្ខីកម្មរបស់សាក្សី ដែលគាត់បានចាំនេះ។ សូមជម្រាបបាទ។

[១០:៣២:២៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៣:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចលើការជំទាស់របស់មេធាវី ម៉ៃខល កាណាវាស មេធាវីការពារក្ដីលោក អៀង សារី ដែលបានជំទាស់ទៅលើសំណួរ តាំងសំណួរដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ គ្មានប្រសិទ្ធភាព។ តំណាងសហព្រះរាជអាជ្ញាអាចបន្តការតាំងសំណួរដេញដោលចំពោះសាក្សីនេះបាន ចំពោះអង្គហេតុអម្បាញ់មិញនេះ។ ប៉ុន្តែអង្គជំនុំជម្រះសូមជម្រាបផងដែរថា អង្គហេតុអម្បាញ់មិញនេះ គឺតំណាងសហព្រះរាជអាជ្ញាជាតិ បានតាំងសំណួរហើយ គ្រាន់តែគាត់ទើបសួរត្រួសៗ គាត់មិនបានសួរឲ្យបានស៊ីជម្រៅទេ។

[១០:៣៣:៥៥]

អ៊ីចឹងបញ្ហាមានពីរ។ ទីមួយ នៅពេលដែលលោកតាំងសំណួរនេះ សូមលោក-- ដែលសំណួរ ៗ បន្ថែមទៅលើអង្គហេតុដែលលោកបានបែងចែកឲ្យទៅតំណាងសហព្រះរាជអាជ្ញាជាតិ បានតាំងសួររួច ហើយ នេះគឺសួរខ្លីៗ ហើយចៀសវាងឲ្យផុតនូវការសំណួរច្រំដែល។ បញ្ហាទីពីរ អង្គជំនុំជម្រះសូមរំឭក ភាគីពាក់ព័ន្ធថា ប្រសិនបើភាគីបានធ្វើការបែងចែកនូវអង្គហេតុគ្នាក្នុងការដេញដោលទៅតាមលំដាប់នៃ អង្គហេតុ ឬក៏ផ្លាស់គ្នានៃអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយ គប្បីធ្វើការឲ្យបានដាក់ច្បាស់ ដាច់ដោយឡែកពីគ្នា។ ប្រសិនបើការសុំបំពេញបន្ថែម គប្បីឲ្យមានការតិចតួចបំពេញបន្ថែមនូវការតាំង សំណួរទាំងឡាយដែលអង្គហេតុបានបែងចែកគ្នា។ នេះក៏ជាដំណើរការមួយ ធ្វើឲ្យកិច្ចដំណើរការ ពិភាក្សាដេញដោលឆាប់រហ័ស និងមានប្រសិទ្ធភាពដែរ។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

[១០:៣៥:០០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ត្រឡប់ចូលមកប្រធានវិញនេះដដែល លោក សគីម ល្មុត គឺថាលោកបានឃើញប្រជាជន ជាច្រើនធ្វើដំណើរដោយថ្មើរជើង។ នៅក្នុងពេលដែលធ្វើដំណើរចាកចេញនេះ តើលោកបានឃើញកង ទ័ពខ្មែរក្រហមតាំងពីថ្ងៃដំបូងនោះដែរឬទេ?

**លោក សគីម ល្មុត៖**

**ឆ៖** បាទ ពេលដែលចាកចេញនោះ អ្នកដែលចេញទៅហ្នឹង គឺមានមធ្យោបាយអីយកទៅ មាន ឡាន មានម៉ូតូ មានអីក៏ទៅៗ។ ទៅនោះ វាណែនណាន់តាន់តាប់ តាមផ្លូវ ដូចខ្ញុំបានជម្រាបពីលើមុន ហើយអ៊ីចឹង ហើយមានឃើញកងទ័ព គេយាមកាមតាមផ្លូវហូរហែអ៊ីចឹង អ៊ីចឹងទៅ។ ហើយត្រង់ ព្រឹត្តិការណ៍អីផ្សេងទៀត ខ្ញុំដូចពិបាកថាដែរ ខ្ញុំមិនដឹងជាលោកចង់សួរថា មានព្រឹត្តិការណ៍អី? សូមលើក ឧទាហរណ៍ឲ្យខ្ញុំមួយមើល៍ ខ្ញុំឃើញគេទៅណែនណាន់តាន់តាប់ ទាំងខ្ញុំ ទាំងគេ វាគ្មានទៅគិតអីទេ វាចង្អៀត ខ្ញុំជារួម វាអ៊ីចឹង។ តែឲ្យឃើញអីដោយឡែក វាមិនឃើញអីដោយឡែក មិនទាន់ ពេលដែល ចេញទៅហ្នឹង។ សូមអរគុណ។

**ស៖** សូមអរគុណលោក។ តាមដែលលោកបានដឹង និងលោកបានឃើញ ថាតើម្នាក់ៗត្រូវតែចាកចេញ ឬក៏មានអ្នកខ្លះអាចបន្តស្នាក់នៅក្នុងទីក្រុងហ្នឹងបានទៅទៀត?

**ធ៖** បាទ ខ្ញុំមិនដឹងទេបាទៗ។

[១០:៣៧:១៥]

**ស៖** តើលោកមានបានឃើញអ្នកណាម្នាក់ ហ៊ានបដិសេធមិនចាកចេញ ឬក៏ស្នើសុំនៅ ស្នាក់នៅជាបន្តទៅទៀតដែរឬទេ?

**ធ៖** ខ្ញុំមិនបានដឹងទេ ពីព្រោះពេលគេឲ្យខ្ញុំចេញ ខ្ញុំចេញទៅ។ ដូច្នេះត្រង់ថាអ្នកណាបដិសេធមិនទៅ អីមិនទៅ ខ្ញុំមិនបានដឹងទេបាទៗ។

**ស៖** សូមអរគុណ។ ឥឡូវនេះ បន្តទៅនិយាយអំពីកៀនស្វាយវិញម្តង ដែលជាកន្លែងដែលលោកបានទៅនោះ តើចម្ងាយពីភ្នំពេញទៅកៀនស្វាយប៉ុន្មានដែរ ហើយតើលោកចាំទេ? លោកចំណាយពេលវេលាអស់រយៈពេលប៉ុន្មានដែរធ្វើដំណើរទៅដល់កៀនស្វាយហ្នឹង?

**ធ៖** គឺថាយើង ពីភ្នំពេញ ទៅកៀនស្វាយ ប៉ុន្មានជា២០គីឡូជាង ហើយដល់ខ្ញុំទៅឈប់ មិនទាន់ដល់កៀនស្វាយហ្នឹងទេ ទៅដល់វត្តចំប៉ា ភូមិចំប៉ាហ្នឹង វាហួសព្រែកឯង ទៅពីហ្នឹងទៅដូចជា១០គីឡូជាងអីហ្នឹងតាមមើលទៅ ក្រោម២០គីឡូអីហ្នឹង ក្នុងរវាងហ្នឹង មិនឆ្ងាយប៉ុន្មានទេ។ ប៉ុន្តែទៅហ្នឹងចេញ ពីភ្នំពេញទៅ ដល់តែភ្លឺបានដល់ ពីព្រោះវាចង្អៀតពេក ន៎! ទៅមួយម៉ែត្រពីរម៉ែត្រ ឈប់មួយម៉ែត្រពីរម៉ែត្រឈប់ ភ្លឺបានដល់ ទៅពីព្រលប់ ពីភ្លឺ មួយយប់បានដល់។

**ស៖** នៅពេលដែលលោកបានទៅដល់កៀនស្វាយ ពីម្សិលមិញបានលើកឡើងថា គឺថាគេឲ្យលោកបោះទីតាំងនៅទីនោះជាមួយគ្រួសាររបស់លោក។ តើលោកបានសុំការអនុញ្ញាតបោះទីតាំងជាមួយក្រុមគ្រួសាររបស់លោកហ្នឹង លោកសុំការអនុញ្ញាតពីអ្នកណា?

[១០:៣៩:៥១]

**ធ៖** គឺថាថ្ងៃដំបូងហ្នឹង គឺទៅ ខ្ញុំឃើញដូចជាមិនទាន់មានការចាត់តាំងរបៀបអីរៀបរយទៅជាសហករណ៍នុំងទេ។ ហើយដល់ទៅ ផ្ទះបងប្អូនហ្នឹងក៏សូមស្នាក់គាត់នៅហ្នឹង គាត់ក៏ឲ្យនៅទៅ។ អត់ទាន់មានសហករណ៍ ប្រធានអីខ្ញុំអត់ដឹងទេ ដូចមិនទាន់មានអីច្បាស់លាស់ទេ ហើយទៅអ្នកណានៅត្រង់ក៏នៅសិនទៅ អ្នកណាចង់ទៅហួសតទៅទៀតក៏ទៅៗ។ ឆ្លងទន្លេទៅត្រើយម្ខាងក៏ទៅៗ អត់ទាន់មានអីច្បាស់លាស់ទេ ខ្ញុំនៅជាមួយបងប្អូនយើងអីចឹងទៅ។

**ស៖** ដូច្នេះសក្ខីកម្មពីដំបូងៗរបស់គាត់ហ្នឹង គឺថាលោកមិនបានសុំការអនុញ្ញាតពីអ្នកណាម្នាក់ ដើម្បីស្នាក់នៅទីនោះទេ គឺថាលោកសម្រេចស្នាក់នៅទីនោះតែម្តង អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។ ហើយពេលនោះគឺថាគិតថា សុំនៅហ្នឹងក៏អាចថាបណ្តោះអាសន្នក៏បាន ដែរ ព្រោះថាគិតថាមិនមែននៅហ្នឹង គិតថា មានគំនិតទៅដល់ស្រុកនោះ ហើយថា ដោយមានបងប្អូនគេ ព្រមឲ្យនៅក៏នៅសិនទៅចាំមើលមើល៍វាទៅម៉េចទៀត ហើយក៏នៅហ្នឹងទៅ។ ហើយក៏គាត់ព្រមឲ្យនៅ ទៅ។

[១០:៤១:៣៤]

**ស៖** លោកកើតនៅខេត្តកំពត តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ នៅក្នុងខេត្តកំពត ស្រុកឈូកបាទ។ ស្រុកឈូក បាទ។

**ស៖** លោកបាននិយាយថា លោកចង់ធ្វើដំណើរទៅខេត្តកំពត ហេតុអីក៏មិនលោកមិនធ្វើដំណើរ ទៅកាន់ខេត្តកំពត?

**ឆ៖** ពីព្រោះពេលចេញពីផ្ទះមក ខ្ញុំមកនៅម្តុំជិតច្បារអំពៅនេះ គេឲ្យចេញៗទៅម្តុំស្ពានក្បាល ថ្នល់ហ្នឹង ខ្ញុំគិតថា ទៅតាមផ្លូវតាខ្មៅទេ ប៉ុន្តែដល់វាចង្អៀតពេកឈានតែមួយជំហានមិនបានផង ក៏វាគេ រុញឲ្យឡើងស្ពានទៅ ស្ពាននេះហ្នឹងក៏ឡើងអ៊ីចឹងទៅ ចេះតែទៅមុខទៅ តែទៅហើយគ្មានថយក្រោយបាន ទេ វាចង្អៀតណាស់ ហើយទៅតាខ្មៅទៅមិនរួច បើទៅរួចខ្ញុំទៅហើយ។ អាហ្នឹងអ៊ីចឹង។

[១០:៤២:៥១]

**ស៖** សូមអរគុណលោក។ លោកបានជម្រាបមកសហសេវិករបស់ខ្ញុំពីព្រឹកមិញនេះ ថាលោក ត្រូវបានគេបញ្ជូនទៅសហករណ៍ទីពីរ មួយរយៈក្រោយមក។ លោកអាចជម្រាបមកខ្ញុំបានទេថា អ្នក ណាបញ្ជូនលោកទៅកន្លែងសហករណ៍ទីពីរហ្នឹង?

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** តើមានអ្នកណាម្នាក់មកប្រាប់ឲ្យលោក ចេញទៅកាន់សហករណ៍ហ្នឹងដែរឬទេ?

**ឆ៖** បាទ មានមិត្តភក្តិម្នាក់ដែលគេនៅភ្នំពេញហ្នឹង គេទៅប្រាប់ខ្ញុំ តែខ្ញុំមិនដឹងជាគេនុំងមាន ឋានៈជាអ្វីទេ ប៉ុន្តែស្គាល់គ្នាគេថា ឲ្យត្រៀមទៅ ទៅភ្នំពេញ ទៅសហករណ៍-- ទៅភ្នំពេញប៉ុណ្ណឹងទេ។

[១០:៤៤:២២]

**ស៖** លោកហាក់បីដូចជា ទៅមុខមួយជំហានមុនខ្ញុំហើយ។ ខ្ញុំសំដៅទៅលើទីតាំងរបស់លោក

នៅកៀនស្វាយ ហើយលោកធ្វើដំណើរទៅកាន់សហករណ៍នៅខាងត្បូងទីក្រុងភ្នំពេញ អ៊ីចឹងហើយបានជាខ្ញុំសួរទៅលោកថា តើអ្នកណាឲ្យលោកធ្វើដំណើរទៅកាន់សហករណ៍ទីពីរ គឺនៅខាងត្បូងទីក្រុងភ្នំពេញហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ! សំណួរនេះតំណាងសហព្រះរាជអាជ្ញាជាតិបានសួររួចហើយ។ សំណួរច្រំដែល។

[១០:៤៥:០០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកក៏បានជម្រាបមកខាងយើងខ្ញុំផងដែរថា នៅសហករណ៍ទីពីរនោះ គេបានឲ្យលោកសរសេរប្រវត្តិរូប ហើយលោកមិនដឹងថាត្រូវផ្ញើទៅឲ្យអ្នកណានោះទេ។ តើលោកមានបានដឹងទេ មានមូលហេតុអ្វីបានជាគេបង្ខំឲ្យលោកសរសេរប្រវត្តិរូបហ្នឹង?

**លោក សគឹម ល្មុត៖**

**ឆ៖** គឺថាទៅដល់កន្លែងនោះ ខ្ញុំឃើញថា អ្នកណាក៏ត្រូវតែធ្វើ ត្រង់ជាពួកបញ្ញាជន ពួកខាងបងប្អូនកសិករ កម្មករអី ឃើញថា ធ្វើទាំងអស់គ្នា ហើយមានបងប្អូនកសិករខ្លះចាស់ៗគាត់មិនចេះសរសេរហ្នឹង គាត់ឲ្យខ្ញុំជួយសរសេរឲ្យគាត់ នោះធ្វើទាំងអស់គ្នា។ ហើយជូនទៅប្រធានសហករណ៍ទៅ ត្រង់ថាគេយកទៅណាមកណា គឺខ្ញុំមិនដឹងដែរទេបាទ ធ្វើទាំងអស់តែគ្នា។

[១០:៤៦:២៦]

**ស៖** តើគេមានប្រាប់លោកឲ្យសរសេរយ៉ាងដូច្នេះ ឬក៏ថា លោកសរសេរដោយខ្លួនឯង?

**ឆ៖** គឺគេប្រាប់ឲ្យសរសេរៗប្រវត្តិរូប។

**ស៖** គឺថា យើងបាននិយាយពីបញ្ហានេះពីមុនមកហើយ ប៉ុន្តែសំណួររបស់ខ្ញុំ ថាតើលោកសរសេរអំពីអ្វីខ្លះ?

**ឆ៖** សរសេរគឺថា ផ្តើមឡើងគឺថាពី ឈ្មោះយើង ស្រុកកំណើតនៅឯណា រៀនសូត្រកម្រិតណា ធ្វើការនៅឯណាហូរហែអ៊ីចឹងមក។ ប្រាប់គេអ៊ីចឹង ធ្វើការនៅក្រសួងណាអីៗ មុនដែលយើងចេញទៅសហករណ៍ហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០ នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការ សនវការ។ មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សី និងមេធាវី ប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការវិញ នៅ តាមម៉ោងកំណត់។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៨ នាទី ដល់ម៉ោង ១១:០៧ នាទី)*

[១១:០៦:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់វេទិកាជូនទៅក្រុម តំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សគីម ល្មុត ឥឡូវនេះខ្ញុំចូលទៅដល់ការងាររបស់លោក ដែលធ្វើការនៅភ្នំពេញ នៅពេលដែលត្រឡប់មកទីក្រុងភ្នំពេញ បន្ទាប់ពីទៅសហករណ៍ទីពីរនោះ។

តើលោកនៅចាំដែរឬទេអំពីខែ ឬក៏ឆ្នាំនៅពេលដែលលោកត្រឡប់មកភ្នំពេញកាលសម័យនោះ?

**លោក សគីម ល្មុត៖**

**ឆ៖** ខ្ញុំមិនចាំៗច្បាស់ពីខែទេ ខ្ញុំគិតស្មានប្រហែលជាក្នុងដើមឆ្នាំ១៩៧៦ ហ្នឹង គឺថាបើប្រៀប ធៀបនឹងរដូវច្រូតកាត់ហ្នឹង គឺថាធ្វើស្រែបានមួយវស្សា ច្រូតហើយ ច្រូតកាត់ហើយហ្នឹង គេហៅខ្ញុំមក

ភ្នំពេញ។

**ស៖** សូមអរគុណ។ ឥឡូវនេះ នៅពេលដែលលោកត្រឡប់មកដល់ភ្នំពេញ លោកបានជម្រាបប្រាប់តុលាការថា លោកបានជួប បាទគណៈកម្មាធិការឧស្សាហកម្មដែលប្រធានគណៈកម្មាធិការនោះឈ្មោះ អន លោកបាននៅកន្លែងហ្នឹង។ ហើយលោកបានស្គាល់នៅពេលនោះគឺ-- ហើយគាត់ជា-- បាទ ឌឿន ជាប្រធានខាងពាណិជ្ជកម្ម ហើយក្រោយមកថាមាន វន វ៉េត ជាអ្នកទទួលបន្ទុកខាងពាណិជ្ជកម្ម។ តើលោកអាចបញ្ជាក់ត្រឹមត្រូវទេ ព្រោះខ្ញុំមិនច្បាស់ត្រង់ចំណុចនេះ?

**ឆ៖** តាមខ្ញុំក្តាប់បានគឺ វន វ៉េត មិនមែនៗ ជាប្រធានពាណិជ្ជកម្មទេ អាចគាត់នៅពីលើ ពីលើទាំងពាណិជ្ជកម្ម ទាំងឧស្សាហកម្ម គឺគាត់-- គឺថាយើងសេដ្ឋកិច្ចវារួមពាណិជ្ជកម្ម ឧស្សាហកម្ម។ គាត់ដូចជានៅខាងលើ។

[១១:១០:០០]

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់ច្បាស់បែបនេះ។ ឥឡូវនេះដោយហេតុថាយើងបានពិភាក្សាអំពីរចនាសម្ព័ន្ធ អំពីគណៈកម្មាធិការមួយចំនួន ខាងថ្នាក់លើ ហើយនិងថ្នាក់ក្រោមនោះថា សូមឲ្យលោកជួយបំភ្លឺកំណត់ ថាតើមនុស្សមួយចំនួនតួនាទីរបស់គាត់ដូចម្តេចនៅក្នុងឯកសារមួយចំនួន ដូចដែលលោកបានបង្ហាញខាងដើម?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំចង់សូមអនុញ្ញាត ខ្ញុំចង់បង្ហាញជូនសាក្សីនូវឯកសារមួយ IS13.2 ដែល-- ដែលបាន-- តុលាការបានទទួលស្គាល់ថាជា E3.182 ជាកំណត់ហេតុរបស់កិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៥។

[១១:១១:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏មានឯកសារលើក្រដាស សូមឲ្យមន្ត្រីតុលាការ អនុញ្ញាតបង្ហាញទៅលោកសាក្សីអំពី-- នូវឯកសារនេះបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សីពិនិត្យ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សគីម ល្មុត យើងមិនពិនិត្យមើលលម្អិតលើឯកសារនេះទេ។ ខ្ញុំចង់ឲ្យលោកជម្រាបប្រាប់យើងអំពីឈ្មោះមនុស្សចំនួនដែលនៅលើទំព័រទីមួយ។ បាទ ថាតើជាគណៈប្រតិភូដែល ឬក៏ការផ្ទេរនូវតំណែង នូវអំណាច នូវ-- ទៅឲ្យមនុស្សចំនួនទាំងនោះដែរឬទេ? តើលោកស្គាល់នូវលេខទីបាទទី៣នេះ គឺសមមិត្ត វ៉ាន់ បាទតើលោកស្គាល់គាត់ទេ? ដែលថាសមមិត្ត វ៉ាន់ គាត់ទទួលខាងការងារបរទេស ទាំងបក្ស ទាំងរដ្ឋ បាទ?

[១១:១២:៤៦]

**លោក សគីម ល្មុត៖**

**ឆ៖** ជាដំបូងខ្ញុំសូមបញ្ជាក់ថា ឯកសារនេះខ្ញុំមិនដែលដឹងទេ ហើយក៏មិនដែលបានប្រជុំអីគណៈអចិន្ត្រៃយ៍អីដែរ។ គឺថាខ្ញុំមិនដែលពាក់ព័ន្ធ ព្រោះខ្ញុំក៏មិនមែននៅនឹងគណៈចិន្ត្រៃយ៍ដែរ ហើយនិងទី៣ គេដាក់ថា "សមមិត្ត វ៉ាន់" ការងារបរទេស ទាំងបក្ស ទាំងរដ្ឋ។ បាទ អាហ្នឹងឯកសារថាអីចឹងហើយចង់ឲ្យខ្ញុំបញ្ជាក់ថាម៉េចត្រង់ហ្នឹង? ខ្ញុំចង់សួរវិញ ថាឲ្យខ្ញុំបញ្ជាក់ថាម៉េចបាទ?

**ស៖** គ្រាន់តែចង់សួរថា សមមិត្ត វ៉ាន់ ហ្នឹងជាអ្នកណាបាទ? ប្រសិនបើលោកមិនច្បាស់ទេ លោកជម្រាបយើង ឬតុលាការថាលោកមិនច្បាស់ទេ។

**ឆ៖** ខ្ញុំមិនច្បាស់ទេបាទ។

[១១:១៣:៤៨]

**ស៖** នៅលេខ៤ យើងមានឈ្មោះថា "សមមិត្ត ហែម" តើឈ្មោះ ហែម នោះដែលលោកនិយាយពីខាងដើម ដែលថាទទួលបន្ទុកខាងរណសិរ្ស និងរាជរដ្ឋាភិបាល ហើយពាណិជ្ជកម្ម ខាងបញ្ជីនិងតម្លៃ។ តើឈ្មោះហ្នឹងទេ ដែលលោកនិយាយពីខាងដើមមកនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញតំណាង-- អ៎ មេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់សំណួរនេះ ដោយសាក្សីបានចង្អុលបង្ហាញថា គាត់មិនដែលបានឃើញឯកសារនេះទេពីមុនមក។ ហើយសហព្រះរាជអាជ្ញាដូចជាព្យាយាមឱ្យសាក្សីគាត់សន្និដ្ឋានថា ឈ្មោះមនុស្សនៅលើឯកសារនេះ គឺជា-- ដែលថាអ្នកផ្សេងទេដែលនិយាយពីរឿងនេះ។ ព្រោះថាសាក្សីមិនស្គាល់ មិនដឹង មិនឃើញឯកសារនេះគាត់មិនអាចធ្វើការទស្សន៍ទាយបានទេ ដោយផ្អែកទៅលើការសម្រេចរបស់តុលាការពីខាងដើម គឺថា-- ហើយសុំឱ្យតុលាការដកយកឯកសារនេះមកវិញ។ ប៉ុន្តែខ្ញុំសូមអនុញ្ញាតមតិពីយោបល់លើបញ្ហានេះថា តើត្រូវដកទុក ដកឯកសារនេះចេញ ឬទុកលើអេក្រង់នេះបាទ?

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមទៅលើសហការីដែលបានជំទាស់ទៀត។ គឺថាជាពិសេស គឺសាក្សីមិនដែលបានបញ្ជាក់ថាសមមិត្ត ហែម នេះទទួលបន្ទុកខាងរណសិរ្ស និងរាជរដ្ឋាភិបាលហ្នឹងទេ គាត់មិនដែលបានឆ្លើយអ៊ីចឹងពីមុនមកទេ។ ហើយអ្វីដែលសហព្រះរាជអាជ្ញាបានលើកអម្បាញ់មិញគឺជាការលើកនាំមុខទៀតផងបាទ។ សូមអរគុណ។

[១១:១៥:៥០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា អាចមានអ្វីត្រូវឆ្លើយទៅនឹងការជំទាស់នេះទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

បាទលោកប្រធាន ជាបឋម ការបកស្រាយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះគឺថា បើសិនជាមានមូលហេតុសមស្រប ដើម្បីឱ្យសាក្សីគាត់បញ្ជាក់បានគឺយើងអាចធ្វើបែបនោះបាន។ ដោយជាក់លាក់នោះគឺថា ឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីរបស់ នួន ជា និងឯកសារនេះគឺបានបង្ហាញទៅ

សាក្សី គឺគាត់បានឃើញពីមុន ហើយៗលោកបានយោងទៅរកឯកសារនេះកាលពីគាត់ផ្តល់បទសម្ភាសន៍ឲ្យសហចៅក្រមស៊ើបអង្កេត ដូច្នេះហើយគឺគាត់បានឃើញពីមុន។ ហើយត្រឡប់មករកការជំទាស់របស់មេធាវីរបស់លោក ខៀវ សំផន វិញ ហើយយើងមិនមាន-- បានសួរនាំមុខទៅសាក្សីនោះទេ។ គ្រាន់តែសួរគាត់ថា តើគាត់នៅចាំ នៅនឹកឃើញដែរទេ? យើង-- ហើយគាត់ឆ្លើយថាមិនច្បាស់នៅពេលសំណួរនោះ។ ហើយយើងបានព្យាយាម-- ឲ្យគាត់បង្ហាញយើងថា តើគាត់បានជួបមនុស្សដែលមាននៅលើបញ្ជី? ថាតើគាត់ស្គាល់ដែរឬទេ? បើមិនស្គាល់យើងនឹងបន្តទៅមុខទៀតបាទ។

[១១:១៧:១៣]

**ប្រធានអង្គជំនុំ៖**

សាក្សីមើលឯកសារហ្នឹងម្តងទៀតមើល៍ តើលោកធ្លាប់បានឃើញឯកសារនេះពីមុនមកទេ ជាពិសេសនៅក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មរបស់លោក ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានធ្វើសម្ភាសន៍ជាមួយលោកកន្លងមក។

**លោក សគីម ល្មុត៖**

សូមគោរពលោកប្រធាន ខ្ញុំបាទ ពេលដែលស៊ើបអង្កេតហ្នឹងមិនដែលបានបង្ហាញឯកសារនេះឲ្យខ្ញុំឃើញទេ។ ហើយបើនិយាយអំពីការចាត់តាំងរបៀបណាៗ ក្នុងរណសិរ្ស ឬកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមិនដឹងជានរណាកាន់អីៗ ខ្ញុំមិនដែលបានដឹង បាននេះទេ។ ហើយខ្ញុំ-- ឯកសារយើងទើបតែឃើញអំមិញហ្នឹង។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីការពារក្តីទាំងពីរក្រុមមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយនឹងសំណួរអម្បាញ់មិញនេះទេ ហើយមន្ត្រីរដ្ឋបាលតុលាការ ដកឯកសារនេះចេញពីសាក្សី ហើយនិងឲ្យជំនួយការដកឯកសារចេញពីអេក្រង់កុំព្យូទ័រ។

[១១:១៨:៣៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដើម្បីកំណត់ត្រាហ្នឹងគឺថា យើងសំណួរនិងចម្លើយ៣៦ នៃបទសម្ភាសន៍ជាមួយសាក្សីនេះ គឺសាក្សីរូបនេះបានពិភាក្សាពីឯកសារជាមួយសហចៅក្រមស៊ើបអង្កេត

ប៉ុន្តែយើងខ្ញុំគោរពសេចក្តីសម្រេច។ ហើយយើងខ្ញុំអនុញ្ញាតបន្តទៅមុខទៀតបាទ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សគីម ល្មុត យើងចូលទៅរកឯកសារមួយទៀត ដែលលោក-- គេបានបង្ហាញលោកពីមុន។

[១១:១៩:១៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

ហើយសូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារនេះគឺ E3/235 ឥឡូវនេះ សាក្សីបានឃើញឯកសារនៅក្នុងការសម្ភាសទីពីរ គឺឯកសារ D279/7.1។ នេះគឺជាកំណត់ហេតុ ឬក៏សេចក្តីសម្រេច-- សេចក្តីសង្ខេបនៃសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ដែលដាក់បញ្ជើនៅគណៈកម្មាធិការមួយចំនួន ដែលសាក្សីបានរៀបរាប់ខាងដើមមកហើយ។ ដូច្នេះសូមអនុញ្ញាតតុលាការ ដើម្បីដាក់បង្ហាញឯកសារនេះនៅលើអេក្រង់ និងបង្ហាញជូនឯកសារទៅសាក្សីផងដែរបាទ។

[១១:២០:០៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យត្រឹមតែយកសាក្សី-- យកឯកសារនោះទៅបង្ហាញសាក្សីជាមុនសិនថាតើសាក្សីហ្នឹង បានស្គាល់ឯកសារហ្នឹងពីមុនដែរឬទេ? សាក្សីស្គាល់ ទើបអង្គជំនុំជម្រះអនុញ្ញាតបន្តទៀត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សីពិនិត្យ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអភ័យទោស តើលោកអាចឆ្លើយបានទេ លោក-- បាទ ប៉ុន្តែខ្ញុំអត់ទទួលបានការបកប្រែ។

**លោក សគីម ល្មុត៖**

**ឆ៖** បាទអត់ ខ្ញុំមិនដែលបានឃើញទេបាទ។

[១១:២១:៣៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូម-- លោកប្រធាន ខ្ញុំសូមបំភ្លឺ ខ្ញុំមិនភ្ញាក់ផ្អើលពីអ្វីដែលគាត់មិនចងចាំនោះទេ។ គឺថាមានឯកសារច្រើនណាស់ដែលគេបានបង្ហាញទៅគាត់។ ហើយឯកសារនោះ គឺបានបង្ហាញគឺថា D279/7

ដែលជាបទសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេតនោះ។ ខ្ញុំមិនស្នើដឹកសាក្សីក្នុងវិធីមិនសមស្រប នោះទេ ប៉ុន្តែឯកសារនេះ គឺគេបានបង្ហាញជូនគាត់ទៅហើយ ប្រហែលជាគាត់ភ្លេច។ ប៉ុន្តែខ្ញុំគ្រាន់តែ សួរគាត់ ថាតើគាត់នៅសំណួរមួយចំនួន ថាតើគាត់អាចបំភ្លឺបន្ថែមបានដែរឬទេបាទ? ហើយប្រសិនបើ ឯកសារខ្លះ គឺមានហត្ថលេខារបស់សាក្សីផងដែរ ដែលគាត់បានឃើញ បានពិភាក្សា ហើយឯកសារ ហ្នឹង មាននៅក្នុងសំណុំរឿងផងដែរ លោកប្រធាន បាទ។

**ប្រធានអង្គជំនុំ៖**

ឯកសារដែលដាក់ជូនទៅសាក្សីកំពុងពិនិត្យនេះ តើមានហត្ថលេខាលើឯកសារនេះដែរឬទេ នៅ ក្នុងអំឡុងពេលនេះស្តាប់សក្ខីកម្មរបស់គាត់ ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើប អង្កេតនោះ?

ខាងសហព្រះរាជអាជ្ញា?

[១១:២៣:០៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

បាទ លោកប្រធាន បើសិនលោកសម្រេចផ្អាកពីនេះ យើងខ្ញុំនឹងដកចេញអំពីអេក្រង់ ហើយយើង នឹងមានឯកសារមួយទៀត។ គឺថាវាមានឯកសារហ្នឹង គឺមានលេខច្រើនជាងមួយ ហើយយើងនឹងរក ឯកសារដែលបំពេញទៅតាមលក្ខខណ្ឌហ្នឹង ដើម្បីបង្ហាញបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកឯកសារអម្បាញ់មិញនេះ ចេញពីសាក្សី ពីព្រោះសាក្សីបានឆ្លើយច្បាស់ លាស់ នៅក្នុងសវនាការហើយ ថាគាត់មិនដែលស្គាល់ មិនដែលឃើញឯកសារនេះទេ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** តើលោកដឹងដែរឬទេ ថាតើ ខៀវ សំផន ហៅ ហែម មានមុខតំណែងអ្វីមួយ ឬក៏មុខងារ អ្វីដែរឬទេ នៅក្នុងៗមន្ទីរពាណិជ្ជកម្ម ឬក៏មន្ទីរសេដ្ឋកិច្ចនោះ?

[១១:២៥:០៨]

**លោក សគឹម ល្មុម៖**

**ឆ៖** ខ្ញុំមិនមានឯកសារអ្វីច្បាស់លាស់ដាក់បញ្ជាក់ទេ។ ប៉ុន្តែ ដែលខ្ញុំឃើញនៅចំណារលើឯកសារខ្លះដែលលោកស៊ើបអង្កេតយកទៅបង្ហាញខ្ញុំនោះ ពេលនោះមានឯកសារច្រើនណាស់។ ឯកសារខ្លះឱ្យខ្ញុំអាន ហើយឯកសារខ្លះគ្រាន់តែឱ្យខ្ញុំមើលតែចំណារទេ។ តើចំណារហ្នឹងវាយ៉ាងម៉េច? នរណាស៊ីញេ នរណាអីអ៊ីចឹងទៅ។ ប៉ុន្តែអាចសន្និដ្ឋានបានថា ខាងមន្ទីរពាណិជ្ជកម្មហ្នឹងធ្វើអ្វីៗ គឺថាផ្ញើទៅៗបងវន, បងហែម អ៊ីចឹង។ ដូច្នេះ អាចសន្និដ្ឋានថា បងវន, បងហែម គាត់នៅៗកន្លែងសេដ្ឋកិច្ចហ្នឹងហើយ។ តែត្រង់មុខនាទីច្បាស់លាស់លម្អិតថាធ្វើអីៗដូចថា ខ្ញុំមិនមាន-- មិនអាចដឹងបានទេ។ គ្រាន់តែដឹងថាពីពាណិជ្ជកម្មហ្នឹងទៅ ទៅខាងលើនុ៎ង មានពីរ វន វ៉េត ហើយនិង បងហែម ហ្នឹងបាទ។ អាចបញ្ជាក់បានប៉ុណ្ណឹង។

**ស៖** សូមឱ្យលោកបំភ្លឺបញ្ហានេះបន្ថែមទៀត។

[១១:២៦:២៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតលោកប្រធាន ចង់បង្ហាញឯកសារសេចក្តីថ្លែង កំណត់ហេតុរបស់ អូ.ស៊ី.អាយ.ជេ គឺ D279/6 បាទ ដើម្បីសួរសាក្សីអំពីប្រធានដដែលនេះបាទ។

**ប្រធានអង្គជំនុំ៖**

*(មិនឮសំឡេង)*

[១១:២៦:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៣:០៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ លោកស្រីចៅក្រមស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ មើលទៅហាក់មានការយល់ច្រឡំគ្នា ដោយសារតែការបកប្រែ គឺពាក់ព័ន្ធទៅនឹងឯកសារពីរដែលសហព្រះរាជអាជ្ញាបានយកមកយោង។ ខ្ញុំបានកត់សម្គាល់ឃើញមានឯកសា E3/235 និង D279/6 ខ្ញុំមិនដឹងថាតើបានលើកឡើងត្រឹមត្រូវ ឬក៏អត់ទេ? វាហាក់មានការ

យល់ច្រឡំគ្នា ដែលនាំឲ្យមានការសម្រេចពីលោកប្រធានថា ឯកសារទាំងអស់នេះបានយកមកបង្ហាញសាក្សីនៅក្នុងពេលស៊ើបអង្កេត។

ខ្ញុំគិតឃើញថា សហព្រះរាជអាជ្ញាសូមជួយឲ្យពន្យល់អំពីស្ថានភាពនៃឯកសារទាំងនេះឲ្យបានលម្អិតបន្តិចទើបប្រសើរ។ ហើយអង្គជំនុំជម្រះបានសម្រេចបានយោងទៅសេចក្ដីសម្រេចមុនរបស់ខ្លួនពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារដែលសាក្សីមិនធ្លាប់បានឃើញពីមុនមកនោះ។ ហើយបន្ទាប់មកសេចក្ដីសម្រេចនោះ គឺថាបានសម្រេចជាថ្មីថា ឯកសារទាំងនេះអាចនឹងយកមកប្រើជាមូលដ្ឋាន ដើម្បីការតាំងសំណួរ បើសិនណាជាឯកសារទាំងអស់នេះ វាពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធី។ ដូច្នេះលោកសហព្រះរាជអាជ្ញា លោកអាចជួយបញ្ជាក់ជូនអង្គជំនុំជម្រះអំពីស្ថានភាពនៃឯកសារទាំងនេះបានទេ? សូមអរគុណ។

[១១:៣៤:៥៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍។ ផ្នែកដែលយើងខ្ញុំចង់បាននេះ គឺខ្ញុំអាចរកឃើញពីឯកសារជា នៅលើក្រដាសដែលបានបង្ហាញមកសាក្សី។ ឯកសារទីមួយ គឺឯកសារចុះថ្ងៃ-- ខែតុលា ១៩៧៥ កំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ គឺ D279/6.1។ វាអាចមានការយល់ច្រឡំអ៊ីចឹងមែន ដោយសារឯកសារទាំងអស់នេះមានលេខច្រើនជាងមួយ គឺឯកសារ D279/6.1 គឺមានហត្ថលេខារបស់សាក្សី ដែលខាងអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបានបង្ហាញជូនសាក្សីរូបនេះ។ ហើយដែលឯកសារនេះ គឺមានតែមួយទំព័រទេ។ ដូច្នេះឯកសារដែលចង់បង្ហាញមួយទៀត គឺD279/7.1 នៅទំព័រមុខនៃឯកសារនេះ មានហត្ថលេខារបស់សាក្សី ក៏ដូចជាហត្ថលេ-- និងហត្ថលេខារបស់អ្នកមន្ត្រីស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតផងដែរ។

[១១:៣៦:១៦]

ហើយឯកសារ-- គឺថាលេខក្រោយៗទៀត គឺថាបានយកមកដាក់ជំនួសគឺលេខមុន ដូច្នេះអង្គជំនុំជម្រះនឹងឃើញនូវលេខនៃឯកសារនេះ។ ប៉ុន្តែហត្ថលេខារបស់សាក្សី គឺថាមាននៅលើឯកសារដែលត្រូវសូមយកមកបង្ហាញនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសោកស្ដាយដែលកាត់ផ្ដាច់ ការកត់សម្គាល់ខ្ញុំមានប្រយោជន៍សម្រាប់ភាគីទាំងអស់។ គោលបំណងរបស់ខ្ញុំ ដោយសារតែភាគី សហការីរបស់ខ្ញុំស្ដាប់ជាភាសាខ្មែរ គឺថាមានចម្លើយមួយរបស់សាក្សីមិនត្រូវបានបកប្រែដោយពេញលេញជាភាសាបារាំងនិងអង់គ្លេសនោះទេ។ គឺថានៅពេលដែលគាត់-- ត្រង់កន្លែងថា ពេលដែលគាត់លើកនិយាយពីឯកសារ គឺថាមានការនិយាយជាភាសាខ្មែរថា ឯកសារមួយចំនួនត្រូវបានបង្ហាញទៅគាត់។ ក៏ប៉ុន្តែជួនកាលខ្លះមានតែផ្នែកល្អិតណាមួយនៃឯកសារទេ ដែលបានបង្ហាញទៅសាក្សី។ អ៊ីចឹងដើម្បីឲ្យការកត់កំណត់ហេតុ ឬការពិភាក្សានេះវាច្បាស់លាស់នោះ សូមឲ្យខាងសហព្រះរាជអាជ្ញាបំភ្លឺត្រង់ចំណុចនេះទៅសាក្សី។ ទោះជាយ៉ាងណាក៏ដោយគឺថា ជាអ្វីដែលនិយាយជាភាសាខ្មែរអម្បាញ់មិញនេះ មិនត្រូវបានបកប្រែជាភាសាបារាំងឬក៏ភាសាអង់គ្លេសទេ។ អ៊ីចឹងសូមឲ្យបំភ្លឺត្រង់ចំណុចទាំងអស់នេះឡើងវិញ។

សូមអរគុណលោកប្រធាន។

[១១:៣៨:០០]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានខ្ញុំសូមតែមួយនាទីទេ។ សាក្សីបានបញ្ជាក់រួចហើយថា គាត់មិនបានដឹងអំពីឯកសារនេះពីមុនមកនោះទេ គាត់ទើបតែដឹងឯកសារនេះជាលើកដំបូង។ ដូច្នេះអ្នកស៊ើបអង្កេត គឺគាត់ព្យាយាមបង្កើតឲ្យសាក្សីមានការចងចាំ ដាស់ការចងចាំរបស់សាក្សីថា តើគាត់បានដឹងទេនៅពេលនោះ? និយាយដោយស្មោះត្រង់ទៅ គឺថាខ្ញុំគិតថាមិនអាចយកឯកសារដែលមានបញ្ជីឈ្មោះមនុស្សមកបង្ហាញទេ។ ប៉ុន្តែយើងអាចសួរសាក្សីនេះថាអ៊ីចេះ ក្រោយពីបានឃើញឯកសារនេះថាតើគាត់ដឹងអ្វីខ្លះដែរ? អាចចងចាំអ្វីខ្លះដែរ? ថាយោងទៅលើអង្គហេតុទាំងឡាយដែលគាត់នឹងអាចចងចាំពីពេលនោះមក។ មិនមែនត្រូវបង្កើតឲ្យមានការចងចាំក្រោយពីការបង្ហាញឯកសារនេះនោះទេ។ សូមអរគុណលោកប្រធាន។

[១១:៣៨:០២]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំឃើញថា មេធាវីការពារក្ដីកំពុងតែចងស្ពាបសេកខ្ញុំហើយ គឺសាក្សីរូបនេះគាត់បានដឹងអំពីឯកសារដែលបានបង្ហាញទៅគាត់ពីមុននោះ។ ប៉ុន្តែនេះមិនមែនមានន័យថា ជាការធ្វើឲ្យគាត់មានលំហូរចងចាំទៅលើឯកសារនេះទេ។ យើងខ្ញុំ-- នេះជាហេតុផលមួយដែលយើងខ្ញុំចង់បង្ហាញសាក្សីនូវកំណត់

ហេតុស្តាប់ចម្លើយមុនៗរបស់គាត់ មិនមែនគ្រាន់តែសាក្សីនិយាយថា ខ្ញុំអត់ដែលធ្លាប់ឃើញឯកសារនេះទេ។ យើងត្រូវ-- គាត់ទើបតែបានដឹងឯកសារនេះ គឺនៅក្រោយពេលដែលយើងបង្ហាញគាត់នាពេលនេះទេ។ ពេលនេះករណីមិនត្រូវធ្វើបែបនេះទេ គឺថាយើងត្រូវតែមានលទ្ធភាពដើម្បីធ្វើការសាកសួរ ដើម្បីថាតើសាក្សីរូបនេះមានការចងចាំប្រកបទៅដោយហេតុផលដែរ ឬក៏អត់នោះ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាតសំណួររបស់លោក ចំពោះសាក្សីនេះទៀត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

[១១:៤០:៥០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី ខ្ញុំគិតថាយើងធ្លាប់បាន យើងៗ-- អម្បាញ់មិញនេះលោកបានហាក់សម្រាកបន្តិច តើលោកនៅចងចាំបានទេ អាចជម្រាបមកយើងខ្ញុំថា ខៀវ សំផន ហៅ ហែម តើលោកអាចដឹងអំពីតួនាទីមុខងាររបស់គាត់ ទាក់ទងទៅនឹងគណៈកម្មាធិការពាណិជ្ជកម្ម ឬក៏គណៈកម្មាធិការសេដ្ឋកិច្ចនេះ? លោកអាចនៅចាំបានទេ? សូមជួយរៀបរាប់ផង។

[១១:៤១:២៩]

**លោក សគីម ល្មុត៖**

**ឆ៖** ជាដំបូងខ្ញុំសូមប្រធាន លោកប្រធាន ហើយនិងអស់លោក អនុញ្ញាតឲ្យខ្ញុំបំភ្លឺបន្តិច អំពីឯកសារដែលអ្នកអង្កេតគាត់ឲ្យខ្ញុំអាននោះ។ ឯកសារមានច្រើនដូចខ្ញុំអានអម្បាញ់មិញនេះ ជម្រាបអម្បាញ់មិញ គឺថាឯកសារខ្លះឲ្យខ្ញុំអានសេចក្តី ឯកសារខ្លះឲ្យមើលតែចំណារតែ។ ហើយចំពោះឯកសារដែលពាក់ព័ន្ធនឹងរឿងគណៈអចិន្ត្រៃយ៍ ជាទូទៅខ្ញុំនៅក្នុងនុំងវាថ្នាក់តូចនេះ ខ្ញុំមិនមែនជាគណៈអចិន្ត្រៃយ៍ ហើយក៏មិនមែនគណៈកម្មាធិការផ្សេងៗទេ។ គឺថាជាហេតុផលដូចមិនត្រូវខ្ញុំដឹង ហើយខ្ញុំមិនដឹងជាមានហត្ថលេខាខ្ញុំនៅនោះដែរ ខ្ញុំក៏សួរខ្លួនខ្ញុំ ខ្ញុំឆ្ងល់ដែរ។ ប្រជុំៗគណៈអចិន្ត្រៃយ៍ សុទ្ធតែថ្នាក់លើ រួចខ្ញុំវានៅខាងក្រោមនេះ ហើយគេមិនដែលប្រជុំផង ហើយម៉េចក៏មានខ្ញុំនៅស៊ីញេត្រង់នុ៎ង។ ខ្ញុំត្រង់ហ្នឹងខ្ញុំ ខ្ញុំចង់ឲ្យយកអាថាខ្ញុំស៊ីញេហ្នឹងឲ្យខ្ញុំមើល៍។ តើខ្ញុំស៊ីញេអាម៉េចនៅក្នុងគណៈអចិន្ត្រៃយ៍ហ្នឹងខ្ញុំ?

[១១:៤២:៤៨]

**ស៖** សូមអរគុណលោក សគឹម ល្មុត។ អ្វីដែលយើងខ្ញុំពិតជាចង់បានពីលោកនោះ គឺចង់ថាតើអំពីការយល់ដឹងរបស់លោកនៅពេលនោះ ហើយនិងអ្វីដែលលោកបានដឹងជាបន្តបន្ទាប់ក្រោយៗមកទៀត។ ខ្ញុំចង់បង្ហាញនូវផ្នែកខ្លះនៃឯកសារទាំងនេះ គឺថាយើងខ្ញុំមិនបានចោទប្រកាន់លោកថា លោកជាកម្មាភិបាលជាក់ខ្ពស់ទេ លោកមានឋានៈជាកម្មាភិបាលដែលមានឋានន្តរស័ក្តិខ្ពស់នោះទេ។ យើងខ្ញុំចង់បានជំនួយពីលោកមកដល់ខាងយើងខ្ញុំនេះ ទើបយើងខ្ញុំបង្ហាញ-- ចង់បង្ហាញនូវឯកសារទាំងអស់នេះ។ លោកចង់ឲ្យ-- ខ្ញុំសួរឡើងវិញ ថាតើលោកដឹងពីតួនាទីណាមួយរបស់លោក ខៀវ សំផន ហៅ ហែម ទាក់ទងទៅនឹងផ្នែកខាងពាណិជ្ជកម្ម និងផ្នែកខាងសេដ្ឋកិច្ចនោះដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់អ៊ីចេះ គឺថាខ្ញុំនេះ គឺថាទៅតាមឯកសារដែលអ្នកស៊ើបអង្កេតឲ្យខ្ញុំអាន អានដូចជាចំណារជាអី ចុះឡើងៗ រវាងគណៈកម្មាធិការពាណិជ្ជកម្ម លោក វ៉ាន់ រិទ្ធ ហ្នឹង ហើយទៅខាងលើហ្នឹង គឺពីមុនមានលោក វន វ៉េត លោក ហែម ហ្នឹង។ ដូច្នេះសន្និដ្ឋានថា ពីរនាក់ហ្នឹងជាអ្នកទទួលខុសត្រូវខាងសេដ្ឋកិច្ចហើយ។ បញ្ជាក់បានប៉ុណ្ណឹងខាងខ្ញុំ។ ត្រង់តួនាទីលម្អិតអីផ្សេងៗទៀត ខ្ញុំៗមិនអាចដឹងបានទេបាទ សូមជម្រាប។

[១១:៤៤:៣៩]

**ស៖** សូមអរគុណ។ ថាតើសេចក្ដីសន្និដ្ឋានរបស់លោកនេះ លោកសំអាងទៅលើបទពិសោធន៍របស់លោកនៅពេលធ្វើការនៅភ្នំពេញ ពី៧៦ ទៅ៧៩នោះ មែនទេ?

**ឆ៖** ខ្ញុំៗ សំអាង-- (សូមទោស) ខ្ញុំសំអាងទៅលើឯកសារដែលៗ យកបង្ហាញខ្ញុំច្រើនជាងចំណារអីផ្សេងៗនោះ ពីព្រោះថា ខ្ញុំក៏មិនដែលទៅជួបប្រជុំជាមួយលោក ហែម ជាមួយលោក វន វ៉េត ក្រៅពីជួបគាត់ម្ដងនុ៎ង ក្រោយមកមិនដែលទាក់ទងគ្នា ប្រជុំអីជាមួយគ្នាទេ ហើយឆ្លងតាមឯកសារដែលសហ-- ដែលអ្នកស៊ើបអង្កេតបង្ហាញហ្នឹង ឃើញថាចំណារផ្សេងៗរវាងលោក វ៉ាន់ រិទ្ធ ទៅខាងនោះគឺវាមានទំនាក់ទំនងគ្នាអ៊ីចឹង ហើយខ្ញុំសន្និដ្ឋានតាមហ្នឹងបាទ។

[១១:៤៥:៤០]

**ស៖** សូមអរគុណលោក។ ដើម្បីបង្ហាញឲ្យវាមានកាន់តែច្បាស់បន្ថែមទៅទៀតនោះ អំពីតួនាទីរបស់លោក និងអ្វីដែលលោកអាចបានដឹង ត្រឡប់ទៅឆ្នាំ១៩៧៦ នេះ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន ខ្ញុំសូមចូលទៅឯកសារ D279/7.1 ជាឯកសារដែលខ្ញុំបានជម្រាបជូនខាងដើម

ហើយដែលឯកសារនេះ គឺយោងទៅលើការស្ដាប់ចម្លើយសាក្សីលើកទីពីរ របស់អ្នកស៊ើបអង្កេត។ ខ្ញុំគិតថា លោកសាក្សីអាចនឹងជួយមកដល់ខាងយើងបាន ដោយសំអាងទៅលើពីរ ឬក៏បីផ្នែកខ្លីៗនៅក្នុងឯកសារនេះ។ សូមអរគុណ។

លោកប្រធាន ថាតើខ្ញុំអាចសុំការអនុញ្ញាតដើម្បីបង្ហាញឯកសារ D279/7.1 ដែលនិយាយអំពីសេចក្ដីសង្ខេបនៃកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ នៅខែ-- នៅថ្ងៃទី១៩ ខែមេសា ១៩៧៦។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមបង្ហាញឯកសារជាក្រដាសនេះជូនទៅដល់សាក្សី។ ហើយលោកប្រធាន ក៏យើងខ្ញុំក៏សុំការអនុញ្ញាតបង្ហាញផ្នែកនៃពាក់ព័ន្ធឯកសារនេះលើអេក្រង់ផងដែរ ដើម្បីឲ្យខ្ញុំមានលទ្ធភាពតាំងសំណួរទៅសាក្សី ប្រសិនណាជាអង្គជំនុំជម្រះអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ សូមអញ្ជើញ!

[១១:៤៧:៥២]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឥឡូវនេះ លោក សគឹម ល្មុត ឯកសារនេះ បានលើកឡើងនៅត្រង់លេខមួយ ខ្ញុំ-- ឯកសារសរសេរជាការសែតមក គឺនិយាយអំពីការរៀបចំចាត់តាំង គណៈកម្មាធិការផ្សេងៗជុំវិញមន្ទីរ៨៧០។ លោកបានជម្រាបមកខ្ញុំហើយថា លោកស្គាល់ វ៉ាន់ រិទ្ធ ដែលជាសមាជិកជាន់ខ្ពស់របស់គណៈកម្មាធិការពាណិជ្ជកម្ម លោកស្គាល់សមមិត្ត គ្រិន ហើយដែលគាត់ជាខាងផ្នែកគណៈកម្មាធិការកំពង់ផែ ហើយលោកក៏ស្គាល់ហើយថាគាត់ជាលេខាធិការ នៃគណៈកម្មាធិការឧស្សាហកម្មផងដែរ។ ឈ្មោះ អន ដែលជាលេខាធិការគណៈកម្មាធិការឧស្សាហកម្ម។ ខ្ញុំសូមចូលទៅផ្នែកដែលចាប់ផ្ដើមទៅនឹង និយាយអំពីគណៈកម្មាធិការ ដែលមាន ERN ជាភាសាខ្មែរ 00019146។ ហើយឯកសារត្រង់លេខ ERN នេះគឺថានឹងបង្ហាញនៅលើអេក្រង់ឆាប់ៗនេះហើយ។

[១១:៤៩:៥៣]

នៅលើលេខ រ៉ូម៉ាំងបួន ខ្ញុំសូមអាន ខ្ញុំសូមអានជាភាសាអង់គ្លេស ហើយលោកឃើញឯកសារ

នេះ នៅលើអេក្រង់ហើយ លោក សគឹម ល្មុត គឺនៅចំពោះមុខលោក។ ខ្ញុំចាប់ផ្ដើមឡើងជាមួយ លេខរ៉ូម៉ាំង IV អំពីបញ្ហាពាណិជ្ជកម្ម និងឧស្សាហកម្ម។

១) ចំពោះគណៈប្រតិភូពាណិជ្ជកម្មកូរ៉េ។ ហើយខ្ញុំសូមទុកផ្នែកនេះមួយអន្លើសិន។ ទី២) ចំពោះគណៈប្រតិភូពាណិជ្ជកម្មចិន ហើយដែលគឺនៅលើលេខ ERN 00019146 ចាត់តាំងគណៈប្រតិភូមួយសម្រាប់ទទួល និងចរចាមាន សមមិត្ត ឌឿន, សមមិត្ត គ្រិន, សមមិត្ត សាយ, សមមិត្ត ឈឿន, សមមិត្ត ហុក, ការបរទេសម្នាក់ សមមិត្ត ល្មុត។ លោកសាក្សី លោកឃើញឃ្លានេះទេ?

*(គ្មានការបកប្រែ)*

**ឆ៖** ខ្ញុំចង់សួរថា ការបរទេសម្នាក់ សមមិត្ត ល្មុត ម៉េចក៏ថាការបរទេសម៉េចទៅ? ក្រែងអាចជាបកប្រែដឹង? ពីព្រោះថាឯកសារ ខ្ញុំសូមបញ្ជាក់ទីមួយសិនណ៎ា គឺថានេះខ្ញុំមានស៊ីញ៉េមែន ប៉ុន្តែយកទៅឲ្យខ្ញុំមើល។ ខ្ញុំទទួលថាបានឃើញឯកសារនុំងពេលនុំង ហើយខ្ញុំបញ្ជាក់បានតែ រិទ្ធ, គ្រិន, ហើយនិង អន នេះទេ។ ហើយខ្ញុំបញ្ជាក់ថា ខ្ញុំមិនដែលបានឃើញឯកសារពីមុនមកទេ គឺពេលនុំងអ្នកស៊ើបអង្កេតយកទៅឲ្យខ្ញុំមើលទៅ ខ្ញុំថា ខ្ញុំព្រោះស៊ីញ៉េនេះ មិនមែនបានស៊ីញ៉េដោយខ្ញុំទទួលស្គាល់នេះទេ ខ្ញុំដឹង-- គេសួរខ្ញុំថា ស្គាល់នេះស្គាល់នោះទេ? អាហ្នឹងគឺមិនមែនថា ខ្ញុំទៅចូលរួមទេ ខ្ញុំៗមិនបានទៅចូលរួម ខ្ញុំមិនដឹងទេ។ អានេះគឺថាឯកសារទៅបង្ហាញហើយ ពេលទៅស៊ើបអង្កេតនោះឯកសារវាច្រើន។ ដូចខ្ញុំបានជម្រាបអង្គតុលាការពីមុនអ៊ីចឹងគឺថា ខ្លះក៏បានអាន ខ្លះក៏មិនឲ្យអានទេ មើលអ៊ីចឹងទៅ ហើយខ្ញុំនឹកឃើញថា ស្អីពីរឿងអចិន្ត្រៃយ៍ គណៈអចិន្ត្រៃយ៍ ខ្ញុំមិនអាចដឹងបានទេ ហើយខ្ញុំក៏មិនបានចូលរួមដែរ។ នេះហើយពេលដែលយើងសួរៗតែៗ រឿងរិទ្ធ រឿងគ្រិន រឿងអន ហ្នឹង។ ខ្ញុំបញ្ជាក់ពីរបីនាក់ហ្នឹង ហើយត្រង់អ្នកឯទៀតៗ ខ្ញុំមិនអាចបញ្ជាក់បានទេ។

[១១:៥២:៥៤]

ហើយដល់ចំពោះនេះ ខាងក្រោយរឿងកូរ៉េហ្នឹង ខ្ញុំទទួលថាមាន។ នេះក៏ ពេលនោះក៏មិនបានបង្ហាញខ្ញុំដែរណ៎ា ឯកសារនេះ។ ហើយខ្ញុំឆ្ងល់ថា ម៉េចក៏សរសេរដាក់ ការបរទេសម្នាក់ សមមិត្ត ល្មុត។ ខ្ញុំមិនមែននៅក្រសួងការបរទេសណា។ តាមខ្ញុំចាំ ថាខ្ញុំទៅជួយបកប្រែ ព្រោះកូរ៉េ គាត់ចេះភាសាបារាំង ហើយខ្មែរយើងពេលនោះអត់មានអ្នកណាចេះភាសាកូរ៉េអីទេ។ ហើយពួកខាងគាត់ចេះបារាំង។ យើងខ្ញុំទៅជាអ្នកបកប្រែ ខ្ញុំចាំអ៊ីចឹង។ នេះតាមខ្ញុំចាំ បើ-- ប៉ុន្តែខ្ញុំបញ្ជាក់ថាខ្ញុំមិនមែននៅការបរទេសទេ ខ្ញុំនៅខាងធនាគារហ្នឹង គេដោយសារខ្ញុំចេះភាសាបារាំងស្ទាត់គួរសម ក៏មានគណៈប្រតិភូណាចេះបារាំង ខ្ញុំ

ទៅជាអ្នកបកប្រែគេ។ ដូច្នេះធ្វើធនាគារផង បកប្រែផង។ សូមអរគុណ។

[១១:៥៤:០០]

**ស៖** សូមអរគុណច្រើន លោកសាក្សី។ សំណួររបស់ខ្ញុំថាតើលោកនៅចាំឃ្លាទាំងនេះទេ? យើងខ្ញុំទទួលស្គាល់ថាលោកបានបដិសេធថា លោកមិនបានចូលរួមនូវកិច្ចប្រជុំនេះទេ។ យើងខ្ញុំទទួលស្គាល់។ ប៉ុន្តែពីមុននោះ លោកបានជម្រាបមកយើងខ្ញុំថា លោកបានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយនឹងគណៈប្រតិភូចិន ហើយដែលនៅក្នុងឃ្លាទាំងនេះគឺថាមានការពាក់ព័ន្ធ។ ដូច្នេះ នៅក្នុងឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បានចាត់តាំងលោក ដើម្បីឲ្យលោកចូលរួមនៅក្នុងកិច្ចប្រជុំនេះ និងជួយទៅដល់គណៈអចិន្ត្រៃយ៍ លោកនៅចាំទេ?

**ឆ៖** ខ្ញុំចាំដែលចូលជាមួយគណៈប្រតិភូចិនពេលហ្នឹង គឺថាខ្ញុំដូចថាមិនមែនគណៈអចិន្ត្រៃយ៍ទេ គ្រាន់ថាជាក្នុងក្របខ័ណ្ឌក្រសួង-- អំគណៈកម្មាធិការពាណិជ្ជកម្ម។ ហើយខ្ញុំមិនចាំថាមានអ្នកណាខ្លះទេ ច្រើនគ្នា ហើយក្នុងនុំងមានរូបខ្ញុំហ្នឹង ប៉ុន្តែមិនទាន់បង្កើតជាធនាគារអីទេ គ្រាន់តែជាអ្នកយល់ដឹងរឿងកិច្ចការធនាគារ ហើយក៏ចូលរួមទៅ។ ហើយត្រង់គេសរសេរកំណត់ហេតុយ៉ាងម៉េចៗ ខ្ញុំមិនបានដឹងទេ មិនមែនថា ហើយទៅគេធ្វើកំណត់ហេតុអ៊ីចេះៗយកមកឲ្យខ្ញុំដឹង គឺខ្ញុំមិនដឹងទេ។ ហើយខ្ញុំថា នេះគឺថាជាសរុបសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍។ ដូច្នេះ វាខុសគ្នាពីប្រជុំរវាងប្រតិភូបរទេស ជាចិន ឬក៏ប្រតិភូខ្មែរហ្នឹង។ អាហ្នឹងមិនអាចថាគណៈអចិន្ត្រៃយ៍បានទេ។ អានេះ គឺជាចំណងជើងដាក់ថា "របស់គណៈអចិន្ត្រៃយ៍" នេះគឺគេគណៈអចិន្ត្រៃយ៍ គេសម្រេចថាអ្នកណាស្អី? គណៈកម្មាធិការណាមានណាៗ តាមពិត ខ្ញុំអត់ដឹងទេ គណៈកម្មាធិការទាំងអស់ ក្រៅពីពាណិជ្ជកម្ម ខ្ញុំដឹងតែលោក វ៉ាន់ រិទ្ធ មួយ។ ខាងឧស្សាហកម្ម ខ្ញុំស្គាល់លោក អន ហ្នឹងមួយ ហើយកំពង់ផែ ដឹងថាលោក គ្រិន ហ្នឹង ត្រង់អ្នកណាផ្សេងទៀត ខ្ញុំមិនបានដឹង មិនបានអីទេបាទ។

[១១:៥៦:៣៩]

**ស៖** សូមអរគុណលោក។ ក្រៅពីការចូលរួមប្រជុំជាមួយនឹងគណៈប្រតិភូចិន។ តើលោកមានបានចូលរួមប្រជុំជាមួយនឹងគណៈប្រតិភូមកពីបណ្ដាប្រទេសដទៃៗទៀត ដែរឬទេ?

**ឆ៖** អត់មាន ក្នុងឋានៈ ជាអ្នកបកប្រែភាសា។ ដូចជាមកពីប្រទេសខាងអឺរ៉ុបខាងកើតហ្នឹង គាត់ច្រើនតែចេះមក និយាយភាសាបារាំង។ ហើយខ្ញុំក៏ទៅជាជួយបកប្រែ ហើយមិនមែនតែខ្ញុំទេ មានម្នាក់មកពីខាងក្រសួងការបរទេសដែរ គេចេះបារាំងដែរ។ ហើយនៅការបកប្រែនេះ បកម្នាក់ឯងហាត់

ណាស់។ ពេលប្រជុំក៏បក ពេលគេហូបបាយក៏បក រហូតដល់គេទៅគេងសម្រាកតែម្តង។ ដូច្នេះ វាហត់ណាស់ ទាល់តែមានពីរនាក់។ ហើយខ្ញុំច្រើនតែទៅចូលជាអ្នកបកប្រែជាភាសាបារាំងជាមួយនឹងលោកម្នាក់ទៀត ក៏ខ្ញុំមិនដឹងគាត់នៅឯណា នៅឯណីដែរ ឥឡូវនេះ។

[១១:៥៨:០៥]

**ស៖** សូមអរគុណលោក។ តើលោកអាចជួយរំឭកមកដល់យើងខ្ញុំបានទេ ក្រៅពីគណៈប្រតិភូចិនហ្នឹង តើមានគណៈប្រតិភូបណ្តាប្រទេសឈ្មោះអីខ្លះ ដែលបាន-- ដែលលោកបានចូលរួមហ្នឹង ក្រៅពីគណៈប្រតិភូចិននោះ?

**ឆ៖** គឺសម័យនោះ ខ្ញុំចាំគឺថាមានប្រទេសយូហ្គោស្លាវី ហើយប្រទេសអឺរ៉ុបខាងកើតមួយដែរ ដូចជាប្រហែលជា រ៉ូម៉ានី ខ្ញុំមិនច្បាស់ទេបាទ។ ខាងយូហ្គោស្លាវី, រ៉ូម៉ានី ព្រោះអស់លោកខាងហ្នឹង គេមក និយាយតែភាសាបារាំង។

[១១:៥៩:០៣]

**លោក អាប់ឌុលឡាក់ ថាវីក៖**

នៅក្នុងពេលនេះ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញនូវឯកសារពីរបីជូនទៅសាក្សី។ ប្រសិនណាជាលោកប្រធានអនុញ្ញាត គឺយើងខ្ញុំនឹងធ្វើការបង្ហាញជូនទៅដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះ ដល់ពេលសមល្មមសម្រាកដើម្បីពិសាអាហារត្រង់ថ្ងៃហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារត្រង់ថ្ងៃ ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលដល់សាក្សីផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងឲ្យអញ្ជើញគាត់ ជាមួយនឹងមេធាវីប្រឹក្សារបស់គាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅម៉ោងកំណត់គឺម៉ោងមួយ និងសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:០០:០២]

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន លោក នួន ជា សុំការអនុញ្ញាតទៅតាមដានដំណើរការនីតិវិធីនៅបន្ទប់រង់ចាំបំពាក់ប្រព័ន្ធសោតទស្សន៍នៅខាងក្រោយ។ ហើយយើងខ្ញុំបំពេញសំណើសុំនេះរួចរាល់ហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បានស្តាប់សំណើសុំរបស់លោក នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលដំណើរការសវនាការពេញមួយរសៀលនេះ។ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ហើយមេធាវីការពារក្តី បានរៀបចំនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់សម្រាប់ជនជាប់ចោទរួចហើយ។

[១២:០០:៥១]

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំបន្តទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។ បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមបន្ទប់សវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ហើយនៅរសៀលនេះ ឲ្យទុកលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយ-- ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង១៣:៣១ នាទី)*

[១៣:៣១:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការសួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី សតឹម លុត។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** មុនពេលសម្រាកនោះយើងបានពិភាក្សារួចហើយ នូវគណៈកម្មាធិការមួយចំនួន ដូចជាគណៈកម្មាធិការពាណិជ្ជកម្មជាដើម។ ខ្ញុំចង់បន្តទៅទៀត មុននឹងត្រឡប់ទៅរកបញ្ហាដែលនិយាយអំពីរចនាសម្ព័ន្ធនោះ ដែលទាក់ទងទៅនឹងមេដឹកនាំជាន់ខ្ពស់នោះ ខ្ញុំចង់ឲ្យលោកជួយបំភ្លឺបន្ថែមបន្តិចអំពីគណៈកម្មាធិការពាណិជ្ជកម្មខ្លួនឯងនោះ ថាតើគណៈកម្មាធិការនោះនៅកន្លែងណា? ហើយធ្វើការងារអ្វីខ្លះ? ហើយសូមលោកប្រាប់យើងផងដែរ ថាតើគណៈកម្មាធិការពាណិជ្ជកម្មនោះវាស្ថិតនៅកន្លែងណាក្នុងឆ្នាំ១៩៧៦ នៅពេលដែលលោកនៅភ្នំពេញនាពេលនោះ?

[១៣:៣៣:៣៣]

**លោក សតឹម លុត៖**

**ឆ៖** បាទនៅក្នុងឆ្នាំ១៩៧៦ហ្នឹង ពេលដែលខ្ញុំមកពីសហករណ៍មកធ្វើការនៅទីនោះគឺថា ឃើញតែគណៈកម្មាធិការនេះធ្វើការនៅជិតផ្សារចាស់ ឥឡូវកន្លែងឥឡូវនេះគឺជាកន្លែងក្រុមហ៊ុនធានារ៉ាប់រងនៅម្តុំ នៅត្រង់នុ៎ង អគារមួយទៀតខាងមុខហ្នឹង អគារពីរហ្នឹង។ អាខាងមុខហ្នឹងពីមុន-- ហើយឥឡូវដូចប្រគល់ទៅឲ្យខាងអង្គការអីរបស់បារាំង បែប អេ.អេហ្វ.ស៊ី អីអ៊ីចឹង នៅម្តុំហ្នឹង។ ហើយក្រោយមកបានរើមកនៅខាងអគារក្រសួងការពារប្រទេសសព្វថ្ងៃនេះ មកឯនេះ អគារវែងធំហ្នឹង មកហ្នឹង។ មុនដំបូងនៅឯខាងនោះ ហើយបានមក១ឯនេះ។ ដល់ពេលដែល-- អង្កាល់នៅនោះ គឺលោក ឌឿន គាត់នៅជាប្រធានគណៈកម្មាធិការពាណិជ្ជកម្ម។ ដល់លោក វិទ្ធ គាត់ឡើងនោះ គឺរើមកខាងឯណេះ។ ខ្ញុំមិនដឹងជាមូលហេតុអីទេ បានគេរើហ្នឹង។ ខ្ញុំមិនដឹងដែរ។ ប៉ុន្តែកន្លែង អ៊ីចឹងបាទ។

[១៣:៣៥:០០]

**ស៖** នៅពេលដែលលោកនិយាយថា ក្រសួងការពារប្រទេសនោះនៅផ្លូវសហព័ន្ធរុស្ស៊ីនៅភ្នំពេញហ្នឹងដែរឬបាទ?

**ឆ៖** បាទៗ អ៊ីចឹងហើយបាទ។ រាល់ថ្ងៃនេះជាក្រសួងការពារប្រទេស។

**ស៖** សូមអរគុណ។ តាមដែលលោកដឹង ឬក៏លោកចងចាំនោះ ថាតើគណៈកម្មាធិការនោះទំហំប៉ុនណា? បាទនិយាយ-- គណៈកម្មាធិការដែលគេប្រើពេលនោះ គឺបើនិយាយពីទំហំ តើមានទំហំស្មើនឹងក្រសួង ឬក៏មន្ទីរ ឬផ្នែក? តើជាក់ស្តែងនោះ គឺវាទំហំប៉ុនណា? តើមានបុគ្គលិកប៉ុន្មាននៅក្នុងគណៈកម្មាធិការហ្នឹង?

**ឆ៖** ពេលនោះ ខ្ញុំមិនដឹងថានៅក្នុងគណៈកម្មាធិការហ្នឹងមានគ្នាប៉ុន្មាននាក់ ខ្ញុំមិនដឹងទេ។ គ្រាន់តែដឹងថា អានេះជាប្រធានគណៈកម្មាធិការ ហើយត្រង់មានប៉ុន្មាននាក់ទៀត ខ្ញុំមិនបានដឹងដូច បានក្នុងឯកសារនេះទៀត ខ្ញុំអត់ដឹងទេ។ នៅសល់តែលោក-- ដល់មកក្រោយនេះមក គឺមានលោក វ៉ាន់ រិទ្ធ ហ្នឹងក៏ស្គាល់លោក វ៉ាន់ រិទ្ធហ្នឹង។ ហើយគ្រាន់ថាមានប៉ុន្មាននាក់ៗនៅក្នុងនេះ ខ្ញុំមិនបានដឹងទេ។ ហើយខ្ញុំមិនប៊ានជីកសួរគេដែរ ព្រោះមិនមែនជារឿងរបស់ខ្ញុំ។

[១៣:៣៦:៣៦]

**ស៖** គឺខ្ញុំចង់ដឹងអំពីបុគ្គលិក អំពីបុគ្គលិកធម្មតាដែរធ្វើការនៅក្នុងគណៈកម្មាធិការហ្នឹង គឺថាមិនចង់ដឹងតែប្រធាននោះទេ។ ជាពិសេស តើលោកអាចស្មាន ឬក៏ប៉ាន់ប្រមាណថាមានមនុស្សប្រហែលប៉ុន្មាននាក់នៅក្នុងគណៈកម្មាធិការនោះបាទ?

**ឆ៖** អាហ្នឹង និយាយអំពីអ្នកដែលធ្វើការនៅក្នុងហ្នឹង ដូចថាជាបុគ្គលិកធម្មតាហ្នឹង តាមមើលទៅដូចជាមិនហួសពី២០នាក់ទេមើលទៅ មិនហួសពីនុ៎ង។ អាហ្នឹងខាង-- អាហ្នឹងវាមានអ៊ីចេះ មានកាលនុ៎ង ខាងផ្នែកកិច្ចការពាណិជ្ជកម្មបរទេស។ ហើយបើផ្នែកកិច្ចការពាណិជ្ជកម្មក្នុងប្រទេសនោះ។ មានក៏ដោយ ខ្ញុំមិនដឹងជានៅឯណាទេ។ មិនដឹងមានគ្នាប៉ុន្មាននាក់ ខ្ញុំមិនដឹងទេ។ ខ្ញុំមិនដឹងទេបាទ។ នៅក្នុងនុ៎ងមានតែជាផ្នែកខាងពាណិជ្ជកម្មក្រៅប្រទេស។ ហើយមានបុគ្គលិកប៉ុន្មាន? ប្រហែលមិនដល់២០នាក់ហ្នឹង។ ឯក្នុងប្រទេស មិនដឹងជាមានប៉ុន្មានទេ ហើយក៏មិនដឹងជានៅត្រង់ណាដែរ អាចជានៅក្នុងភ្នំពេញហ្នឹង តែមិនដឹងនៅត្រង់ណាទេ ខ្ញុំមិនបានដឹងដែរ។

[១៣:៣៨:០០]

**ស៖** សូមអរគុណ។ លោកបានប្រាប់យើងខ្ញុំពីព្រឹកមិញនេះថា ធនាគារដែលលោកធ្វើការឲ្យ

នោះ គឺជាស្ថាប័នចំណុះឲ្យគណៈកម្មាធិការ ឬក៏ក្រសួងពាណិជ្ជកម្ម។ តើលោកជាផ្នែកមួយនៃក្រសួង ឬក៏មន្ទីរហ្នឹង ឬក៏ធនាគារនុ៎ង ដាច់ដោយឡែកទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ធនាគារមិនមែនជាផ្នែករបស់គណៈកម្មាធិការពាណិជ្ជកម្មទេ គឺវាដោយឡែក។ ដោយឡែកពីគ្នា អត់មានៗឡើងទៅតាមគណៈកម្មាធិការពាណិជ្ជកម្មហ្នឹងទេ គឺនៅដោយឡែក ប៉ុន្តែនៅកន្លែងជិតគ្នា ជាប់គ្នាអ៊ីចឹង ធ្វើជាប់គ្នា ដោយឡែកពីគ្នា។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងអាចបន្តទៅឆ្ងាយពីនេះបន្តិច និយាយពីមន្ទីរ ឬការិយាល័យផ្សេងៗនៃគណៈកម្មាធិការ ឬក៏ក្រសួងផ្សេងៗ។ សូមអភ័យទោស! គឺយើងគ្រាន់តែ យើងទៅសំណួរមួយផ្សេងទៀត មុនទៅដល់នោះ។ តើលោកអាចជម្រាបតុលាការបានទេ ថាតើការងារ បាទ តើការងាររបស់គណៈកម្មាធិការ ឬក៏ក្រសួងពាណិជ្ជកម្មនោះ គេធ្វើការងារអ្វីខ្លះបាទ?

[១៣:៣៩:៤៨]

**ឆ៖** ខ្ញុំមិនអាចជម្រាបល្អិតបានទេ ពីព្រោះការងារនេះ វាជាការងារដោយឡែករបស់គណៈកម្មាធិការពាណិជ្ជកម្ម គ្រាន់តែដឹងថា គេចែកជាពីរផ្នែក អាមួយពាណិជ្ជកម្មក្រៅប្រទេស អាមួយក្នុងប្រទេស ហើយគេចាត់តាំង របៀបម៉េចៗ ក្នុងផ្ទៃក្នុងគេ ខ្ញុំមិនអាចបញ្ជាក់ជូនបានទេ ហើយនៅក្នុងនោះពិតជាថាខ្ញុំនៅកៀកគ្នាមែន ខ្ញុំក៏មិនទៅប៉ាន់ទៅជ្រៀតជ្រែកលួចសួរអ៊ីចេះ សួរអ៊ីចុះពីនេះដែរ។ ជួលកាលគេឲ្យជួយធ្វើត្រង់ណា ធ្វើត្រង់ជួយត្រង់ហ្នឹង បាទ។

**ស៖** ក្នុងឋានៈជាអនុប្រធានធនាគារ បើខ្ញុំនិយាយខុសសូមកែខ្ញុំផង គឺលោកត្រូវធ្វើការងារទាក់ទងទៅនឹងប្រតិបត្តិការហិរញ្ញវត្ថុទាក់ទងនឹងព័ត៌មានហិរញ្ញវត្ថុផ្សេងៗ។ ក្នុងការងាររបស់លោកបែបនោះ តើលោកមានលទ្ធភាពក្នុងសង្កេត ថាតើផ្នែកផ្សេងៗទៀតនៃក្រសួងពាណិជ្ជកម្មធ្វើអ្វីខ្លះ? ដូចជាទាក់ទងទៅនឹងពាណិជ្ជកម្មក្រៅប្រទេសជាដើមហ្នឹង ជាសាខាក្រៅប្រទេសហ្នឹងបាទ?

[១៣:៤១:១៣]

**ឆ៖** សូមបញ្ជាក់ថា នៅទីនោះ វាគ្មានកិច្ចការហិរញ្ញវត្ថុទេ។ យើងចាយលុយ បានវាមានហិរញ្ញវត្ថុ អានេះគ្រាន់តែកត់ឲ្យមើលទៅខាងក្រសួងហ្នឹងគេធ្វើឯកសារ ឧបមាថា គេដាក់អីវ៉ាន់អីចុះកប៉ាល់ទៅគេធ្វើគូសប្លង់គូសអី ធ្វើបញ្ជីអីយកទៅឲ្យកប៉ាល់អ៊ីចឹង។ ធ្វើកិច្ចការអ៊ីចឹង ហើយដល់ពេលមានអីវ៉ាន់មកទៅទទួលរបៀបម៉េច? យកតែបញ្ជីមកចុះអ៊ីចឹង ហើយគេរាយការណ៍ទៅខាងក្រសួង រាយការណ៍ទៅថ្នាក់លើទៅ។ ហើយខ្ញុំមិនៗទៅជ្រាបល្អិតក្នុងការគេទេ ហើយបើគេសួររឿងខ្លះវា

ពាក់ព័ន្ធនឹងរឿងដឹកជញ្ជូនហ្នឹងសួរមក ខ្ញុំចេះត្រង់ណា ខ្ញុំប្រាប់គេត្រង់ហ្នឹង។ ជាពិសេសពេលធ្វើឯកសារ បែបបទអ៊ីចឹង។ ប៉ុណ្ណឹងបាទ។

[១៣:៤២:១៥]

**សៈ** លោកបានប្រាប់យើងថា លោកបានធ្វើជាបញ្ជីទំនិញមួយចំនួននៅពេលដែលត្រូវការទំនិញ ដែលដឹកជញ្ជូន។ ថាតើលោកទទួលព័ត៌មានប្រភេទណា? ហើយតើទំនិញដែលត្រូវដឹកជញ្ជូននោះមាន ប្រភេទទំនិញអ្វីខ្លះនៅលើបញ្ជីទាំងនោះបាទ?

**ឆៈ** បញ្ជីទទួលមានដូចជាថា មានកំណាត់ មានដែក មានអី ស៊ីម៉ង់ត៍ អ៊ីចឹង។ ខ្ញុំមិនចាំអស់ទេ បាទ ប៉ុន្តែមានរបៀបអ៊ីចឹងបាទ។ យកមកឱ្យចុះទៅ ដូចថា ទទួលពីណាប៉ុន្មានយើងចុះក្នុងបញ្ជីយើងទុក ទៅ ហើយកាលណាចេញទៅវិញ ចេញអីទៅខ្លះយើង-- គេឱ្យបញ្ជីមកកត់ក៏កត់ទៅ តែប៉ុណ្ណោះទេ។

**សៈ** សូមអរគុណព័ត៌មានដែលលោកឆ្លើយនេះ មានសារប្រយោជន៍សម្រាប់យើងខ្ញុំ។ នៅក្នុង ការកត់ត្រាទំនិញទាំងអស់នោះដែលត្រូវកត់ត្រា ថាតើទំនិញណាដែលត្រូវនាំចេញជាដើម តើមានអ្នក ផ្សេងណាផ្តល់ព័ត៌មានឱ្យមកលោក ឬក៏ត្រូវសម្រេចថាតើត្រូវនាំចូលទំនិញអ្វី? ត្រូវនាំចេញទំនិញអ្វី? ថាតើបានព័ត៌មាន ឬការសម្រេចនោះមកពីថ្នាក់ណាដែរ?

[១៣:៤៤:០២]

**ឆៈ** ខ្ញុំមិនដឹងថាមកពីថ្នាក់ណាទេ គឺថាមានណែនាំមក មានឯកសារមកខ្ញុំកត់ទៅតាមឯកសារ ដែលគេឱ្យមកហ្នឹង។ ហើយខ្ញុំមិនដឹងជាខាងណាជាអ្នកបញ្ជូនមកជាអីៗខ្ញុំៗមិនបាច់សួរទេបាទ មិន ដែលសួរ គេយកមកធ្វើតាមហ្នឹងទៅបាទ។ អត់មាន--។

**សៈ** សូមអរគុណ។ សំណួរចុងក្រោយនៅប្រធានបទនេះ លោកបានឆ្លើយថា ព័ត៌មាននោះគឺ ថាត្រូវបានកត់ត្រាមួយផ្នែក ហើយទៅតាមអ្វីដែលគេផ្តល់មកឱ្យលោកនូវព័ត៌មាននៅបញ្ជី។ លោកបាន និយាយខាងដើមនោះថា លោកក៏គេនាំលោកមកភ្នំពេញវិញដោយសារលោកមានជំនាញខាងធនាគារ ក្នុងឋានៈជាអនុប្រធានធនាគារកាលនោះ តើលោកប្រើជំនាញរបស់លោកដែរឬទេ? ឬក៏មិនបានប្រើ ជំនាញខាងធនាគារ ដើម្បីធ្វើប្រតិបត្តិការទាក់ទងនឹងទំនិញនាំចេញនាំចូលជាដើមហ្នឹង?

**ឆៈ** បាទ ខ្ញុំអត់បានប្រើជំនាញទាំងអស់នោះទេ។

**សៈ** ឥឡូវនេះ ខ្ញុំសូមសួរលោកផងដែរអំពីមន្ទីរផ្សេងៗទៀត ដែលអាចពាក់ព័ន្ធទៅនឹងការងារ មួយចំនួនដែលលោកជួយធ្វើការងារនោះ។ ថ្ងៃនេះលោកបានប្រាប់ថា លោកបានជួបសមមិត្ត គ្រិន នៅ

ពេលដែលលោកទៅកំពង់សោម។ តាមពិត យើងបានឃើញព្រឹកមិញនេះ គឺថាសមមិត្ត គ្រិន ហើយលោកបានឆ្លើយនោះ វាស៊ីសង្វាក់គ្នា គេបានតែងតាំង គ្រិន នោះជាប្រធាននៃកំពង់ផែ នៃគណៈកម្មាធិការកំពង់ផែសីហនុ។ តើកំពង់ផែនោះនៅក្រោមក្រសួងពាណិជ្ជកម្ម ឬក៏កំពង់ផែនោះគឺគ្រាន់តែសហការជាមួយក្រសួងពាណិជ្ជកម្មទេ?

[១៣:៤៦:៣៣]

**ផ៖** ខ្ញុំមិនដឹងថា កំពង់ផែនៅក្រោមនរណាទេ ខ្ញុំមិនបានដឹងទេបាទ មិនបានដឹងទេ។ ថាតែធ្វើការទៅវាមានពាណិជ្ជ ហើយនិងកំពង់ផែវាត្រូវទាក់ទងគ្នា ព្រោះនាំទំនិញចេញចូល។ តែត្រង់ថាកំពង់ផែហ្នឹងនៅក្រោមពាណិជ្ជកម្ម ឬនៅ មិននៅក្រោម ឬនៅក្រោមអ្នកណាទៀត ខាងខ្ញុំមិនដឹង មិនដឹងទេបាទ។

**ស៖** សូមអរគុណ។ លោកបានជម្រាបយើងអំពីការនាំចេញនិងនាំចូល។ ថាតើការនាំចេញនាំចូលតាមរយៈកំពង់ផែ ឬក៏បញ្ជូនចេញពីប្រទេស ឬចូលប្រទេសតាមវិធីណា ក្រៅពីកំពង់ផែដែរឬទេ?

**ផ៖** ខ្ញុំមិនបានដឹងថាមានកន្លែងណានាំចេញ នាំចូលទៀតដែរទេ។ ខ្ញុំដឹងថា អាចត្រឹមវា-- នាំចេញនៅតាមកំពង់ផែហ្នឹង ត្រង់ថាមានច្រកផ្សេងទៀត ឬមិនមាន ខ្ញុំមិនអាចបញ្ជាក់ជូនបានទេបាទ។

**ស៖** ឥឡូវនេះ ផ្អែកតាមការយល់ដឹងរបស់លោក គឺថាការបង្កើតបញ្ជីទំនិញ។ តើលោកអាចជម្រាបតុលាការបានទេថា តើទំនិញអ្វីខ្លះ ដែលសម័យនោះគេនាំចេញនោះ?

[១៣:៤៨:៣៣]

**ផ៖** សូមបញ្ជាក់ថា ការនាំចេញហ្នឹង គិតគូររឿងហ្នឹង គឺជាភារកិច្ចរបស់សហ-- ជាគណៈកម្មាធិការកិច្ចការពាណិជ្ជកម្មផ្នែកក្រៅប្រទេស។ គេនុំង គេជាអ្នករិះរកមុខទំនិញអី នាំចេញបាន ចេញទៅឯណាមកឯណា។ ប៉ុន្តែទាំងអស់ហ្នឹងអត់មាន គ្មានធនាគារទៅចូលឡុកឡំទេ។ អត់ទេ អត់មានបញ្ជីអីខាងខ្ញុំ អត់មានទេ។ ប៉ុន្តែខ្ញុំមើលទៅដឹងថាដូចជាមាន ស្រូវ អង្ករ ផលិតផលដូចជា សណ្តែក ដូចជាអីចឹង ផលិតផលកសិកម្មហ្នឹង។ ប៉ុន្តែទាំងអស់ហ្នឹងគ្មានបញ្ជីអីនៅក្នុងធនាគារទេ។ ហើយតាមខ្ញុំមើលទៅ គឺថាគណៈកម្មាធិការពាណិជ្ជកម្មផ្នែកក្រៅប្រទេសហ្នឹង គេទាក់ទងខាងណាៗ ទៅយ៉ាងម៉េច មិនដឹងទេ។ ហើយដែលខ្ញុំជួយគេ គ្រាន់ថាធ្វើបែបបទដូចថា ឯកសារនាំចេញត្រូវមានអីៗ? ធ្វើឲ្យកប៉ាល់តែប៉ុណ្ណឹងទេ។ ហើយបញ្ជីម្រយអី បញ្ជីប៉ុន្មានៗ គឺថាខ្ញុំមិនបានដឹងទេ ព្រោះអត់មានឆ្លងតាមធនាគារ។

[១៣:៤៩:៥២]

សូមបន្ថែមបន្តិចបាទ ធម្មតាគឺថាបើយើង-- តាមធម្មតា គឺថាកាលណានាំចេញ គេត្រូវលិខិតឥណទានឆ្លងតាមធនាគារ-- អ៎ នាំចូល ចេញក៏មានឯកសារតាមធនាគារនាំមុខ។ នេះគឺគ្មានទេ ប៉ុន្តែគឺក្រសួង ក្រសួងផ្នែកនុ៎ង ហើយគេទាក់ទងផ្ទាល់ជាមួយភ្ញៀវខាងក្រៅទៅ ហើយគេនិយាយគ្នាទូទាត់ម៉េចខាងក្រៅទៅ ខ្ញុំក៏មិនដឹងដែរ អត់មានធនាគារទេ។ ព្រោះធនាគារខ្ញុំ វាគ្មានគណនីអីឯណានៅក្រៅផង មាននៅណាផង ខ្ញុំមិនដឹង ធនាគារគ្មានលុយផង។

**ស៖** លោក សគីម ល្អុត ប្រសិនបើផ្នែកពាណិជ្ជកម្មក្រៅប្រទេសធ្វើការងារទាំងនេះ ដូចជាលិខិតឥណទាន ហើយធនាគារមិនមានលុយកាក់នោះទេ ថាតើគោលបំណងនៃធនាគារនោះធ្វើអ្វីបាទ?

[១៣:៥១:១៧]

**ឆ៖** គឺគ្រាន់តែថា ចំពោះករណីខ្លះធ្វើឲ្យមានឯកសារដូចគេ ដូចឯងអ៊ីចឹងទៅ។ តែដល់រឿងទូទាត់លុយកាក់ទៅឲ្យគេ ឬយ៉ាងម៉េចៗ អាហ្នឹងខាងផ្នែកពាណិជ្ជកម្មហ្នឹង ហើយនិងថ្នាក់លើដោះស្រាយយ៉ាងម៉េច ខ្ញុំក៏មិនដឹងដែរ អត់ដឹងទេ។ ដូចខ្ញុំជម្រាបពីលើកមុនមកអ៊ីចឹង គឺថាធនាគារមានឈ្មោះតែថាធនាគារ អ៊ីចឹងតែថាវាមិនពេញអង្គទេ។ មានមនុស្សម្នាក់ធ្វើធនាគារយ៉ាងម៉េច? ខ្ញុំមិនចេះគ្រប់សព្វឯណា។ ហ្នឹងសូមជម្រាបខ្លីតែប៉ុណ្ណឹងបាទ។

**ស៖** តាមពិតខ្ញុំយល់ហើយ។ ខ្ញុំសូមបង្ហាញជូនលោកនូវសេចក្ដីដកស្រង់នូវចម្លើយរបស់លោកកាលពីមុន។ ហើយទាក់ទងទៅតែនឹងចំណុចមួយដែលយើងចង់បញ្ជាក់ថា ចំណុចមួយចំនួនដែលថាមានចំណុចមិនខ្វែងគ្នា។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវបទសម្ភាសន៍ទីមួយ របស់សាក្សីរូបនេះជាមួយសហចៅក្រមស៊ើបអង្កេត។ ឯកសារ D279/6 បាទ D279/6 ផ្នែកមួយនៃឯកសារនេះដែលខ្ញុំចង់បង្ហាញជូនសាក្សីនោះ គឺសំណួរ និងចម្លើយ៤៤ និង៤៥។

[១៣:៥៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ គ្រាន់តែជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ ត្រង់ចំណុចដែលសហព្រះរាជអាជ្ញាមានបំណងសួរដេញដោលដល់សាក្សី។

[១៣:៥៣:៥៥]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឥឡូវនេះដើម្បីផ្តល់ជាបរិបទមួយចំនួន លោក សគឹម ល្អុត ខ្ញុំនឹងចាប់ផ្តើមនូវសំណួរ និងចម្លើយ៣៩។ គ្រាន់តែបំភ្លឺឲ្យបានច្បាស់ ជាបញ្ហាបច្ចេកទេសតែប៉ុណ្ណោះទេ។ ហើយតាមពិតយើងនិយាយអំពីបញ្ហាដែលកើតឡើងយូរណាស់មកហើយ។ ហើយទាក់ទងទៅនឹងរចនាសម្ព័ន្ធនោះវាស្មុគស្មាញផង។ សំណួរទី៣៩ បាទ ៣៩ បាទ ៨, ៣៩ ខ្ញុំផ្តោះបន្តិច ចំណុច៣៩ ដែលមានសេចក្តីយោងទៅរក ហែម។

ចំណុចដែលខ្ញុំចាប់អារម្មណ៍នោះ គឺថាប្រយោគទីពីរនៃលេខ ៨, ៣៩ ដែលដំបូងនោះលោកនិយាយថា គឺថានៅពេលដែលលោកមកដល់ភ្នំពេញភ្លាម៖ "ជាដំបូងគេមិនឲ្យខ្ញុំធ្វើអ្វីទេ រហូតទាល់តែមានការជួបជាមួយគណៈប្រតិភូចិន។ បន្ទាប់ពីប្រជុំជាមួយនោះមកគឺថា គណៈប្រតិភូចិនដើម្បីណែនាំឲ្យបង្កើតធនាគារ ដើម្បីសម្រួលដល់ការនាំចេញ។ បន្ទាប់មក គឺគេបង្កើតអង្គភាពមួយដែលមានឈ្មោះថាធនាគារហ្នឹង ហើយនិយាយថា ធនាគារក្រៅប្រទេសរបស់កម្ពុជាដែលខ្ញុំធ្វើការនោះ។ ខ្ញុំសូមអភ័យទោស ដែលថាខ្ញុំនឹងបញ្ចប់សេចក្តីដកស្រង់នេះ ធនាគារនោះស្ថិតនៅក្រោមគណៈកម្មាធិការពាណិជ្ជកម្ម ហើយខ្ញុំមិនដឹងទេថា អ្នកណាជាអ្នកបញ្ជាផ្ទាល់នៅពីលើនោះទេ។ ឥឡូវនេះ ខ្ញុំចង់ឈានទៅមុខបន្តិចទៀត ទាក់ទងទៅនឹងសំណួរនិងចម្លើយ៤៦។ សំណួរ៖ តាមបើសិនជាខ្ញុំយល់ ដឹងរបស់យើងហ្នឹង ដើម្បីបង្កើត ថាបើសិនជាចិនផ្តល់ឲ្យលុយជំនួយចំនួន១៤០លាន ដើម្បីឲ្យធនាគារនោះ បើតាមដែលខ្ញុំដឹងគឺ ខ្ញុំមិនដឹងចំនួនច្បាស់លាស់ទេ ប៉ុន្តែខ្ញុំជារួមនោះគឺពាណិជ្ជកម្មក្រៅប្រទេស យើងត្រូវតែមានធនាគារ។ តើនេះជាសេចក្តីសង្ខេបត្រឹមត្រូវពីអ្វីដែលលោកឆ្លើយប្រាប់ទៅអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតដែរឬទេ?

[១៣:៥៦:៣៥]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** បាទអ៊ីចឹងសូមលោកសាក្សី រង់ចាំដល់មីក្រូហ្វូនមានភ្លើងក្រហមសិនបាទ។

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** តើផ្នែកដែលខ្ញុំបានអានជូនហ្នឹង គឺត្រឹមត្រូវដែរឬទេ តាមលោកចងចាំ? បាទ ជាពិសេសគឺចម្លើយ៤៦ បាទ។

**ឆ៖** ចម្លើយហ្នឹង ខ្ញុំបានឆ្លើយអ៊ីចឹងមែន ប៉ុន្តែដល់ខ្ញុំមកមើលឡើងវិញអ៊ីចឹង ខ្ញុំឆ្លើយហ្នឹងដូចជាកំបុតបន្តិច ដូចជាមិនអស់សេចក្តី។ ហេតុអីបានពេលនុ៎ងឆ្លើយអ៊ីចឹង? ព្រោះថា សំណួរហួរហែនិយាយពីលើមកល្មមនោះ ឱ្យទៅអ៊ីចឹង ថាសរុបទៅវាត្រូវតែអ៊ីចឹងតាមយល់ណា ហើយខ្ញុំក៏ជម្រាបត្រង់ គឺពេលនុ៎ងវា ហត់ហេវផង ឯកសារច្រើន ហើយវាវិលមុខវិលអីក៏ថា អើវាអ៊ីចឹងហើយ អាចអ៊ីចឹងហើយ ប៉ុន្តែខ្ញុំបានបញ្ជាក់ថារឿងទឹកលុយ ខ្ញុំមិនដឹងទេ អានេះខ្ញុំដាក់។ ទឹកលុយខ្ញុំមិនដឹងទេ ហើយចំពោះដែលថា អ៊ីចឹងមែននេះ ខ្ញុំត្រូវឆ្លើយថាវាអាចអ៊ីចឹងមែន ខ្ញុំគ្មានឯកសារអីបញ្ជាក់ថា ចិនឱ្យប៉ុណ្ណេះខ្ចីប៉ុណ្ណេះ គឺគ្មានទេ។ ហ្នឹងខ្ញុំថា អ៊ីចឹងមែនគឺថា ដែលនិយាយគ្នាពីលើមកហួរហែមក វាអាចថា ចិនហ្នឹង គាត់ជួយឬគាត់ផ្តល់អី លុយប៉ុណ្ណេះប៉ុណ្ណោះ ធ្វើធនាគារហ្នឹង។ ប៉ុន្តែខ្ញុំបញ្ជាក់ថា ខ្ញុំមិនដឹង មិនដែលបានដឹងថាលុយប៉ុន្មាន មកពីណាច្បាស់លាស់ខ្ញុំមិនដឹងដែរ។ ដូចនៅក្នុង-- ខ្ញុំឆ្លើយហ្នឹងវាដូចវាកំបុតបន្តិច។ ហើយខ្ញុំសូមកែសម្រួលឡើងវិញគឺថា វាអាចទៅអ៊ីចឹង ពីព្រោះហួរហែមកវាអ៊ីចឹង ប៉ុន្តែត្រង់ថា ខ្ញុំមានអីសំអាងគឺគ្មានដែរ។ ឧបមាខ្ញុំថាទៅ ចិនគេថា អេ៎ះ មានអីសំអាងថាគេ-- អាហ្នឹងគឺថា ខ្ញុំៗសូមកែត្រង់ហ្នឹងពីពេលជួបលោកខាងអ្នកអង្កេតលើកណា ខ្ញុំបានស្នើឱ្យចំណុចហ្នឹងដែរ ខ្ញុំចាប់អារម្មណ៍។ ហើយអាចសួរខ្ញុំថា ចុះពេលនោះម៉េចក៏ឆ្លើយអ៊ីចឹង ខ្ញុំថា ពេលសួរចម្លើយ គឺថា វាទៅហត់ហេវណា ហើយក៏ឆ្លើយដូចថា ចាក់បណ្តោយបន្តិចទៅ ដល់មកមើលឡើងវិញ អ្ហ៎! ខ្ញុំមិនត្រូវឆ្លើយអ៊ីចឹងទេ។

[១៣:៥៩:៤៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំត្រូវការឱ្យមីក្រូហ្វូនមានភ្លើងក្រហមបាទ។ បាទ សូមខាងអង្គភាពជួយបាទ។

**លោក សគីម ល្មុត៖**

**ឆ៖** លោកប្រធាន ខ្ញុំបាទសូមតបន្តរឿងហ្នឹងទៀតគឺថា តាមពិត ខ្ញុំមិនដែលបានឃើញឯកសារស្អីដែលថាចិនគាត់ជួយប៉ុណ្ណេះ គាត់ឱ្យខ្ចីប៉ុណ្ណោះ គឺជាអ្នកស៊ើបអង្កេត គាត់វាអ៊ីចឹង វាគួរអ៊ីចឹងទេ? អ៊ីចឹងខ្ញុំៗថា វាត្រូវតែអាចអ៊ីចឹងដែរ ប៉ុន្តែខ្ញុំបញ្ជាក់ថារឿងទឹកលុយខ្ញុំមិនដឹងទេ។ ខ្ញុំបានបញ្ជាក់នៅក្នុងចម្លើយនុ៎ង។ នៅឆ្លើយកំបុតត្រង់ថាវាអ៊ីចឹងដែរ។ តាមពិតត្រូវសួរថាប្រហែលៗជាអ៊ីចឹង។ ប៉ុន្តែខ្ញុំគ្មានឯកសារអី ហើយអារឿងលុយកាក់ហ្នឹង គឺតាមខ្ញុំគិតទៅវាថ្នាក់លើទេដែលគិតគូរ លុយពីណា ខ្ចីពីណាបានពីណា បានខ្ញុំមិនដឹងទេបាទ។ ហើយនេះសូមបំភ្លឺប៉ុណ្ណឹង សូមអរគុណ។

[១៤:០០:៥២]

**ស៖** សូមអរគុណ។ យើងមិនចាប់អារម្មណ៍ទៅលើទឹកប្រាក់ ចំនួនទឹកប្រាក់ជាក់លាក់នោះទេ លោក សគីម ល្មុត ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់សួរបំភ្លឺអំពីតួនាទីរបស់ធនាគារនោះតែប៉ុណ្ណោះ។ យើងគ្រាន់តែចង់ឱ្យលោកមើលឯកសារមួយ តើលោកចាំដែរឬទេ?

[១៤:០១:២១]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំចង់បង្ហាញឯកសារមួយដល់សាក្សី គឺឯកសារដីការបញ្ជូនរឿងទៅស៊ើបសួរ 21.93 គឺឯកសារលេខ 21.93។

លេខពាក់ព័ន្ធនៃឯកសារនេះ គឺឯកសារបង្កើតឡើងដោយក្រសួងពាណិជ្ជកម្ម ដែលក្នុងនេះយោងទៅរកសាក្សី។ ដូច្នេះហើយខ្ញុំចង់សួរបំភ្លឺបញ្ជាក់ ទៅលើចំណុចបញ្ហាហិរញ្ញវត្ថុមួយចំណុច បន្ទាប់មកខ្ញុំនឹងបន្តទៅមុខ។ ខ្ញុំចង់បង្ហាញជូនសាក្សីនេះនូវឯកសារលេខ 21.93។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ ពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្មុត ខ្ញុំមិនមានបំណងចង់ធ្វើការសួរដេញដោល ទៅលើការចងចាំរបស់លោកនោះទេ ការដែលគេសម្ភាសលោកនោះ អ្វីដែលលោកឆ្លើយគឺ ស្របទៅនឹងកំណត់ហេតុនានារួចមកហើយ។ ឯកសារនេះនៅត្រង់ទំព័រខាងមុខ ទំព័រដំបូង គឺខ្ញុំសូមអនុញ្ញាតបញ្ចាំងលើអេក្រង់ផង ដើម្បីឱ្យខ្ញុំបានមើល និងអស់លោក លោកស្រីបានមើល។

[១៤:០៣:២១]

ហើយខ្ញុំសូមអនុញ្ញាតឱ្យខាងសោតទស្សន៍ធ្វើការបញ្ចាំងឯកសារនេះផងដែរ។ សូមអរគុណច្រើន។ នៅត្រង់ទំព័រដំបូងត្រង់ចំណងជើងខាងឆ្វេង សរសេរថា កម្ពុជាប្រជាធិបតេយ្យ ក្រសួងពាណិជ្ជកម្ម។ ក្រោយបន្ទាប់មកនៅកណ្តាល ការប្រើប្រាស់ឥណទាន ១៤០លានយ័ន គិតត្រឹមថ្ងៃ១៥ កុម្ភៈ ១៩៧៨។ ហើយនៅពេលដែលយើងទៅដល់ទំព័រចុងក្រោយតែម្តងទៅ។ សូមឱ្យចូលទៅដល់ទំព័រចុងក្រោយតែម្តង គឺទំព័រមួយទំព័រទៀត គឺទំព័រចុងក្រោយ បាទ។ សូមមើលលោក ល្មុត! បាទ ចុះមួយទំព័រទៀត សូមចុះមួយទំព័រទៀត។ យើងឃើញមានកំណត់ចំណារ មានចំណារ ហើយវាពាក់ព័ន្ធទៅនឹងការ

ចំណាយ។ តើខ្ញុំចង់សួរចំណុចនេះបន្តិចបន្តួច ជូនបង ល្មុត។ តើបង ល្មុត នេះ គឺលោកមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៤:០៤:៣៣]

**ស៖** សូមឲ្យលោកចាំមីក្រូហ្វូនចេញភ្លើងសិនចាំលោកនិយាយ។

**ឆ៖** ល្មុត ហ្នឹងគឺខ្ញុំហ្នឹងហើយបាទ។

**ស៖** សូមអរគុណច្រើន។ យើងខ្ញុំមិនត្រូវការបង្ហាញឯកសារនេះបន្តទៀតទេ ខ្ញុំគ្រាន់តែចង់សួរការចងចាំរបស់លោក អ្វីដែលលោកចងចាំគឺត្រឹមត្រូវដែរឬទេប៉ុណ្ណោះ? នៅពេលនេះ ខ្ញុំអធ្យាស្រ័យដោយសារតែខ្ញុំរំលងចំណុចពាក់ព័ន្ធមួយ។ ដូច្នេះហើយសូមបញ្ចាំងឯកសារនេះសាជាថ្មីបន្តិចវិញបាទ។

លោក សគីម ល្មុត ប្រសិនបើលោកមើលនៅខាងឆ្វេង មុខខាងលើខាងឆ្វេង យើងមានឃើញចំណារនៅខាងឆ្វេងខាងលើ។ គឺខាងឆ្វេង សូមឲ្យលោកមើលទំព័រដំបូង ទំព័រមុខដែលបញ្ឡៀងបន្តិចខាងឆ្វេងខាងលើ។ ហើយសូមអនុញ្ញាតបញ្ចាំងលើអេក្រង់ផង។ សូមឲ្យសោតទស្សន៍ធ្វើការបញ្ចាំងឯកសារនេះនៅលើអេក្រង់ផង គឺឯកសារលេខ 21.93។ សូមអរគុណ។

លោក ល្មុត នឹងអានការបកប្រែទៅជាភាសាអង់គ្លេស ហើយប្រហែលជាវាស៊ីសង្វាក់ទៅហ្នឹងអ្វីដែលលោកកំពុងតែអាននេះ គឺអក្សរសរសេរដោយដៃ គឺចំណារ "បានផ្ញើជូន បងហែម, វន ហើយ។ ហើយមានចុះហត្ថលេខា ថ្ងៃ១៩/២"។ តើលោកមើលទៅឃើញដូចអ្វីដែលខ្ញុំអានទេ?

**ឆ៖** បាទ ឃើញបាទៗ។

**ស៖** ផ្អែកតាមបទពិសោធន៍របស់លោកនាពេលនោះ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ហេតុអ្វីឯកសារប្រភេទនេះ ចាំបាច់-- ហេតុអ្វីចាំបាច់ផ្ញើជូនទៅ បងហែម និងបងវន ធ្វើអ្វី?

[១៤:០៧:០៤]

**ឆ៖** នេះ ខ្ញុំមិនដឹងហេតុផលអីទេ នេះគឺជាអក្សរ គឺថាលោក វ៉ាន់ រិទ្ធ គាត់ផ្ញើជូនទៅបងហែម និងបងវន។ ហើយទៅប្រហែលសម្រាប់ជូនជាដំណឹងហើយ ខ្ញុំក៏-- គាត់អ្នកផ្តើមគំនិតបញ្ជូនទៅ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសោកស្តាយដែលបានកាត់ផ្តាច់ លោកសហព្រះរាជអាជ្ញា។ ខ្ញុំ

មាន-- ខ្ញុំជំទាស់នឹងរបៀបចោទសំណួរទាក់ទងនឹងអត្ថបទនេះ។ សាក្សីបានឆ្លើយនឹងសំណួរហើយ ក៏ប៉ុន្តែដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការពិភាក្សាគ្នា សំណួរទីមួយដែលត្រូវចោទសួរនោះ គឺថាត្រូវសួរថា តើសាក្សីនេះ ស្គាល់ឯកសារនេះពីមុនមកហើយឬនៅ? ពីព្រោះថាជាទូទៅនោះ គាត់ សហព្រះរាជអាជ្ញាចង់ឲ្យគាត់ឆ្លើយព្រាវ ប៉ុន្តែ ឬក៏សន្មត មិនមែនឈរលើមូលដ្ឋាននៃការដែលថាគាត់បានឃើញ ឬក៏ដឹងពីមុនមកទេ។ អ៊ីចឹង ដើម្បីឲ្យច្បាស់លាស់នោះ ម្តង ជាថ្មីម្តងទៀត គឺថាធ្វើយ៉ាងណាកុំឲ្យសាក្សីហ្នឹង-- យើងកុំនាំសាក្សីឲ្យឆ្លើយព្រាវៗ ធ្វើការសន្និដ្ឋាន។

[១៤:០៨:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ប៉ុន្តែមេធាវី គប្បីលើកការជំទាស់របស់ខ្លួនឲ្យបានទាន់ពេល តាំងពីដើមដំបូងនៃការដាក់ឯកសារ។ យើងបង្អង់មើលដែរ នៅក្នុងកិច្ចដំណើរពិភាក្សានេះ ថាតើមានសេចក្តីជំទាស់ពីភាគីណាដែរឬទេ មុននឹងសម្រេចឲ្យអនុញ្ញាតឲ្យដាក់ឯកសារនេះ ដើម្បីដេញដោល ប៉ុន្តែមិនមានទេ។ ឆ្លៀងឱកាសនៅពេលដែលសួរចប់ ទើបលោកស្រីលើកចុងក្រោយគេ លើកបែបនេះ គេហៅថា លើកយកល្អ។ គ្រាន់តែជាលម្អនូវសកម្មភាពរបស់ខ្លួនតែប៉ុណ្ណោះ មិនមែនគោលបំណងដើម្បីស្វែងរកការពិតទេ។

[១៤:០៩:៤០]

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា! ហើយសូមរំឭកម្តងទៀត សាជាថ្មី ថាតំណាងសហព្រះរាជអាជ្ញាត្រូវរៀបចំនូវឯកសារ ដែលខ្លួនមានបំណងលើកយកមកដាក់ដេញដោលចំពោះសាក្សី ឬអ្នកជំនាញ ទៅថ្ងៃមុខ ត្រូវរៀបរយឲ្យបានច្បាស់លាស់ ហើយស្នើសុំបង្ហាញអត្តសញ្ញាណឯកសារ និងបញ្ជាក់ចំពោះសាក្សី ឬអ្នកជំនាញជាមុន ថាតើបញ្ហាឯកសារនេះខ្លួនស្គាល់ ឬមិនស្គាល់ជាមុនសិន។ មិនអាចកេងចំណេញដោយសារស្ថានភាពនៃការលើកយកឯកសារមកដេញដោលដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលយើងបានកំណត់ និងអនុវត្តច្រើនថ្ងៃ ច្រើនខែ មកហើយ ពាក់ព័ន្ធនឹងបញ្ហាឯកសារនេះ។ យើងកត់សម្គាល់ឃើញថា ហាក់ដូចជាកើតឡើងនៅដដែលៗទេ។ វិលវល់គឺនៅតែរឿងដដែលៗទេ មិនមានការកែប្រែអ្វីឲ្យរីកចម្រើនជាងមុនទាល់តែសោះ។

សូមឲ្យលោកគិតគូរពីបញ្ហានេះឲ្យបានស៊ីជម្រៅ ហើយនិងឲ្យបានហ្មត់ចត់ជាងមុន។

[១៤:១០:៥៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ អ្វីដែលខ្ញុំធ្វើនេះគឺផ្អែកទៅតាមអ្វីដែលសាក្សីគាត់ស្គាល់ឯកសារនេះរួចទៅហើយ។ យើងខ្ញុំសូមបន្តទៅមុខទៀត។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** តើលោកសាក្សីចង់លើកយោបល់អ្វីដែរលោក?

**លោក សគឹម ល្មុត៖**

**ឆ៖** សូមមគោរពលោកប្រធាន ហើយនិងគឺថា ចំពោះឯកសារនេះ ពេលដែលលោកទៅស៊ើបអង្កេតមុនមកគឺថា មានឯកសារច្រើនណាស់ដែលយកឱ្យខ្ញុំមើល។ ខ្លះក៏ឱ្យអាន ដូចខ្ញុំនិយាយដដែលៗឱ្យអាន ឬឱ្យថា-- ហើយដែលខ្ញុំៗឃើញឯកសារនេះមក ខ្ញុំ ឬក៏ជាខ្ញុំមិនមានការចងចាំ ឬក៏ម៉េច ខ្ញុំមិនប្រកែកនូវការឯកសារហ្នឹងថាវាក្លែងក្លាយ មិនក្លែងក្លាយទេ ខ្ញុំមិនប្រកែកអ៊ីចឹងទេ។ គឺថា ខ្ញុំ ដូចជាៗពេលនុ៎ងដូចមិនបានបង្ហាញខ្ញុំអាហ្នឹង ហើយខ្ញុំឆ្ងល់ដែរ សរសេរខាងក្រោយនេះ! ដាក់ជូន បងល្មុតមិនដឹងស៊ីញ៉េនរណាទេ។ ហើយដាក់ជាអង់គ្លេស ជូនបងល្មុត *ស៊ីញ៉ាផ័រ*។ មិនដឹងជាស្អីទេនេះ។ ខ្ញុំមិនដឹងជាអក្សរនរណាអី ហើយខ្ញុំខ្មែរម៉េចក៏-- បើសិនអ៊ីចឹងម៉េចក៏មិនសរសេរទៅដាក់ខ្មែរ ម៉េចដាក់ព្រួញអ៊ីចឹង ទៅជូន បងល្មុត ទៀត។ ត្រង់ហ្នឹងខ្ញុំដូចជាធ្វើឱ្យខ្ញុំឆ្ងល់ដែរ ខ្ញុំមិន-- នេះអាហ្នឹង។ ត្រង់នេះ ខ្ញុំមិនប្រកែករឿងការពិត មិនពិតទេ ព្រោះថាលោក វ៉ាន់ រិទ្ធ គាត់រាយការណ៍ទៅៗថ្នាក់លើ ដូចថាលោកបងហែម និងលោក វន ហើយលុយចាយទៅឯណា សល់ប៉ុន្មានៗ វាអាចអ៊ីចឹង។ ប៉ុន្តែក្នុងធនាគារគ្មានកត់ត្រាអីទេ។ សូមទោសលោកប្រធាន។ ឱ្យបានតែឱ្យមក ទុកមក។

[១៤:១២:៥៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវចាំស្តាប់ចំណុចសាកសួរបន្តទៅ ហើយចំណុចមានបញ្ហាដែលលោកកត់សម្គាល់អំមិញហ្នឹងខាងតំណាងសហព្រះរាជអាជ្ញាមិនបានតាំងសំណួរទេ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំពិតជាមានបំណងចង់សួរបញ្ជាក់ទៅលើចំណុចដែលគេសរសេរយោងនោះ។ ការសរសេរជាភាសាអង់គ្លេសនោះ គឺខ្ញុំសរសេរខ្លួនឯងសម្រាប់ឱ្យខ្ញុំយល់តែប៉ុណ្ណោះនោះទេ។ ខ្ញុំសូមបន្តទៅមុខទៀត។

[១៤:១៣:៣៥]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** រហូតមកដល់ពេលនេះ គឺយើងបានពិភាក្សាទៅលើការងាររបស់គណៈកម្មាធិការពាណិជ្ជកម្ម និងក្រសួងពាណិជ្ជកម្ម និងសាខារបស់ក្រសួងពាណិជ្ជកម្ម និងអ្វីដែលលោកបានបញ្ជាក់។ លោកបានលើកឡើងរួចមកហើយថា នៅកំពង់សោម ផែនៅកំពង់សោម គឺមានការពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនអីវ៉ាន់ចេញទៅក្រៅប្រទេស។ ក្រៅពីមន្ទីរទាំងអស់នេះ តើមានមន្ទីរណាផ្សេងទៀតដែរឬទេ តាមអ្វីដែលលោកចាំ តើមានមន្ទីរណាផ្សេង ដែលពាក់ព័ន្ធទៅនឹងសកម្មភាពពាណិជ្ជកម្មអន្តរជាតិ បានន័យថា ការនាំចេញ និងនាំចូលទៅក្រៅប្រទេស ចូលមកប្រទេសជាមួយនឹងកម្ពុជាប្រធិបតេយ្យ តើមានមន្ទីរណាដែលពាក់ព័ន្ធទៅលើការងារនេះដែរឬទេ?

**លោក សគីម ល្មុត៖**

**ឆ៖** ទេបាទ ខ្ញុំមិនដឹងទេបាទ។

**ប្រធានអង្គជំនុំ៖**

សាក្សី សូមរំឭកម្តងទៀត ញឹកញាប់ពេកហើយ នៅពេលដែលលោកនិយាយដោយក្បាលមីក្រូមិនទាន់ប្រតិបត្តិការ។ សូមរៀបចំបញ្ហានេះឡើងវិញ។ បើពុំដូច្នោះទេ កើតបញ្ហានីតិវិធីវាអាចយឺតហើយនិងពិបាកនិងកត់ត្រា ពីព្រោះលោកនិយាយម្តងហើយ ជួនកាលអត់បាននិយាយថែមទៀតទេ ហើយអត់បានបកប្រែទេ។ អ៊ីចឹងវាលទ្ធផលនៃកិច្ចពិភាក្សាដេញនេះ វាទៅជាអត់បានលទ្ធផលទៅវិញ ឬក៏វាលំបាកទៅថ្ងៃក្រោយ នៅពេលដែលមានការប្តឹងជំទាស់លើបញ្ហាប្រតិចារឹកដែលកត់ត្រានូវកិច្ចដំណើរការសវនាការនេះ។

[១៤:១៥:២៦]

បើសិនជាលោកមានការលំបាក មិនទំនង លោកអាចប្រាប់យើង ដើម្បីយើងឲ្យ ចាត់ឲ្យបុគ្គលិកមន្ត្រីជំនួយការរបស់យើងរៀបរយនូវក្បាលមីក្រូជូនលោក ដើម្បីឲ្យងាយក្នុងការពិនិត្យមើល។

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** តើលោកសាក្សី ចាំដែរឬទេ-- បាទខ្ញុំសូមសួរឡើងវិញសិន តើលោកដឹងទេអ្វីទៅ គឺ រ៉េន ហ្វុង? ក្រុមហ៊ុន រ៉េន ហ្វុង?

**លោក សគីម ល្មុត៖**

**ឆ៖** ពេលដែលមានការស៊ើបសួរមុននោះ ខ្ញុំមិនចាំឈ្មោះ រ៉េន ហ្វុង ហ្នឹងទេ។ តែពេលនុ៎ង ចៅក្រមជាអ្នកអង្កេតហ្នឹងបានយកឯកសារមួយមកខ្ញុំមើល ឃើញឈ្មោះ រ៉េន ហ្វុង បានខ្ញុំនឹកឃើញ។ អាហ្នឹងមុនឃើញឯកសារមកឲ្យរំឭកការចងចាំ ខ្ញុំភ្លេចហើយ ខ្ញុំ ពីព្រោះអានេះវាមិនមែនឈ្មោះខ្មែរអីណា ឈ្មោះដូចចិនអ៊ីចឹង។ ហើយបាននឹកឃើញថា នេះគឺជាក្រុមហ៊ុនមួយដែលគេបង្កើតនៅទីក្រុងហុងកុង ខ្ញុំបានបំភ្លឺអ៊ីចឹងសម្រាប់ទាក់ទងដោះដូរទំនិញអីជាមួយប្រទេសខាងលោកសេរីអីផ្សេងៗហ្នឹង បាទ រ៉េនហ្វុង ហ្នឹងបាទ។

[១៤:១៧:១១]

**ស៖** សូមអរគុណច្រើន។ តើទំនាក់ទំនងមន្ទីរ រ៉េន ហ្វុង ជាមួយនឹងគណៈកម្មាធិការពាណិជ្ជកម្ម ឬក្រសួងពាណិជ្ជកម្មហ្នឹង តើមានទំនាក់ទំនងអ្វីដែរ?

**ឆ៖** អាហ្នឹងជាការបង្កើតរបស់ អាដែងការងារពាណិជ្ជកម្មហ្នឹង គណៈកម្មាធិការពាណិជ្ជកម្មហ្នឹង ដើម្បីឲ្យវាមាន ដូចថាកន្លែងមួយសម្រាប់ដោះដូរទំនិញរវាងប្រទេសខាងក្រៅទៀត ជាពិសេសខាងប្រទេសលោកសេរីបាទ។ នេះជាក្នុងសមត្ថកិច្ចរបស់គណៈកម្មាធិការពាណិជ្ជកម្ម ហើយ-- បាទ នេះប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណច្រើនចំពោះចម្លើយនេះ។ ខ្ញុំនឹងព្យាយាមបញ្ចប់ចំណុចពាក់ព័ន្ធនឹងចំណុចអង្គហេតុដែលពាក់ព័ន្ធទៅនឹងមន្ទីរនេះ ថាតើមន្ទីរនេះមានទំនាក់ទំនងយ៉ាងម៉េចជាមួយនឹងគណៈកម្មាធិការពាណិជ្ជកម្ម? លោកបានជម្រាបជូនយើងខ្ញុំមុននេះថា ការដឹកជញ្ជូនទៅក្រៅប្រទេស រួមមានការដឹកអាហារ រួមទាំងសណ្តែក និងស្រូវ។ តើលោកដឹងទេ កសិផលទាំងអស់នោះ គឺគេធ្វើនៅឯណាប្រមូលទិន្នផលនេះពីណាមកមុនពេលដឹកចេញទៅ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ ព្រោះនេះជាការងាររបស់ក្រសួងពាណិជ្ជ-- កិច្ចពាណិជ្ជ ក្នុងប្រទេសក្រៅប្រទេស បាទ។ ខ្ញុំមិនបានទៅចូលរួមដឹងឮនូវរឿងនេះទេបាទ។

[១៤:១៩:២២]

**ស៖** តើលោកធ្លាប់បានឮ ឃ្លាំងមួយដែលមានទីតាំងនៅទួលទំពូងដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលឮទេបាទ។

**ស៖** ចុះទីតាំងហៅគីឡូលេខ៦ តើលោកស្គាល់ទីតាំងគីឡូលេខ៦នេះ ដែរឬទេ?

**ឆ៖** ទីតាំងគីឡូលេខ៦ នេះ ពីមុនគឺថា សំដៅជារ៉ាវទេះភ្លើងនៅត្រង់នុំង ហើយអាហ្នឹងពីមុនមកធ្លាប់តាំងនៅកន្លែងនុំង ដែលហៅថា សម័យកម្ពុជាប្រជាធិបតេយ្យ បានគេយកឃ្លាំងហ្នឹងធ្វើអីដែរ ខ្ញុំក៏មិនដឹងដែរ។ អាហ្នឹងវាឈ្មោះតាំងពីមុនមកថា ឃ្លាំងគីឡូលេខ៦ បាទ។

**ស៖** តើលោកដឹងដែរឬទេថា ទីតាំងគីឡូរលេខ៦ នោះត្រូវបានក្រសួងពាណិជ្ជកម្មប្រើប្រាស់ចាប់ពីឆ្នាំ៧៥ ដល់៧៩ ដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** សូមអរគុណច្រើនចំពោះចម្លើយទាំងអស់នេះ។ នៅពេលនេះ ខ្ញុំសូមត្រឡប់ទៅចម្លើយដែលលោកបានឆ្លើយពីខាងដើម ដែលចម្លើយនោះគឺពាក់ព័ន្ធនឹងកិច្ចប្រជុំដែលលោកបានចូលរួមប្រជុំជាមួយនឹងគណៈប្រតិភូបរទេស។ ខ្ញុំសូមបញ្ជាក់ថា យើងទទួលស្គាល់នូវចម្លើយដែលលោកបានឆ្លើយក៏ប៉ុន្តែនៅពេលនេះ ខ្ញុំសូមបង្ហាញនូវឯកសារមួយចំនួន ហើយនិងសួរលោក តើលោកអាចឆ្លើយបញ្ជាក់យើងខ្ញុំបានដែរឬទេ? ថាតើឯកសារទាំងអស់នោះគេប្រើសម្រាប់គោលបំណងអ្វីដែរ?

[១៤:២២:០៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមានបំណងបង្ហាញជូនសាក្សីនេះនូវឯកសារមួយចំនួនពីក្រសួងពាណិជ្ជកម្ម។ ឯកសារទីមួយ នៅក្នុងចង្កោមឯកសារទាំងអស់នោះ មានលេខ D248/6.1.11។ លោក លោកស្រីចៅក្រមជាទីគោរព ឯកសារទាំងអស់នេះ មានការពាក់ព័ន្ធទៅនឹងសាក្សី ដូចដែលសាក្សីបានបញ្ជាក់រួចមកហើយថា សាក្សីបានចូលរួមប្រជុំជាមួយនឹងគណៈប្រតិភូបរទេស។ ឯកសារនេះ គឺជាកំណត់ហេតុនៃកិច្ចប្រជុំទាំងអស់នោះ ហើយបានបញ្ជាក់ថា សាក្សីគឺគាត់មានវត្តមានក្នុងពេលប្រជុំតាងនាមឲ្យខាងប្រទេសកម្ពុជា។ ដូច្នេះហើយ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ធ្វើការបង្ហាញឯកសារនេះជូនសាក្សីដើម្បីសួរសាក្សីថា តើគាត់ស្គាល់ឯកសារនេះដែរឬទេ? ហើយឲ្យសាក្សីឆ្លើយបញ្ជាក់ជូនយើងខ្ញុំផង។ សូមអរគុណ។

[១៤:២៣:១៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ ជាបឋម គឺមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យជាមុនសិន។ ហើយតំណាងសហព្រះរាជអាជ្ញាសួរបញ្ជាក់អំពីបញ្ហាថា តើសាក្សីនេះធ្លាប់ស្គាល់ និងឃើញឯកសារនេះពីមុនមកដែរឬទេ? ដើម្បីឲ្យអង្គជំនុំជម្រះសម្រេចចុងក្រោយ ថាដាក់-- ឲ្យដាក់ដេញដោល ឬក៏មិនឲ្យដាក់នៅចំពោះមុខសាក្សីក្នុងការដេញដោលនាពេលនេះទេ។

[១៤:២៤:០០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក លុត សូមឲ្យលោកអញ្ជើញពិនិត្យឯកសារនេះ ហើយដូចដែលអង្គជំនុំជម្រះបានបង្គាប់ និងសួរទៅកាន់លោកថា តើលោកនឹកឃើញថា ធ្លាប់ឃើញឯកសារនេះដែរឬទេ?

**លោក សគឹម លុត៖**

ខ្ញុំសូមអនុញ្ញាតឲ្យខ្ញុំមើលបន្តិចបានទេបាទ? ព្រោះមើលមួយភ្លែតអ៊ីចឹងទៅវា-- ខ្ញុំសូមអរគុណ។

*(សាក្សីពិនិត្យមើលឯកសារ)*

**ឆ៖** ខ្ញុំសូមជម្រាបតុលាការដូចតទៅ៖ ខ្ញុំចាំបានថាធ្លាប់មានប្រជុំជាមួយគណៈកម្មាធិការ-- អ៎! ខាងគណៈប្រតិភូកូរ៉េ ហើយមានទិញស្អី នាំអីវ៉ាន់ហ្នឹងៗ គឺថា ខ្ញុំមិនចាំស្អីច្បាស់ទេ ប៉ុន្តែឯកសារនេះបញ្ជាក់ហើយ។ ហើយដល់-- ហើយដល់ធ្វើរបាយការណ៍ទៅលើ គឺជាគណៈកម្មាធិការពាណិជ្ជជាអ្នកធ្វើៗយ៉ាងម៉េចៗ ក៏ខ្ញុំមិនបានចូលរួមធ្វើទេ។ តែខ្ញុំទទួលស្គាល់ថាបានទៅចូលរួមជាមួយគណៈប្រតិភូ ព្រោះថាដូចខ្ញុំបានជម្រាបពីព្រឹកមិញក៏អ៊ីចឹង តែកាលណាគណៈប្រតិភូកូរ៉េមក គាត់មានអ្នកចេះភាសាបារាំង ហើយខ្មែរយើងជំនាន់នោះគ្មាននរណាចេះភាសាកូរ៉េ គាត់ក៏ដូចជាមិនចេះភាសាខ្មែរដែរ។ ហើយខ្ញុំនេះបារាំងដែរទៅ គាត់ក៏បារាំង ខ្ញុំក៏បារាំង។ ហើយ--

[១៤:២៦:៣៤]

**ប្រធានអង្គជំនុំ៖**

បាទអរគុណៗ។ ឥឡូវចាំស្តាប់អង្គជំនុំជម្រះអនុញ្ញាត តំណាងសហព្រះរាជអាជ្ញាអាចតាំងសំណួរដេញដោលចំពោះសាក្សីបានហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក លួត។ ខ្ញុំមិនមែនស្នើសុំឲ្យលោកពន្យល់ខ្លឹមសារលម្អិតនៃឯកសារនេះទេ។

ប្រហែលខ្ញុំសូមអនុញ្ញាតពីលោកប្រធានបញ្ចាំងឯកសារនេះនៅលើអេក្រង់ ហើយអាចឲ្យអ្នកផ្សេងគាត់អាចបានមើលឯកសារនេះផង។ តើយើងខ្ញុំទទួលការអនុញ្ញាតពីលោកប្រធានបញ្ចាំងឯកសារនេះដែរទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត! តែលើកក្រោយកុំធ្វើដូច្នេះ។ រង់ចាំយើងអនុញ្ញាត សឹមបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ មិនមែនបង្ហាញរួច ទើបសុំយើងទេ។

[១៤:២៧:៤៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ ហើយសូមឲ្យខាងសោតទស្សន៍ជួយបញ្ចាំងឯកសារនេះនៅលើអេក្រង់ផង។ សូមអរគុណច្រើន។ ដើម្បី-- បាទ យើងទំនងជាហាក់ដូចជាមានការជំទាស់ពីភាគី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្ដី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំហាក់ដូចជាមិនយល់ច្បាស់ទេ ហើយខ្ញុំមិនស្ដាប់ឮសាក្សីឆ្លើយបញ្ជាក់ថាតើសាក្សីធ្លាប់ឃើញឯកសារនេះពីមុនមកដែរឬទេ? សាក្សីគ្រាន់តែនិយាយអំពីខ្លឹមសារនៃឯកសារនេះតែប៉ុណ្ណោះ។ ហើយអត់ឃើញមានសំណួរទៅកាន់សាក្សី ថាតើសាក្សីស្គាល់ឯកសារនេះដែរឬទេ?

[១៤:២៨:៣៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំគិតថាយើងកំពុងតែមានចំណុចខុសគ្នាហើយត្រង់នេះ។ យើងមានមូលដ្ឋានសមរម្យ ដែលយើងសួរទៅលើសាក្សីនេះរួចមកហើយ ដោយសារតែសាក្សីគាត់បានបញ្ជាក់ហើយថាគាត់ឯកសារនេះ ហើយថាកិច្ចប្រជុំបានធ្វើឡើងនាពេលនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ។ លោកតំណាងសហព្រះរាជអាជ្ញាអាចផ្អែកលើមូលដ្ឋាននៃឯកសារនេះដេញដោលចំពោះសាក្សីនេះបានហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ នៅពេលនេះ យើងត្រឡប់មើលឯកសារនេះវិញ។ សូមលោក ល្អុត មើលជាថ្មីម្តងទៀត។ ខ្ញុំសូមឲ្យជួយបញ្ចាំងនៅលើអេក្រង់ ដើម្បីឲ្យអស់លោក លោកស្រីទាំងឡាយនៅក្នុងបន្ទប់សវនាការនេះបានមើល។

[១៤:២៩:៣០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត ជាថ្មីម្តងទៀត ខ្ញុំនឹងអានពីរបីជួរ ជាភាសាអង់គ្លេស បន្ទាប់មកឲ្យលោកជួយបញ្ជាក់ថាអ្វីខ្ញុំអានជាភាសាបរទេសនេះ ស៊ីសង្វាក់គ្នាជាមួយភាសាខ្មែរដែរឬទេ? នៅខាងឆ្វេងសរសេរថា៖ "ក្រសួងពាណិជ្ជកម្ម" នៅចំណុចកណ្តាល៖ "ជូនចំពោះ បងហែម ជាទីគោរពនិងស្នេហា"។ ដូច្នេះ តើនេះជាអ្វីដែលលោកបានមើលឃើញដែរឬទេ? ហើយដូចនឹងអ្វីដែលខ្ញុំអានដែរឬទេ នៅចំណុចកណ្តាលនៃឯកសារនេះ នៃទំព័រនេះ? បាទ គឺជួរនៅកណ្តាលគេនេះ តើដូចនឹងអ្វីដែលលោកបានមើលដែរឬទេ តាមអ្វីដែលខ្ញុំអាន?

**លោក សគឹម ល្អុត៖**

**ឆ៖** បាទៗ ឃើញអ៊ីចឹង "ជូនចំពោះ បងហែម ជាទីគោរព! ជាទីស្នេហា!" បាទ។

**ស៖** សូមអរគុណ។ ប្រសិនបើ *ស្គ្រីប* វា រំលង ចូលទៅមើលទំព័រចុកក្រោយនៅក្នុងឯកសារនេះ។ សូមឲ្យលោក ល្អុត មើលទំព័រចុងក្រោយក្នុងឯកសារនេះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ហើយសូមខាងសោតទស្សន៍ជួយបញ្ចាំងឯកសារនេះមួយភ្លែតផង ដើម្បីឲ្យយើងមើលឃើញទាំងអស់គ្នា។ បញ្ចាំងតាមអេក្រង់។ បាទ សូមឲ្យខាងសោតទស្សន៍ជួយបញ្ចាំង។ សូមអរគុណ។

[១៤:៣១:១៩]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ប្រសិនបើខ្ញុំចាប់ផ្តើមនៅខាងឆ្វេង អានពីខាងឆ្វេង ហើយខ្ញុំនឹងអានជាភាសាអង់គ្លេស

សម្រាប់អ្នកដែលមិនចេះភាសាខ្មែរ។ ខ្ញុំសូមពង្រីកអេក្រង់នេះសិន។ “ផ្ញើជូន បងហែម មួយច្បាប់, បងវ៉ន មួយច្បាប់, ៥១ មួយច្បាប់”។ តើលោកបានឃើញទេ អ្វីដែលខ្ញុំអានផ្នែកហ្នឹង?

**លោក សតឹម ល្អុត៖**

**ឆ៖** ឃើញបាទ ឃើញ។

**ស៖** តើលោកឯកសារជាមួយនឹងខ្ញុំដែរឬទេ? ប្រសិនបើយើងមើលខាងលើហ្នឹងបន្តិច ពីប្រយោគខាងលើ លិខិតនេះ របាយការណ៍នេះសរសេរថា៖ “សូមបងជ្រាបជាព័ត៌មាន និងមានមតិណែនាំ”។ តើលោកឃើញឃ្លាហ្នឹងដែរឬទេ? គឺអំមិញតែមួយប្រយោគទេអ្វីដែលខ្ញុំអាន តើលោកឃើញដែរឬទេ?

**ឆ៖** អំ យល់ហើយ, “សូមបងជ្រាបជាព័ត៌មាន និងមានមតិណែនាំ”។ បាទ ឃើញបាទ។

[១៤:៣២:៤៥]

**ស៖** សូមអរគុណច្រើន។ នេះគឺឯកសារកិច្ចប្រជុំជាមួយនឹងគណៈប្រតិភូកូរ៉េ តាមអ្វីដែលឯកសារនេះបានសរសេរ។ ដើម្បីជាកំណត់ត្រា កំណត់ប្រតិចារឹក “ខាងកម្ពុជាមាន សមមិត្ត បងរិទ្ធ, ឆេង និង ល្អុត ជាអ្នកបកប្រែ”។ នៅពេលនោះ តើលោកយល់ថា ហេតុអ្វីជាបានជាគេរៀបចំរបាយការណ៍បែបនេះ ផ្ញើជូនទៅ ហែម ហើយនិងផ្ញើជូនទៅ វន?

**ឆ៖** ខ្ញុំមិនដឹងជាមូលហេតុអីទេ ប៉ុន្តែបើថាតាមធម្មតាទៅ គឺថាធ្វើការអីអ្នកខាងក្រោមក៏ត្រូវតែរាយទៅខាងលើអ៊ីចឹងហើយ ខ្ញុំយល់អ៊ីចឹង។ តែត្រង់មូលហេតុយ៉ាងម៉េចៗ ខ្ញុំមិនអាចបញ្ជាក់ជូន។ តែយើងជាធម្មតាអ្នកខាងក្រោម ខាងក្រសួងពាណិជ្ជកម្មទៅ-- រាយការណ៍ការទៅខាងលើ ទៅគណៈកម្មាធិការសេដ្ឋកិច្ចហ្នឹង ដែលឈ្មោះហ្នឹង មានឈ្មោះ បងវន ហើយ បងហែម ហ្នឹងបាទ។

[១៤:៣៤:២៥]

**ស៖** សូមអរគុណ។ បាទ គ្រាន់តែឲ្យលោកបញ្ជាក់ថា ខ្ញុំយល់ត្រឹមត្រូវដែរទេ? នោះមានន័យថា បងហែម ហើយនិង បងវន គឺជាថ្នាក់លើរបស់ក្រសួងពាណិជ្ជកម្មនោះ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយបាទ។

**ស៖** សូមអរគុណ។ នៅក្នុងទំព័រចុងក្រោយ ហើយមានសេចក្ដីយោងមួយ ដែលថាមួយច្បាប់បញ្ជូនទៅ៥១។ តើលោកអាចជម្រាបតុលាការបានទេ ថាតើ៥១ នោះគឺមានន័យដូចម្ដេច? មន្ទីរ ឬក៏អ្វីកន្លែងណាបាទ?

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ជូនបានទេ។ មិនដឹងជាមន្ទីរ ឬក៏មនុស្ស ខ្ញុំមិនដឹងទេបាទ។

[១៤:៣៥:៣៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ ឥឡូវនេះ ខ្ញុំបន្តទៅរក នៅក្នុងប្រធាននេះដែរ ខ្ញុំសូមអនុញ្ញាតបង្ហាញលោកនូវឯកសារមួយទៀតដែរ។ សូមអនុញ្ញាតពីលោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតបង្ហាញ D366/7.1.160។ ចំណុចពាក់ព័ន្ធនៃឯកសារនេះចំពោះសាក្សីនេះគឺ មិនច្រើនប៉ុន្មានទេ គឺទាក់ទងទៅនឹង ជារបាយការណ៍របស់ក្រសួងពាណិជ្ជកម្ម ហើយមានសេចក្តីយោងទៅរកសាក្សី ដែលថាគាត់វត្តមាននៅក្នុងការប្រជុំជាមួយគណៈប្រតិភូ ហើយមានរបាយការណ៍ពីការប្រជុំនោះ ហើយសូមអនុញ្ញាតលោកប្រធានដើម្បីបង្ហាញឯកសារលើក្រដាសជូនលោកសាក្សីបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបឋម អនុញ្ញាតឲ្យយកនេះជូនសាក្សីពិនិត្យសិន មុននឹងសម្រេចដាក់ឲ្យពិភាក្សាដេញដោល ឬក៏អត់។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាស ពីតំណាងសហព្រះរាជអាជ្ញា ជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្អុត នេះជាឯកសារចុងក្រោយ ហើយសូមលោកពិនិត្យមើលឯកសារ លោកជម្រាបប្រាប់យើងខ្ញុំ ថាតើលោកធ្លាប់ស្គាល់ឯកសារហ្នឹងឬទេ ហើយថាមានកិច្ចប្រជុំបែបនេះទេ ដូចដែលមាននៅក្នុងឯកសារកំណត់ហេតុនេះបាទ?

[១៤:៣៧:៤៧]

**លោក សគីម ល្អុត៖**

**ឆ៖** បាទ ខ្ញុំចាំបានថា ធ្លាប់មានប្រជុំជាមួយគណៈប្រតិភូយូហ្គោស្លាវីមែន ក្នុងការគេស្នើទិញលក់ដូរហ្នឹង។ ហើយខ្ញុំទៅរួមជាអ្នកបកប្រែ ប៉ុន្តែក្រោយគេធ្វើសេចក្តីរាយការណ៍ហ្នឹងហើយ ក៏គេមិនបានឲ្យខ្ញុំមើលដែរទេ ប៉ុន្តែខ្ញុំមើលនេះទៅឃើញថា វាអាចអ៊ីចឹងមែនហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ សូមអនុញ្ញាតលោកប្រធាន ដើម្បីសួរសំណួរលោកសាក្សីអំពីឯកសារនេះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ ហើយជំនួយការអាចជួយបញ្ចាំង បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយនិងផ្នែកខាងសោតទស្សន៍ បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តី លោក នួន ជា!

[១៤:៣៩:២៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់ជំទាស់ទេថា ខ្ញុំមិនចង់ឲ្យដកចេញពីសាក្សី ប៉ុន្តែខ្ញុំចង់ដឹងថា សេចក្តីសម្រេចនេះ ហាក់ដូចជាមិនសមស្រប មិនស្របទៅតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ ពីមុនមកទេ។ ដូច្នេះ សូមតុលាការជម្រាប ឬក៏បកស្រាយខ្លឹមសារនៃសេចក្តីសម្រេចនេះផងបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងមានទស្សនៈ។ យើងយល់ថា នេះជាការសម្រេចស្របគ្នាទៅតាមសេចក្តីសម្រេចដែលថា យើងសួរសាក្សី ឲ្យគាត់ស្គាល់ ឬមិនស្គាល់ ហើយគាត់បានយោងទៅរកការប្រជុំ គាត់បានឆ្លើយ។ ដូច្នេះមានមូលហេតុសមស្រប ដើម្បីនឹងដាក់ឯកសារនេះដេញដោលបានទៅតាមការបង្គាប់របស់តុលាការហើយ។

[១៤:៤០:១៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនទៅលោកមេធាវី ម៉ៃខល ផេសមិន សូមអញ្ជើញក្រោកឈរ!

យុត្តិសាស្ត្រ ឬក៏សេចក្តីណែនាំអនុវត្ត ដែលអង្គជំនុំជម្រះបានជម្រាបជូនកន្លងមក វាមិនដូចគ្នា

នឹងករណីឯកសារដែលតំណាងសហព្រះរាជអាជ្ញា ស្នើសុំដាក់បង្ហាញចំពោះអង្គ-- ចំពោះមុខសាក្សី ដើម្បីសួរដេញដោលនាពេលនេះឡើយ។ សូមលោកពិនិត្យ ហើយពិចារណាឡើងវិញឲ្យបានច្បាស់ ឯកសារនេះគឺវាពាក់ព័ន្ធផ្ទាល់ទៅនឹងការពិតជាក់ស្តែងដែលសាក្សីបានទទួលស្គាល់ថា ខ្លួនពិតជាបានដឹង និងបានចូលរួមដោយផ្ទាល់នៅក្នុងកិច្ចពិភាក្សានោះយ៉ាងពិតប្រាកដ។ ដូច្នេះ ខ្លឹមសារនៃការសួរដេញដោលវាមិនសំខាន់ទេទៅលើពាក្យពេចន៍ខ្លឹមសារនៃឯកសារ វាសំខាន់ទៅលើខ្លឹមសារនៃការប្រព្រឹត្តជាក់ស្តែងនៅក្នុងអំឡុងពេលនៃដំណើរការពាក់ព័ន្ធទៅនឹងឯកសារ។ នេះជាមូលដ្ឋានសំអាងហេតុក្នុងការដែលអនុញ្ញាតឲ្យលើកយកឯកសារនេះ មកពិភាក្សាដេញដោលចំពោះមុខសាក្សីនៅចំពោះអង្គជំនុំជម្រះ ដែលវាខុសពីឯកសារនាពេលមុន ដែលឯកសារផ្សេងទៀតដែលសាក្សីមិនដែលដឹងទាល់តែសោះទាំងខ្លឹមសារ ទាំងអង្គហេតុពាក់ព័ន្ធនឹងខ្លឹមសារនៃឯកសារនោះ។ ដូច្នេះ អង្គជំនុំជម្រះបដិសេធនូវការជំទាស់នេះ ម្យ៉ាងទៀតការជំទាស់របស់លោក គឺយឺតពេល ពីព្រោះអង្គជំនុំជម្រះបានសម្រេចរួចហើយ។

បាទ អញ្ជើញអង្គុយចុះ!

អញ្ជើញតំណាង-- អំ លោកមេធាវីការពារក្តីលោក ខៀវ សំផន!

ចង់លើកបញ្ហាអីទៅ បញ្ហាដដែល ឬក៏បញ្ហាផ្សេងទៀត? បញ្ហាជំទាស់លើបញ្ហាអម្បាញ់មិញនេះ ឬក៏បញ្ហាផ្សេងទៀត? ជាបឋម លោកស្រីឆ្លើយនឹងសំណួរយើងសិន ថាតើលោកស្រីចង់លើកឡើងមតិជំទាស់លើបញ្ហាអម្បាញ់មិញនេះ លើដាក់ឯកសារនេះ ឬក៏លើកបញ្ហាផ្សេងទៀត?

[១៤:៤៤:០៩]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ជាប្រធានបទផ្សេងទៀត។ ខ្ញុំចង់មានការបំភ្លឺ ដែលថាការបំភ្លឺនេះវាមានសារៈសំខាន់សម្រាប់អ្នកនិយាយភាសាបារាំង។ ឯកសារ ចំពោះឯកសារនេះ ខ្ញុំចង់បញ្ជាក់ថាឯកសារជាភាសាបារាំងគឺ ERN 00501192 ឯកសារនេះពុំមានការបកប្រែនៅលើចំណារដៃទេ ខាងជាភាសាខ្មែរក៏អត់មាន អង់គ្លេសក៏អត់មាន។ ដូច្នេះដើម្បីឲ្យមានកំណត់ហេតុច្បាស់លាស់នោះ ព្រោះថាពេលក្រោយមកអង្គជំនុំជម្រះត្រូវការធ្វើការសម្រេច។ អ៊ីចឹងគ្រាន់តែចង់បញ្ជាក់ថា ពុំមានការបកប្រែចំណារជាភាសាបារាំងនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក

២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដែលយើងបានកំណត់អម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៤:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។ ហើយជាបឋមលោកត្រូវឲ្យមកយើងនូវរបៀបវារៈ ឬបញ្ហាដែលលោកមានបំណង និងលើកមកនិយាយនៅពេលនេះដោយខ្លីបានហើយ តើយើងត្រូវអនុញ្ញាត ឬក៏មិនអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែងការណ៍នេះ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអធ្យាស្រ័យ សូមអភ័យទោសលោកប្រធាន សូមអធ្យាស្រ័យខាងសហព្រះរាជអាជ្ញាដោយសារតែខ្ញុំកាត់នៅត្រង់នេះ។ ខ្ញុំមានចំណុចមួយដែលត្រូវលើកឡើងដែលពាក់ព័ន្ធទៅនឹងអ៊ីម៉ែលដែលទទួលបានពីមន្ត្រីជាន់ខ្ពស់របស់លោកកាលពីប៉ុន្មានសប្តាហ៍មុន ហើយបានស្នើសុំព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងការទំនាក់ទំនងអ៊ីម៉ែល រវាងចៅក្រម ខាតវ៉ាយថ៍ និងអាន់ឌ្រូ ខេលី។ ជាពិសេស យើងខ្ញុំបានសួរបញ្ជាក់តាមការពិនិត្យទៅមើលអ៊ីម៉ែលនេះ--

[១៥:០៥:៥៨]

**ប្រធានអង្គជំនុំ៖**

លោកអាចត្រូវធ្វើពាក្យលាយលក្ខណ៍អក្សរមកយើងនែ៎! យើងបានប្រាប់ហើយ បញ្ហាក្រៅពីឆ្ងាយពីរបៀបវារៈដែលត្រូវជជែកដេញដោលនេះ យើងមិនអនុញ្ញាតឲ្យទេ។

E1/79.1

អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញបន្តការតាំងសំណួរដេញដោល!

យើងឲ្យលោកឈប់ យើងមិនអនុញ្ញាតឲ្យលោកនិយាយបញ្ហានេះទេ លោកអាចធ្វើលាយលក្ខណ៍អក្សរមកយើងបញ្ហាអ្វីខ្លះដែលលោកត្រូវការឲ្យអង្គជំនុំជម្រះដោះស្រាយ។

**លោក ហ្សាស្តើ ប៉ោ៖**

*(និយាយមិនបើកក្បាលមីក្រូហ្វូន)*

[១៥:០៦:៥៨]

**ប្រធានអង្គជំនុំ៖**

យើងឲ្យលោកអង្គុយចុះ យើងមិនអនុញ្ញាតឲ្យលោកនិយាយទេ!

**លោក ហ្សាស្តើ ប៉ោ៖**

*(និយាយមិនបើកក្បាលមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យលោកនិយាយទេ!

លោកអាចធ្វើលាយលក្ខណ៍អក្សរមកយើង។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។

សួស្តីសាជាថ្មីម្តងទៀត លោក សគឹម ល្អុត។ ខ្ញុំដឹងថា វារសៀលបន្តិចហើយ ហើយលោកប្រាកដជាហត់នឿយ ខ្ញុំនឹងសួរបញ្ចាក់យឺតៗ ហើយខ្ញុំសង្ឃឹមថាលោកអាចជួយឆ្លើយជូនយើងខ្ញុំ។ ប្រសិនបើលោកពិនិត្យឡើងវិញ មើលឯកសារចុងក្រោយមុនពេលដែលយើងឈប់សម្រាកដែលយើងខ្ញុំទទួលបានការអនុញ្ញាតបង្ហាញជូនលោក គឺឯកសារលេខ D366/7.1.160។ លោក ល្អុត ប្រសិនបើលោកមើលខាងស្តាំដែលសរសេរលេខថា D366។ អ៊ីចឹងខាង-- ឲ្យមន្ត្រីខាងតុលាការជួយបង្ហាញគាត់ផង។

លោកប្រធាន យើងខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើអេក្រង់ ដើម្បីឲ្យសាធារណជននិងភាគីទាំងអស់បានមើលឃើញផង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញបុគ្គលិកជំនួយការ ហើយនិងផ្នែកសោតទស្សន៍ បង្ហាញឯកសារហ្នឹងលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។

[១៥:០៩:៣៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្មុត យើងមើលផ្នែកខ្លីៗនៅក្នុងឯកសារនេះ ចំណុចខ្លីៗនៅក្នុងឯកសារនេះ ខ្ញុំនឹងមើលឯកសារជាភាសាអង់គ្លេស។ តើឯកសារនេះផ្ញើជូនចំពោះ បងហែម ជាទីគោរព និងស្នេហា ដែរឬទេ? សូមឲ្យលោកមើលជួរដំបូងគេបំផុតនៅចំកណ្ដាល តើលោកឃើញទេ? ជូនចំពោះ បងហែម ជាទីគោរព និងស្នេហា។

**ឆ៖** បាទ ឃើញបាទ។ អានថា "ជូនចំពោះ បងហែម ជាទីគោរព និងស្នេហា"។ បានឃើញបាទ។

**ស៖** តើលោកអាចអានចំណារដោយដៃនេះដែរឬទេ នៅខាងឆ្វេងនោះ ឬក៏លោកចង់ឲ្យខ្ញុំអានជាភាសាអង់គ្លេស បន្ទាប់ឲ្យលោកផ្ទៀងផ្ទាត់ទៅលើអ្វីដែលខ្ញុំអាន? លោកអាចអានបានទេ?

**ឆ៖** ខ្ញុំអានបានតែក្នុងនេះជាអក្សរខ្មែរទេ។ ជាអក្សរខ្មែរ អានបាន បកប្រែហើយបាទ។ អានអ្វី? ខាងមុខមើលមិនដាច់ "ផ្ញើជូនបងហែម និង វន ហើយ" អ៎! "បានផ្ញើជូន បងហែម និងវន ហើយតាមរយៈ ក--" "ក"ប៉ុន្មានទេមិនច្បាស់ទេ "មានលេខិតជូនទៅស្ថានទូតយូហ្គោស្លាវីផង "ក" ប៉ុន្មានខ្ញុំមើលមិនច្បាស់ទេ លេខហ្នឹងអ្វី! បានន័យថា បានជូនទៅ បងហែម និងបងវន ហើយតាមរយៈ "ក" លេខប៉ុន្មានដែលមើលមិនច្បាស់ហ្នឹង មានលិខិតផ្ញើទៅ អ៎! អគ្គរដ្ឋទូតយូហ្គោស្លាវី ផង។

[១៥:១២:០៤]

**ស៖** សូមអរគុណច្រើន។ លោកបានជម្រាបជូនយើងខ្ញុំរួចមកហើយថា មានការប្រជុំជាមួយនឹងគណៈប្រតិភូយូហ្គោស្លាវី។ ឯកសារនេះបានបង្ហាញថា កិច្ចប្រជុំនេះជួបជាមួយឯកឧត្តមអគ្គរដ្ឋទូតយូហ្គោស្លាវី។ ប្រសិនបើយើងមើលទំព័រដំបូង គឺទំព័រដដែលនេះ ដែលលោកកំពុងតែពិនិត្យមើលហ្នឹង ដែលចំណុច ដែលនិយាយថា មតិអគ្គរដ្ឋទូតយូហ្គោស្លាវី តើលោកឃើញទេចំណុចហ្នឹង? មតិអគ្គរដ្ឋទូត

យូហ្គោស្លាវី?

**ឆ៖** ឈប់ៗ។

**ស៖** បាទ គឺប្រហែលជានៅខាងលើបន្តិចត្រង់ពាក់កណ្ដាល កន្លែងចំណុចកណ្ដាលតែខាងលើបន្តិច ក៏ប៉ុន្តែខ្មែរទំនងជាខុសគ្នានឹងភាសាអង់គ្លេស។ ខ្ញុំបានឃើញជាភាសាខ្មែរហើយ គឺត្រង់ចំណុចដែលចំណុចនិយាយថា មតិអគ្គរដ្ឋទូតយូហ្គោស្លាវី បន្ទាប់មកបញ្ហាទីមួយ។ តើលោកឃើញទេ?

បាទ ខ្ញុំសូមឲ្យមន្ត្រីតុលាការជួយចង្អុលបង្ហាញផង។

[១៥:១៣:៤៨]

**ឆ៖** ខ្ញុំបានឃើញហើយបញ្ហាទីមួយ ទីពីរហ្នឹងបាទ ឃើញបាទ។ ខ្ញុំអានអ៊ីចឹងអ្ហ៎! ឲ្យខ្ញុំអានគឺថា "បញ្ហាទីមួយ យើងខ្ញុំបានទទួលទូរលេខពីម្សិលមិញស្ដីពីការលក់ដូរអង្ករ និងកាហ្វេ និងទូរលេខដែលយើងខ្ញុំបានបក--"។

**ស៖** សូមអរគុណលោក ល្អុត។ ចំណុចត្រឹមតែប៉ុណ្ណឹងទេ ដែលខ្ញុំចង់ផ្ដោតសួរ។ ក្នុងនេះនិយាយអំពីការលក់ដូរអង្ករ និងកាហ្វេ។ តើលោកនឹកឃើញទេ ការពិភាក្សាអំពីការនាំចេញអង្ករនិងកាហ្វេ ពីកម្ពុជានោះ? តើគេបានពិភាក្សាលើអ្វីខ្លះ? តើលោកចាំទេ?

**ឆ៖** បាទ ខ្ញុំមិនចាំទេបាទ។ ខ្ញុំមិនចាំទេបាទ។ មានតែលក់អង្ករ កាហ្វេ ត្រង់លម្អិតទៀត ខ្ញុំមិនចាំទេបាទ។

[១៥:១៥:០៣]

**ស៖** តើវាត្រឹមត្រូវដែរឬទេ ដែលយើងអាចនិយាយថា ពាក់ព័ន្ធទៅនឹងឯកសារនេះ នេះគឺជាឯកសាររបាយការណ៍របស់ក្រសួងពាណិជ្ជកម្ម និងគណៈកម្មាធិការពាណិជ្ជកម្មដែលផ្ញើជូនទៅកាន់បងហែម តើត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក--

ឈប់! កុំអាល់ទាន់ឆ្លើយសាក្សី ឥឡូវមានការជំទាស់តវ៉ាពីមេធាវីការពារក្ដី។

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំជំទាស់នឹងសំណួរនេះដែលជាសំណួរនាំមុខ។ ហើយខ្ញុំសូមរាប់ថានៅក្នុងសំណួរ

មុននោះ សំណួរៗដែលបានសួរពីមុននោះ ដោយលោកសហព្រះរាជអាជ្ញានេះ គឺថាក៏នាំឲ្យសាក្សីឆ្លើយព្រាវៗ ក៏ប៉ុន្តែមិនផ្តល់សក្ខីកម្មលើអ្វីដែលគាត់បានឃើញ និងគាត់បានឆ្លងកាត់នោះដែរ។ អ៊ីចឹងក្នុងលក្ខខណ្ឌនេះខ្ញុំសូមជំទាស់នឹងរបៀបធ្វើ របៀបចោទសំណួរបែបនេះ។ សូមអរគុណលោកប្រធាន។

[១៥:១៦:២១]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយខ្លី។ ខ្ញុំសួរយ៉ាងប្រុងប្រយ័ត្នដោយសារខ្ញុំមិនចង់ដឹកមុខសាក្សីនោះទេ។ តាំងពីពេលមុនមកដល់មកពេលនេះ គឺយើងស្តាប់ឮមតិរបស់សាក្សីពាក់ព័ន្ធទៅនឹងឯកសារចំនួនពីររួចមកហើយ។ ហើយឯកសាររបាយការណ៍បញ្ជូនទៅ ហែម ដែលជាមេ។ ខ្ញុំមិនបានសួរសំណួរនេះ ដោយសារតែយើងខ្ញុំបាន-- ចង់សន្សំពេលវេលា។ ហើយសាក្សីបានឆ្លើយទៅបញ្ហានេះរួចមកហើយ ដោយសារតែពេលវេលា គឺខ្ញុំគិតថាខ្ញុំមិនចង់សួរបញ្ជាក់ទៅលើចំណុចហ្នឹង។ ហើយនៅចំណុចនេះ គឺខ្ញុំមិនមែនផ្តល់ព័ត៌មានថ្មី ហើយធ្វើការដឹកមុខនោះទេ។ អ្វីដែលខ្ញុំសួរ គឺផ្ទុះបញ្ជាំងនូវអ្វីដែលសាក្សីបានឆ្លើយតែប៉ុណ្ណោះ។ សូមអរគុណ។

[១៥:១៧:០៨]

**លោកស្រី អង់តា ហ្គីសសេះ៖**

លោកប្រធាន តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំឆ្លើយតបទៅនឹងលោក ព្រះរាជអាជ្ញាដែរទេ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៧:៥៣]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន គ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ។ លើកលែងតែលោកមិនចងចាំ លោកអាចស្នើសុំឲ្យលោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរនេះសាជាថ្មីម្តងទៀត។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្មុត តើលោកចង់ឲ្យខ្ញុំសួរសំណួរឡើងវិញដែរឬទេលោក? យើងបានពិភាក្សាគ្នាលើឯកសារមួយចំនួនរួចមកហើយ។ ខ្ញុំគ្រាន់តែសួរលោកនៅពេលនេះ នេះគឺជាឯកសាររបាយការណ៍ដែលបានបញ្ជូនទៅបង ហែម ជាមេ។ តើត្រឹមត្រូវដែរឬទេបាទ?

[១៥:១៨:៥៤]

**លោក គង់ សំអុន៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

បញ្ហាដដែលទេ យើងបានសម្រេចរួចហើយ។ ក្រោយពីអង្គជំនុំជម្រះសម្រេច យើងមិនអនុញ្ញាតឲ្យភាគីណាជំទាស់ ឬក៏លើកបញ្ហានេះសាជាថ្មីបន្ថែមទៀតទេ។ សូមលោកចងចាំចាប់ពីពេលនេះតទៅ យើងមិនអនុញ្ញាតឲ្យធ្វើដូច្នេះទេ។ យើងមិនអនុញ្ញាតទេ។

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញា! សូមសាក្សីឆ្លើយ!

**លោក សតឹម ល្អុត៖**

**ឆ៖** ឯកសារនេះ គឺវាស្របទៅនឹងការដែលខ្ញុំចងចាំដែរ។ ប៉ុណ្ណឹងបាទ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់អ្វីដែលបានបញ្ជូនទៅ-- នេះគឺជាឯកសារដែលបានបញ្ជូនទៅបង ហែម ដែលជាមេ តាមរយៈក្រសួងពាណិជ្ជកម្ម។ តើអ៊ីចឹងដែរឬទេ?

[១៥:២០:០៣]

**ឆ៖** បាទ ចំណាវនេះ--

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំសូមជំទាស់។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាល់ទាន់ឆ្លើយ! បាទ សូមអញ្ជើញលោកមេធាវី!

[១៥:២០:១៧]

**លោក គង់ សំអុន៖**

បាទ ខ្ញុំសូមជំទាស់ចំពោះការប្រើពាក្យលើសពីអ្វីដែលមាននៅក្នុងអត្ថបទនេះ។ ពីព្រោះលោកសហព្រះរាជអាជ្ញាគាត់ប្រើពាក្យថា “លោក ហែម ជាមេ” ក៏ប៉ុន្តែនៅក្នុងលិខិតនេះ ហើយក៏ដូចជាការឆ្លើយរបស់សាក្សីពុំបានបញ្ជាក់ថា ឈ្មោះ ហែម នេះជាមេទេបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីជាតិការពារក្តីលោក ខៀវ សំផន គ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយ អម្បាញ់មិញនេះ។

[១៥:២១:០១]

**លោក សគីម ល្មុត៖**

**ឆ៖** ក្នុងចំណារហ្នឹង គឺដាក់ថា "ជូនទៅ បងហែម និង បងវ៉ន" ហើយខ្លឹមសារវាស្របទៅពេលដែលខ្ញុំចងចាំអ៊ីចឹងដែរ។ ធ្លាប់មានប្រជុំមួយយូហ្គោ ក្នុងការទិញលក់អីអ៊ីចឹង។ ហើយបញ្ជូនទៅតាមរយៈ "ក" ប៉ុន្មានទេ ខ្ញុំអាហ្នឹងខ្ញុំ ខ្ញុំមិនដឹងប៉ុន្មានទេ។ ប៉ុន្តែ គឺថាចំណារហ្នឹង ខ្ញុំជឿថាចំណារហ្នឹងវាត្រឹមត្រូវ ហើយមានហត្ថលេខានេះ គឺជាលោក វ៉ាន់ រិទ្ធ ដែលគាត់ជាអ្នក-- ជាប្រធានគណៈកម្មាធិការពាណិជ្ជ បាទ។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោក ល្មុត មុនពេលដែលយើងឈប់សួរទៅលើឯកសារនេះ ខ្ញុំបានសួរលោកពីខាងដើមស្តីអំពីរបាយការណ៍មួយ ថាហេតុអ្វីបានជា រិទ្ធ លោក រិទ្ធ នេះបញ្ជូនរបាយការណ៍ទៅ ហែម និង វន? លោកបានឆ្លើយថា៖"អ្នកនៅក្រោមបង្គាប់ត្រូវបញ្ជូនឡើងទៅថ្នាក់លើ" ហើយលោកបញ្ជាក់ថា៖"លោក រិទ្ធ នេះ គឺជាអ្នកក្រោម ដែលមានថ្នាក់លើជា បងហែម និងបងវ៉ន"។ ខ្ញុំក៏បានបង្ហាញឯកសារនេះមួយទៀត ដែលពាក់ព័ន្ធទៅនឹងរបាយការណ៍នេះ ដែលបានបញ្ជូនទៅថ្នាក់លើទាំងពីរនាក់នោះ"។ តើអ៊ីចឹងមែនដែរឬទេ?

[១៥:២២:៥២]

**ឆ៖** បាទ អ៊ីចឹងបាទ អ៊ីចឹងមែនបាទ។

**ស៖** សូមអរគុណច្រើនលោក ល្មុត។

នៅពេលនេះដើម្បីយើងសន្សំពេលវេលា ដើម្បីជាកំណត់ប្រតិចារឹក ខ្ញុំសូមអានឯកសារ លេខឯកសារ គឺមានរបាយការណ៍បីបន្ថែម បួនបាទ ដែលបានបញ្ជូនរបាយការណ៍ទាំងបួននេះ បានបញ្ជូនផ្ញើជូនទៅ ហែម គឺកំណត់ហេតុកិច្ចប្រជុំដែលលោក ល្មុត បានចូលរួមនៅពេលនោះ។ ខ្ញុំអាចបង្ហាញឯកសារទាំងអស់នេះជូនទៅលោកសាក្សី ក៏ប៉ុន្តែខ្ញុំស្នើសុំថា យើងខ្ញុំអាចបន្តទៅមុខទៀត មិនចាំបាច់បង្ហាញទេ ដោយសារឯកសារទាំងអស់នោះស៊ីសង្វាក់ទៅនឹងឯកសារនេះ។ ឯកសារទីមួយ គឺ IS18.50

គឺរបាយការណ៍កិច្ចប្រជុំថ្ងៃទី២៧ ខែ០៩ ខែកញ្ញា ឆ្នាំ១៩៧៧។ ឯកសារទីពីរ លេខ ដីកាបញ្ជូនរឿងទៅស៊ើបសួរ 18.53 កិច្ចប្រជុំជាមួយនឹងអគ្គរដ្ឋទូតយូហ្គោស្លាវី ចុះថ្ងៃទី១៨ តុលា ៧៧។

[១៥:២៤:២១]

ឯកសារទីបី គឺលេខ D366/7.1.509 គឺជារបាយការណ៍ចុះថ្ងៃទី២២ ខែវិច្ឆិកា ៧៧។ ចំពោះឯកសារចុងក្រោយ គឺ D366/7.1.510 ជាកំណត់ហេតុកិច្ចប្រជុំ របាយការណ៍កិច្ចប្រជុំ ដែលរបាយការណ៍ផ្ញើទៅ បងហែម ចុះថ្ងៃទី២៩ ខែវិច្ឆិកា ៧៧។ នៅពេលដែលខ្ញុំលើកឡើងអំពីបញ្ហានេះ ខ្ញុំសូមបញ្ជាក់ដើម្បីជាប្រតិចារឹកថា មានរបាយការណ៍បែបនេះប្រហែលជាងម្ភៃ ដូចដែលខ្ញុំលើកឡើងយោងអម្បាញ់មិញ។ ឯកសារទាំងអស់នេះ គឺបានបង្ហាញថា សាក្សីរូបនេះ បានចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់នោះ។

លោក ល្មុត យើងខ្ញុំចង់សួរមួយចំនួនតូចទៅនឹងការនាំចេញ។ តើឯកសារចុងក្រោយអម្បាញ់មិញនេះ ធ្វើឲ្យលោកចងចាំដែរឬទេ? លោកបានឆ្លើយពីខាងដើមជូនយើងខ្ញុំរួចមកហើយ លោកបានលើកឡើងថា អង្ករ និង សណ្តែក ត្រូវបានគេនាំចេញ រួមទាំង កាហ្វេផងដែរ។ តើលោកនឹកឃើញទេ មានកសិផល និងទំនិញ ណាផ្សេងទៀត ដែលបានដឹកចេញពីប្រទេសកម្ពុជាដែរឬទេ?

[១៥:២៦:០៥]

**ឆ៖** ខ្ញុំមិនចាំទេបាទ។

**ស៖** ពាក់ព័ន្ធទៅនឹងស្រូវ ពាក់ព័ន្ធទៅនឹងអង្ករ ថាតើមានចំនួនស្រូវប៉ុន្មាន ដែលបានដឹកចេញទៅតាមឯកសារដែលលោកបានដឹង?

**ឆ៖** សូមបញ្ជាក់ថា ការងារនេះជាការងាររបស់ផ្នែកស្ទី នៃ គណៈកម្មាធិការពាណិជ្ជកម្ម។ ហើយដើងលេខអ្វីៗគេមិនដែលបានឲ្យខ្ញុំដឹងទេ អត់មានឲ្យខ្ញុំដឹងដើងលេខអស់នោះទេ។ លើកលែងតែលោកមានឯកសារយកមកបង្ហាញ ខ្ញុំអាចបញ្ជាក់ បើថាឲ្យខ្ញុំចាំ ខ្ញុំមិនចាំទេ។

**ស៖** សំណួរមួយទៀត លើប្រធានបទនេះ។ តើលោកចាំទេ តើកសិផល ឬទំនិញនេះ យកមកពីណាដែរ នៅពេលដែលគេយកទៅផែកំពង់សោមនោះ?

**ឆ៖** ខ្ញុំមិនដឹងជាគេយកមកពីណាទេ តែតាមស្មានវាមានតែយកពីជនបទហ្នឹងឯង តែត្រង់គេទៅយកមករបៀបម៉េច អ្នកណាទៅយក ខ្ញុំមិនអាចបញ្ជាក់បានទេ។

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមសួរខ្លីៗ នៅក្នុងអំឡុងពេលនោះ តើលោកធ្លាប់ជួប ឬក៏ធ្វើការ

ជួយនឹង ខៀវ សំផន ដែរឬទេ?

**ឆ៖** អត់ទេបាទ។ តាមខ្ញុំចាំអត់ទេបាទ។

**ស៖** ចុះចំពោះលោក អៀង សារី តើលោកធ្លាប់ធ្វើការជាមួយ ឬក៏ជួបជាមួយនឹងលោក អៀង សារី ដែរឬទេ?

[១៥:២៩:០៤]

**ឆ៖** គឺថាលោក អៀង សារី គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេស។ ខ្ញុំ អង្គភាពខ្ញុំមិនមែននៅក្រោមក្រសួងនេះទេ ហើយក្នុងការប្រជុំអីផ្សេងៗ ធ្លាប់បានទៅរួមប្រជុំជាមួយគាត់ក្នុង ឲ្យតែតំណាងជាខាងៗធនាគារជាសេដ្ឋកិច្ចហ្នឹង ហើយក៏ម្ដងម្កាលធ្លាប់ទៅ ពេលណាប្រជុំពីរឿងពាណិជ្ជកម្ម ពីសេដ្ឋកិច្ចអីអីចឹង។ ហើយខ្ញុំក៏មិនដែលបានចោទសួរខ្លួនឯង ថាតើម៉េចក៏គាត់មកប្រជុំរឿងហ្នឹង? អីខ្ញុំមិនបានចោទសួរទេ ហើយឃើញគាត់ប្រជុំ ប៉ុន្តែនិយាយពីរឿងពាណិជ្ជកម្ម រឿងអីអីចឹង។ ខ្ញុំទៅចូលរួមទៅ តែមិនមានស្អីផ្សេងទៀតទេ។

[១៥:៣០:០៨]

**ស៖** តើលោកនឹកឃើញទេ ចាំទេ ថានៅពេលនោះ លោក អៀង សារី មាននាទីអ្វីដែរ?

**ឆ៖** ខ្ញុំដឹងថាគាត់ជារដ្ឋមន្ត្រីក្រសួងការបរទេស។ ខ្ញុំដឹងប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ អ្វីដែលខ្ញុំចង់បន្តទៅជាមួយលោកសាក្សី សគីម ល្មុត ខ្ញុំនឹងបង្ហាញឯកសារមួយចំនួនជូនលោកមើល ហើយឯកសារទាំងនេះ គឺយើងបានបង្ហាញជូនលោកឲ្យបញ្ជាក់រួចហើយ នៅពេលដែលលោកផ្ដល់ការសម្ភាសទៅសហចៅក្រមស៊ើបអង្កេត គឺអ្នកស៊ើបអង្កេតមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញជូនគាត់ គឺថាឯកសារនេះគឺនិយាយអំពីទំនាក់ទំនងរវាងក្រុមហ៊ុនមួយនៅវ៉េនហ្វុង ជាក្រុមហ៊ុនដែលបានបង្កើតដោយកម្ពុជាប្រជាធិបតេយ្យនៅទីនោះ ហើយឯកសារនីមួយៗដែលខ្ញុំស្នើសុំបង្ហាញនេះ គឺៗបានពិភាក្សា គេយកបានឯកសារនេះពិភាក្សាជាមួយគាត់ឲ្យអ្នកស៊ើបអង្កេត របស់ការិយាល័យស៊ើបអង្កេតរួចហើយ នៅក្នុងបទសម្ភាសន៍ជាមួយគាត់កាលពីមុននោះ។

[១៥:៣១:៤៦]

ឯកសារទីមួយ មានលេខ D161/1.4។ នៅពេលពេលដែលគេបង្ហាញជូនសាក្សីនោះ គឺគេបាន ឲ្យលេខឯកសារនោះថា D279/7.5 ជាលិខិតដែលផ្ញើជូនទៅក្រុមហ៊ុនរ៉េនហ្វុង។ ដូចដែលខ្ញុំបាន ជម្រាបអ៊ីចឹងគឺថា អ្នកស៊ើបអង្កេតបានបង្ហាញជូនសាក្សីរួចហើយ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតតុលាការ ដើម្បីបង្ហាញជូនឯកសារនេះទៅសាក្សីក្នុងពេលនេះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ជាបឋមគឺ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាស យកទៅជូន សាក្សីពិនិត្យជាមុនសិន!

[១៥:៣៣:២៦]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សគីម ល្មុត តើលោកនឹកឃើញទេថា លោកបានឃើញឯកសារនេះដែលអ្នកស៊ើប អង្កេតបានបង្ហាញជូនលោក ដែលថា លោកបានចុះហត្ថលេខានៅទំព័រទីមួយនៃឯកសារនោះផងដែរ ពេលដែលគេបង្ហាញលោកនោះ។

**លោក សគីម ល្មុត៖**

**ឆ៖** បាទ ខ្ញុំ អ្នកស៊ើបអង្កេតពេលនោះបានបង្ហាញឯកសារនេះ ខ្ញុំក៏ចុះហត្ថលេខាថាបានៗ ឃើញ បានទទួលអានឯកសារនេះ។

[១៥:៣៤:១១]

**ស៖** សូមអរគុណ។ ឥឡូវនេះពិនិត្យមើល--

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានសូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរ ដើម្បី ឲ្យភាគីដទៃទៀតលោកបានមើលឃើញផងបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញជំនួយការអាចបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយ និងផ្នែកខាងសោតទស្សន៍ បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណ។ លោក ល្មុត តើលិខិតដែលចុះថ្ងៃទី០៧ កក្កដា ឆ្នាំ១៩៧៨ សំបុត្រនេះ

ផ្ញើជូនក្រុមហ៊ុន រ៉េនហ្វុង នៅហុងកុង តើមែនទេ? ខ្ញុំមិនសង្កត់ធ្ងន់ទៅលើខ្លឹមសារទាំងស្រុងនោះទេ ឯកសារនៅក្នុងឯកសារនេះ តើលោកអាចអានចំណារផ្ទាល់ដៃដែលមើលឃើញទំព័រទីមួយនៅខាងលើ តើលោកអាចអានបានដែរ ឬក៏ចង់ឲ្យខ្ញុំអានជាអង់គ្លេស ហើយមានការបកប្រែដើម្បីផ្ទៀតផ្ទាត់បាទ។

**ឆៈ** បាទ ខ្ញុំអានបានបាទ ខ្ញុំអាន សូមអាន "បានផ្ញើជូនបងហែម ហើយ។ ច្បាប់ដើម មើលមិនដាច់ មាន១សំបុត្រចម្លង ឡាំងឈុតគំរូ" ប៉ុន្មានឡាំងទេនែ៎? បាទ ដូចថាច្បាប់ដើមជូនបងហែម ហើយ១មានសំបុត្រចម្លង។ មានសំបុត្រចម្លងអីទេ "ហើយឡាំងឈុតគំរូ" បែបជាគំរូ ទំនិញដែលត្រូវជាឈុត១ផ្ញើឲ្យគេ។ ខ្ញុំអានបានប៉ុណ្ណឹងបាទ។

[១៥:៣៦:៣៤]

**សៈ** សូមអរគុណលោកច្រើន។ តើលោកអានជូនតុលាការស្តាប់នូវអត្ថបទនៅខាងចុង នៃសំបុត្រនេះ។ យើងចង់ដឹងថា តើអ្នកណាជាអ្នកចុះហត្ថលេខាបាទ បាទគឺពាក្យនៅក្រោមលេខ៧ តើលោកបានឃើញផ្នែកនោះទេ គឺនៅក្រោមកថាខណ្ឌលេខ៧នេះ បាទ មានពីរជួរនេះបាទ។

**ឆៈ** ឲ្យខ្ញុំអានអាលេខ៧ហ្នឹង ឬខាងក្រោម ខ្ញុំសូមបញ្ជាក់។

**សៈ** បាទ សូមអញ្ជើញលោកអានចាប់ពីលេខ៧ រហូតដល់បន្ទាត់ត្រង់ចុងបញ្ចប់នៅភ្នំពេញ ប្រសិនបើលោកអាចអានបាន?

**ឆៈ** បាទខ្ញុំសូមអានបាទ "សូមផ្ញើឈុតគំរូម្រេចខ្មៅចំនួនពីរគីឡូ ដើម្បីផ្ញើទៅសិង្ហបុរី ក្រុមហ៊ុនអ៊ីនត្រាកូ មានការស្នើសុំពីក្រុមហ៊ុននេះ"។ ហើយខាងក្រោមដាក់ "ដោយ អ្ហឹ... ដោយការគោរពបដិវត្តន៍យ៉ាងកក់ក្តៅ ហ្វ៊តត្រាភ្នំពេញ"។

**សៈ** តើត្រឹមត្រូវទេដែលខ្ញុំយល់ថានេះជាលិខិត សូមកែតម្រូវខ្ញុំ បើខ្ញុំខុស "នេះជាគំរូ ម្រេចគំរូម្រេចរបស់ខ្មែរផ្ញើពីរគីឡូដើម្បីជាគំរូឲ្យខ្មែរនាំចេញនោះ" តើអ៊ីចឹងមែនទេ?

**ឆៈ** បាទ អ៊ីចឹងហើយបាទ។

**សៈ** សូមអរគុណលោកច្រើន ហើយសំបុត្រនេះចុះហត្ថលេខាដោយដាក់ថា ហ្វ៊តត្រា។ តើហ្វ៊តត្រាហ្នឹងមានន័យដូចម្តេច? សូមលោកជម្រាបតុលាការផងបានទេ ហ្វ៊តត្រា ហ្នឹងជាអ្វីបាទ?

**ឆៈ** ហ្វ៊តត្រាហ្នឹងជាពាក្យកាត់មួយ។ ខ្ញុំមិនច្បាស់ទេ ពីព្រោះខ្ញុំមិនបានបង្កើតពាក្យហ្នឹងទេ ហើយខ្ញុំប៉ាន់ទៅថា ប្រហែលជាគេចង់ដាក់ថា ក្រុមហ៊ុនដូចជា ហ្វ៊ូរ ហ្វ៊ូររ៉េនត្រេត អ៊ីចឹង។ អាចកាត់ទៅអ៊ីចឹង ប៉ុន្តែខ្ញុំបញ្ជាក់ថា ខ្ញុំមិនបានបង្កើតពាក្យនេះដែរ ហើយក៏មិនបានចូលរួមបង្កើតពាក្យនេះដែរ។

ហើយខ្ញុំស្មាន ប្រហែលជាជា ហ្វ័រវ៉េនត្រេត ព្រោះ “ហ្វ័រ ឬហ្វ័រវ៉េន”, “ត្រា” អាចជា “ត្រេត”។ នេះជាការសន្និដ្ឋានរបស់ខ្ញុំទេ។ ខ្ញុំមិនអះអាងយ៉ាងម៉េចទេ។

[១៥:៣៩:៥០]

**ស៖** សូមអរគុណលោកច្រើន ដែលលោកបានជួយពន្យល់។ ឥឡូវនេះយើងបញ្ចប់ជាមួយឯកសារនេះ នៅពេលនេះ។ អ្វីដែលខ្ញុំចង់បង្ហាញជូនលោកបន្ទាប់នោះ គឺឯកសារមួយផ្សេងទៀត គឺជាលិខិតឆ្លើយឆ្លងទៅៗហុងកុង បាទ យើងមើលទៅឃើញអ៊ីចឹង។ ដែលជាថ្មីម្តងទៀត គឺអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្ហាញជូនលោកឯកសារនេះ លោកប្រធាន គឺលេខ IS21.142 ហើយនៅពេលដែលគេបានបង្ហាញជូនលោកសាក្សីនោះ គឺលេខនោះ D279.7.7 បាទ។ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញជូនឯកសារនេះទៅសាក្សីបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ជាបឋមមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យជាមុនសិន!

[១៥:៤១:១៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំទុកពេលបន្តិចជូនលោកសាក្សី លោក ល្អុត ប្រសិនបើលោកត្រូវការអានបាទ។ បាទ តើលោកនៅនឹកឃើញទេថា ខាងអ្នកអង្កេតរបស់ការិយាល័យសហចៅក្រមបានបង្ហាញឯកសារជូនលោកដើម្បីពិភាក្សាកាលនោះ?

**លោក សគីម ល្អុត៖**

**ឆ៖** បាទ គាត់បានបង្ហាញ ហើយខ្ញុំក៏បានចុះហត្ថលេខាថាបានៗទទួលអានដែរ។ គាត់បានបង្ហាញបាទ។

[១៥:៤២:០៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន សូមអនុញ្ញាតដើម្បីបង្ហាញឯកសារនៅលើអេក្រង់ផងដែរ ដើម្បីភាគីទាំងឡាយ

បានមើលផង។ ហើយបាទ ដើម្បីឲ្យភាគីដែលមិនអាចភាសាខ្មែរអាចមើលបាន បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញមន្ត្រីជំនួយការដាក់បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយនិងផ្នែកខាងសោតទស្សន៍ដាក់បង្ហាញឯកសារនេះ នៅលើអេក្រង់ទូរទស្សន៍!!

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** សូមអរគុណ។ លោក ល្អុត ថាតើលោកឃើញថា តើលោកបានឃើញលិខិតដែលចុះហត្ថលេខាដោយគណៈពាណិជ្ជកម្ម ជាលិខិតចុះថ្ងៃទី២២ តុលា ឆ្នាំ១៩៧៨ ដែលនៅក្នុងចំណងជើងនោះថា "ជម្រាបមកសមមិត្ត គ្រិន, ណាត ជាទីស្នេហា នឹករឮក"។ ហើយខ្ញុំនឹងពិនិត្យមើល ខ្ញុំមិនអាចអានភាសាខ្មែរបានទេ។ គោលបំណងប្រយោគទីមួយនោះ គឺយើងបានទទួលដំណឹងពីអង្គការស្តីពីសំបុត្រាយការណ៍របស់សមមិត្តក្នុងការផ្ទេរវាងសមមិត្ត គ្រិន និងសមមិត្ត សុខ និងការផ្ទេរភាគហ៊ុនពីសមមិត្តណាត ជូនទៅសមមិត្តផ្សេងមួយទៀត។ លោក ល្អុត លិខិតនេះទំនងជានិយាយអំពីការផ្ទេរភាគហ៊ុន បាទ ភាគទុន មិនមែនជាការផ្ទេរឈ្មោះ-- មួយទៀតមានការផ្ទេរឈ្មោះ ហើយនិងការផ្ទេរភាគទុនគឺរវាងសមមិត្ត គ្រិន និងសមមិត្ត សុខ បើជាការផ្ទេរឈ្មោះ។ រីឯការផ្ទេរភាគទុនវិញ គឺផ្ទេរពីសមមិត្តណាត ជូនទៅសមមិត្តមួយផ្សេងទៀត។

[១៥:៤៤:១៤]

ជាបឋមហ្នឹងខ្ញុំ យើងបានពិភាក្សាពីរឿងលោក គ្រិន សមមិត្ត គ្រិន ពីខាងដើម តើនេះជាមនុស្សដែលទេ គ្រិន នេះ ឬក៏ជាមនុស្សផ្សេង?

**លោក សគីម ល្អុត៖**

**ឆ៖** ខ្ញុំគិតថាជាមនុស្សដដែល។ ជាមនុស្សដដែលហ្នឹងបាទ។

**ស៖** ដូច្នេះ ដើម្បីរំឭកការចងចាំវិញ គឺសមមិត្ត គ្រិន នេះជាប្រធាននៃគណៈកម្មាធិការកំពង់ផែសមុទ្រនៅកំពង់សោម។ លោកសាក្សី តើលោកដឹងទេ សុខ ហ្នឹងជាអ្នកណា? សមមិត្ត សុខ និងសមមិត្តណាត ហ្នឹង? តើលោកនៅចាំទេ នឹកឃើញទេ?

[១៥:៤៥:០២]

**ឆ៖** សុខ ហ្នឹង បើខ្ញុំចាំគឺ គាត់ជាសមាជិកក្រុមហ៊ុន គាត់នៅ ដូចជានៅហុងកុង ហើយ ណាត ៗហ្នឹង ខ្ញុំមិន១បានស្គាល់ទេ។ ឈ្មោះហ្នឹងក៏មិនស្គាល់ ហើយគឺដឹងចុងក្រោយនៅថ្ងៃដែល១អ្នកស៊ើប

អង្កេត ថ្ងៃចុងបញ្ចប់ឲ្យឯកសារខ្ញុំមើលទៅថា ណាត ហ្នឹងជានរណាៗ។ ដែលពីមុនហ្នឹង ខ្ញុំមិនដឹងទេ។ តែគ្រាន់ថា គាត់ហ្នឹងវាជាមានភាគហ៊ុននៅក្នុងអាក្រុមហ៊ុននៅហុងកុងហ្នឹង។ វាអាចមាន សុខ ហ្នឹង ហើយនិង ណាត ហ្នឹង។ ហើយ គ្រិន ទៅ វាត្រូវទៅផ្ទេរហ៊ុនពីអ្នកណាមួយ អាហ្នឹងជាកិច្ចការរបស់ខាងពាណិជ្ជកម្ម។ ខ្ញុំមិនដឹងថា ខ្ញុំពន្យល់ទៅលោកយល់ ឬមិនយល់ទេ សូម-- បើមិនច្បាស់សូមសួរម្តងទៀត។

**ស៖** សូមអរគុណលោកច្រើនបាទ។ តើលោកអាចនឹកឃើញបានទេ តើគោលបំណងនៃការផ្ទេរភាគទុន ថាតើមានការផ្ទេរទៅ គ្រិន ឬក៏ផ្ទេរទៅអ្នកណាបាទ?

[១៥:៤៦:៣៦]

**ឆ៖** តាមដំណើរវាត្រូវតែផ្ទេរទៅ គ្រិន ហ្នឹងហើយ ព្រោះគាត់ ទៅក្រោយៗ ផ្ទេរពីឈ្មោះអ្នកណាទៅអ្នកណា អំ ពីអ្នកណា ខ្ញុំមិនច្បាស់ដែរទេ ប៉ុន្តែត្រូវផ្ទេរទៅ គ្រិន ហ្នឹង ព្រោះ គ្រិន ហ្នឹងគាត់ក៏ត្រូវទៅហុងកុង ធ្វើការនៅនោះ។ ហើយដើម្បីអ្វីហ្នឹង ខ្ញុំមិន-- មូលហេតុអី? ខ្ញុំក៏មិនអាចក្តាប់បានទេបាទ។

**ស៖** យើងខ្ញុំយល់ហើយ ប៉ុន្តែយើងគ្រាន់តែតាមដានមើល ថាតើការដំណើរការផ្ទេរហ្នឹងយ៉ាងដូចម្តេចតែប៉ុណ្ណោះទេ។ ដូច្នេះ ដើម្បីសង្ខេបអំពីការផ្ទេរភាគទុននេះពី វ៉េនហ្វុង ទៅលោក គ្រិន ហ្នឹងតាមដែលលោកពន្យល់ហ្នឹង។ បាទ តើអ៊ីចឹងមែនឬទេ?

**ឆ៖** អ៊ីចេះនេះគឺថាការផ្ទេរភាគហ៊ុននេះគឺមិនមែនពី វ៉េនហ្វុង ទៅ គ្រិន ទេ គឺពីភាគទុនដូចគ្នាគឺថា វ៉េនហ្វុង វាឈ្មោះក្រុមហ៊ុន ហើយនិងភាគទុន វាមានៗ ណាត វាមាន សុខ ហើយត្រូវផ្ទេរពីមួយទៅមួយ គឺថាផ្ទេរទៅមួយ មួយទៀតអស់សិទ្ធិហើយ ឧបមាថាផ្ទេរពី ណាត ទៅ គ្រិន, គ្រិន ជាម្ចាស់ភាគហ៊ុនថ្មី ណាត ហ្នឹងអស់ហើយ។ ហ្នឹងផ្ទេរអ៊ីចឹង។

**ស៖** សូមអរគុណលោកច្រើន។ នេះអ្វីជាចម្លើយដែលខ្ញុំចង់ព្យាយាមយល់នោះ គឺអ៊ីចឹង។

[១៥:៤៨:២៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

ឥឡូវនេះយើងមានឯកសារតែមួយទៀតទេ ដែលទាក់ទងទៅនឹង-- បាទជាលិខិតមួយផ្សេងទៀតដែលទាក់ទងទៅនឹងក្រុមហ៊ុននេះ។ លោកប្រធាន ខ្ញុំសូមឯកសារនេះគឺលេខ IS21.147 ហើយអ្នកអង្កេតបានបង្ហាញទៅសាក្សីនូវការសម្ភាសទីពីរ ហើយបានលេខកាលនោះគឺថា D279/7.9 បាទ គឺជា

លិខិតចេញពីសមមិត្តគណៈពាណិជ្ជកម្មជូនទៅក្រុម រ៉េនហ្វុង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ជាបឋម មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំជូនពេលបន្តិចទៅលោកសាក្សីដើម្បីអាន។ ហើយសូមអនុញ្ញាតខាងប្រព័ន្ធសោតទស្សន៍រៀបចំដាក់ឯកសារនេះនៅលើអេក្រង់ផងដែរបាទ។

[១៥:៤៩:៥២]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ល្មុត តើលោកនៅចាំទេថា អ្នកអង្កេតបានបង្ហាញជូនលោកនូវឯកសារនេះ ហើយលោកបានចុះហត្ថលេខាពេលដែលបានទទួលកាលនោះ នោះ?

**ឆ៖** អត់ទោស ខ្ញុំអានមួយភ្លែត មើលមួយភ្លែត។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទៅសម្រួលនូវឧបករណ៍ស្តាប់សំឡេងរបស់គាត់ ឲ្យបានស្រួលបួលផង។

*(សាក្សីអានឯកសារ)*

[១៥:៥០:៥៣]

**លោក សគឹម ល្មុត៖**

**ឆ៖** បាទ ខ្ញុំបានអានចប់ហើយ ក្នុងនោះខាងលោកដែលទៅស៊ើបអង្កេតពេលនោះ គឺថាបានៗដូចថាឲ្យខ្ញុំឃើញរួចហើយ។ ហើយក្នុងនោះ ខ្ញុំមិនបានស៊ីញ៉េទេ ប៉ុន្តែតាមខ្ញុំចាំដូចជាបានឃើញអ៊ីចឹងហើយ បានបង្ហាញ។ គេសរសេរណែនាំទៅ ឲ្យសហការគ្នាធ្វើអីៗ អ៊ីចឹងទៅ។ តែខ្ញុំ កាលនោះអត់មានឲ្យខ្ញុំស៊ីញ៉េថាបានឃើញ មិនឃើញទេ ប៉ុន្តែខ្ញុំដូចជាបាន-- ដូចជាគាត់បានបង្ហាញដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបុគ្គលិកជំនួយការ បង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ ហើយនិងផ្នែកខាងសោតទស្សន៍ គ្រប់ឯកសារទាំងអស់ដែលដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័រ លោកត្រូវតែដាក់ដោយស្វ័យប្រវត្តិតែម្តងជាមួយគ្នានឹងការបង្ហាញនៅលើអេក្រង់កុំព្យូទ័រ គឺដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍។

[១៥:៥២:០៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំនឹងសួរដោយសង្ខេបទេ អំពីឯកសារនេះ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នេះជាលិខិតចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៨ បាទ សរសេរឡើងដោយគណៈកម្មាធិការពាណិជ្ជកម្ម។ ហើយខ្ញុំនឹងអានផ្នែកដែលពាក់ព័ន្ធដើម្បីឱ្យលោកសាក្សីជួយបំភ្លឺបន្ថែម។ លិខិតនេះចាប់ផ្ដើងឡើងដោយគឺថា៖ “ជូនសមមិត្ត គ្រិន និងសមមិត្ត ណាត ជាទីស្នេហា និងនឹករឭក”។ កថាខណ្ឌទី១៖ “យើងខ្ញុំបានទទួលការណែនាំមកថា សមមិត្ត សុខ និងសមមិត្ត ណាត ត្រូវទទួលភារៈថ្មីនៅពេលខាងមុខឆាប់នេះ”។

[១៥:៥៣:១១]

ហើយខ្ញុំអានកថាខណ្ឌទី៣ ដើម្បីឱ្យលឿន ផ្លោះចោល គឺថា៖ “ក្រោយពីរៀបចំការងារបានចប់សព្វគ្រប់ហើយ យើងខ្ញុំនឹងស្នើឱ្យសមមិត្ត គ្រិន ជួយរៀបចំដំណើរវិលមកក្នុងប្រទេសវិញរបស់មិត្ត ណាត និងកុមារ សានហ្វេង ឱ្យបានស្រួលផង និងធានាសុខភាព”។ ហើយនៅក្នុងឯកសារនេះសូមលោក ល្មុត កែខ្ញុំបើខុស។ ហើយនៅក្នុងនេះ សុខ និង ណាត គឺជាភាគទុន ម្ចាស់ភាគទុននៅក្នុងក្រុមហ៊ុន ដែលទទួលផ្ទេរភាគហ៊ុនថ្មី ទទួលភារកិច្ចថ្មី ឱ្យពួកគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ។ តើខ្លឹមសារហ្នឹងមានន័យអ៊ីចឹងដែរឬទេបាទ?

[១៥:៥៤:០២]

**លោក សគឹម ល្មុត៖**

**ឆ៖** បាទ ខ្លឹមសារហ្នឹងមានន័យអ៊ីចឹងហើយបាទ គឺឱ្យពីរនាក់ហ្នឹងមក ប្រគល់សិទ្ធិឱ្យទៅ--ផ្តល់ហ៊ុនទៅលោក គ្រិន ហើយពីរនាក់ហ្នឹងមក គ្រិន ហ្នឹងដំណើរការទៅ ហើយឱ្យយកចិត្តទុកទៅនឹងធ្វើដំណើរការឱ្យអីឯណាឱ្យត្រឡប់មកវិញ។ គឺក្នុងន័យអ៊ីចឹងហើយបាទ។

**ស៖** សូមអរគុណ។ លោកបានប្រាប់តុលាការថា លោកដឹងថា លោកគិតថា ហើយលោកបានពិនិត្យឃើញនៅក្នុងឯកសារនេះ ដែលអ្នកអង្កេតបានបង្ហាញលោកពីការិយាល័យចៅក្រមអង្កេតហ្នឹង គឺថា ណាត និងប្រពន្ធរបស់គាត់បានអនុវត្តតាមហ្នឹង។ តើលោកបានដឹងដែរឬទេ ថាតើមានបញ្ហាអ្វីកើតឡើងដល់អ្នកទាំងនោះតាមការណែនាំរបស់គណៈពាណិជ្ជកម្មកាលនោះៗ?

**ឆ៖** ខ្ញុំបាទមិនដឹងទេ ហើយព្រោះសំបុត្រអានេះ គឺថាគណៈកម្មការគេសរសេរទៅគឺ មិនមានខ្ញុំអីទៅពាក់ព័ន្ធនឹងរឿងនេះទេ។ អត់មានបានដឹងទេ ដោយសារអ្នកអង្កេតបង្ហាញខ្ញុំទេ បានខ្ញុំដឹងទៅ ហើយជួយៗពន្យល់ន័យខ្លះទៅ តែថាពេលគេសរសេរផ្ញើទៅ ខ្ញុំអត់បានដឹងទេបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ មានឯកសារមួយទៀត ទាក់ទងទៅនឹងដែលអញ្ជើញឲ្យបុគ្គលហ្នឹងត្រឡប់មកពីបរទេសមកស្រុកខ្មែរ ប៉ុន្តែខ្ញុំមើលពេលទៅលោកប្រធាន ប្រហែលជាមិនចាំបាច់បង្ហាញទៅសាក្សីទេ។ ខ្ញុំគ្រាន់តែអានឯកសារ លេខឯកសារដែលពាក់ព័ន្ធ ហើយនិងអានផ្នែកដែលពាក់ព័ន្ធ ដើម្បីពិនិត្យមើលឯកសារនេះគឺ IS3.1 បានដាក់លេខជា E ផងដែរពីមុននោះគឺ E3/1532។ នេះគឺជាៗបញ្ជីអ្នកទោសមកពីស-២១ ដែលមានឈ្មោះថា អ៊ិន សុខ ដែលគេរៀបរាប់ថា ជាប្រធានខាងពាណិជ្ជកម្ម--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៥:៥៦:៥៨]

**លោក គង់ សំអុន៖**

សូមអរគុណ។ ខ្ញុំបាទយល់ថា សហព្រះរាជអាជ្ញាកំពុងតែធ្វើសេចក្តីថ្លែងនៅពេលនេះ ហើយមិនមែនជាការបង្ហាញចំពោះសាក្សីទេ។ ដូច្នេះ សូមជំទាស់ចំពោះការធ្វើបែបនេះបាទ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា រៀបចំនូវការត្រៀមលក្ខណៈក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីឲ្យបានល្អប្រសើរ ដើម្បីចៀសវាងឲ្យផុតពីការជំទាស់តវ៉ា គេមើលទៅឃើញថា វាអាចជាការ ជាគោលបំណងនៃការធ្វើសកម្មភាព នាំមុខសាក្សីក្នុងការឆ្លើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំៗបញ្ឈប់នៅពេលនេះ ហើយខ្ញុំបានយោងទៅលេខឯកសារ ហើយខ្ញុំគ្រាន់តែចង្អុលបង្ហាញពី IS3.5 ក៏ពាក់ព័ន្ធទាក់ទងទៅនឹង ណាត នោះផងដែរ។

បាទ គឺ IS3.5 មូលហេតុដែលខ្ញុំយោងទៅរកឯកសារនេះ ពីព្រោះគាត់បានបញ្ជាក់នៅក្នុងការសម្ភាសនោះថា គាត់-- បាទគឺថា មានបង្ហាញនៅក្នុងឯកសារពាណិជ្ជកម្មផងដែរ។

[១៥:៥៨:២៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ដោយសារនៅពេលវេលាមានកម្រិតខ្លី លោក ល្អុត យើងអាចត្រឡប់ទៅមនុស្សមួយចំនួនដែលលោកបានបញ្ជាក់ប្រាប់តុលាការកន្លងមកនេះ។ លោកបាននិយាយថា ខឿន ដែលគឺជា អ្នកដែលកាន់តំណែងមុន វ៉ាន់ រិទ្ធ នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម ត្រូវបានបាត់ខ្លួន ឬក៏គេដកចេញ។ តើលោកដឹងទេ ក្រោយមក ខឿន ហ្នឹងគាត់ជួបវាសនាដូចម្ដេចដែរ?

**លោក សគឹម ល្អុត៖**

**ឆ៖** ខ្ញុំមិនបានចាំថ្ងៃខែឆ្នាំច្បាស់ទេ តែពាក្យថា "បាត់ខ្លួន" "ដកខ្លួន" គឺថា ចំពោះខ្ញុំគឺថា ចេញទៅខ្ញុំថា បាត់ទៅ បានថាដកក៏បាន ដកចេញទៅ ខ្ញុំមិនសំដៅថា យ៉ាងម៉េចៗទេ គ្រាន់តែធ្លាប់នៅហ្នឹង ម្ល៉ៃគាត់អត់ឃើញនៅហ្នឹង ពេលក្រោយមកថាបាត់ខ្លួនទៅថា គេផ្លាស់ចេញទៅមិនដឹងរឿងពិតយ៉ាងណាទេ ដឹងថា ពីថ្ងៃមួយអ៊ីចឹងទៅ គាត់ដូចធ្លាប់ធ្វើជាប្រធានគណៈកម្មាធិការ មិនឃើញគាត់មកទៀត ខ្ញុំមិនសន្និដ្ឋានថា "បាត់" ថា "ដក" ថាអី ពាក្យពេចន៍ ខ្ញុំមិនប៉ានឲ្យនិយមន័យយ៉ាងម៉េចៗទេ គ្រាន់តែថាមិនឃើញគាត់មកធ្វើការទៀត។

[១៦:00:00]

**ស៖** តើលោកដឹងទេក្រោយមកលោកដឹងទេ តើ ខឿន នេះជួបបញ្ហាអ្វី? ឬក៏គាត់ជួបបញ្ហាអ្វីទេក្រោយពីនោះមកនោះ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេបាទ។

**ស៖** សូមអរគុណ។ ដើម្បីកំណត់ត្រានោះគឺថា ខឿន នៅចម្លើយសារភាពស-២១ ឯកសារ IS21, IS5.22 គឺបញ្ជីអ្នកទោស ស-២១ គឺលេខ ៩៥៤៦។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំចង់ទៅប្រធានបទថ្មី ប៉ុន្តែមើលពេលទៅដូចជាកៀកម៉ោង។ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តបន្តិចទៀត ឬក៏បង្អង់ត្រឹមនេះសិនបាទ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឃើញថាម៉ោងបួនជាងហើយ ប៉ុន្តែមានការ ខ្ញុំមានការជំទាស់

មួយអំពីវិធីសាស្ត្ររបស់សហព្រះរាជអាជ្ញានេះ គឺថា សាក្សី គាត់ថាគាត់មិនដឹងទេ ប៉ុន្តែៗសហព្រះរាជអាជ្ញាក៏ចេះតែឲ្យគាត់ធ្វើសក្ខីកម្មទៅឯកសារស-២១ ហើយយើងមិនអាចយកឯកសារទាំងនោះយកមកដាក់ផ្ទាល់សាក្សីឲ្យគាត់ឲ្យយោបល់ទេ ពីព្រោះថាធ្វើបែបនេះមិនសមស្របទេ។

[១៦:០១:២៩]

ដូច្នេះហើយសាក្សី គាត់ត្រូវគិតថា គាត់ទៅធ្វើការនៅស-២១ បានដឹង ឬក៏វាអាចសមស្របនឹងការតាំងសំណួរ ប៉ុន្តែដោយស្មោះត្រង់ គឺថាការធ្វើបែបនេះគឺមិនសមស្របទេ គឺមានជំទាស់ ការជំទាស់ជាច្រើនបានធ្វើឡើង ប៉ុន្តែសហព្រះរាជអាជ្ញានៅតែបន្ត ហើយសាក្សីនៅតែឆ្លើយ។ ដូច្នេះគឺថាដោយសារថា មិនគប្បីឲ្យសាក្សី គាត់ផ្តល់សក្ខីកម្មទៅលើឯកសារផ្សេងដែលមិនពាន់ព័ន្ធ ហើយវានៅឆ្ងាយពីការយល់ដឹងរបស់គាត់នោះផងដែរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមបំភ្លឺបន្ថែម។ មូលហេតុដែលខ្ញុំយោងទៅរកឯកសារទាំងអស់នេះ គឺថាយើងៗនឹងមានសវនាការដ៏វែង ហើយយើងធ្វើការដោះស្រាយពិភាក្សាលើឯកសារដ៏ច្រើន ហើយខ្ញុំបានប្រើការចងចាំទាំងអស់របស់សាក្សី គឺមិនមានអ្វីមិនសមស្របនោះទេ គឺថាយើងកត់ត្រានៅក្នុងកំណត់ត្រាហើយ ថាឯកសារហ្នឹងគឺពាក់ព័ន្ធទៅនឹងគាត់ លើកលែងតែមេធាវីការពារចង់ជំទាស់ថាបញ្ជាក់ថាជនណាមួយត្រូវបានចាប់មកស-២១ សម្លាប់យ៉ាងយ៉ាងណាដោយជាក់លាក់ ដែលក្រៅពីការយល់ដឹងរបស់គាត់នោះទើបមិនពាក់ព័ន្ធ។

[១៦:០២:៤៦]

**លោក ម៉ែខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យធ្វើ ឲ្យលោកឆ្លើយទៀតទេ លោក កាណាវាស ចាប់ពីពេលនេះតទៅ គឺលោកអាចមានឆ្លើយ មានសិទ្ធិក្នុងការតវ៉ាជំទាស់តែម្តងគត់ មិនអាចអនុញ្ញាតឲ្យលើសពីម្តងទេចំពោះបញ្ហាមួយ។ សូមភាគីទាំងអស់ជ្រាប។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៤:៥៨]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក អៀង សារី គ្មានប្រសិទ្ធភាព។ ឯកសារនេះ គឺសហព្រះរាជអាជ្ញាបាន-- គ្រាន់តែបង្ហាញអំពីភាពពាក់ព័ន្ធនៃឯកសារនេះ ដែលមាននៅក្នុងសំណុំរឿងករណីពីមុនៗមកតែប៉ុណ្ណោះ។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។

លោក សគឹម ល្មុត ដំណើរការសវនាការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ ដែលត្រូវបន្តធ្វើនៅថ្ងៃចន្ទ ទី៤ ខែមិថុនា ឆ្នាំ២០១២ តទៅទៀត។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទ ទី៤ ខែមិថុនា ឆ្នាំ២០១២ ដែលនឹងត្រូវចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយដូចគ្នានេះដែរ សូមអញ្ជើញលោកមេធាវីប្រឹក្សាសាក្សីមកចូលរួម ដើម្បីប្រឹក្សាសាក្សីនៅថ្ងៃ និងពេលវេលាដូចគ្នាជាមួយនឹងសាក្សីដែលត្រូវផ្ដល់សក្ខីកម្មនៅទីនេះដែរ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សី សគឹម ល្មុត វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងប្រាំបួនព្រឹក ថ្ងៃចន្ទ ទី៤ ខែមិថុនា ឆ្នាំ២០១២។

ហើយឥឡូវកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ឃើញថាដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី៤ ខែមិថុនា ឆ្នាំ២០១២ ដែលចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ការធ្វើសវនាការនៅថ្ងៃចន្ទសប្ដាហ៍ក្រោយនេះ នឹងបន្តស្ដាប់សក្ខីកម្មសាក្សី សគឹម ល្មុត ដែលនឹងតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនឲ្យបានជ្រាបផងដែរថា កិច្ចដំណើការសវនាការដែលគ្រោងធ្វើនៅសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះអាចនឹងដំណើរការស្ដាប់ស្ដាប់សក្ខីកម្មឆ្លាស់គ្នារវាងសាក្សី សគឹម ល្មុត ជាមួយនឹងសាក្សីមួយរូបទៀត ដែលមានរហស្សនាម TCW-604 ទៅតាមស្ថានភាពជាក់ស្ដែង ប្រសិនបើអាចប្រព្រឹត្តទៅដូច្នេះ។

[១៦:០៧:១៩]

ហើយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ

ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី៤ ខែមិថុនា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*